ជីវិតប្រក្រតី

ភាគទី ២


Night view of the Mahabodhi Mahavihara

មណ្ឌលពុទ្ធគយានាពេលរាត្រី

មិនសេពគប់សប្បុរស

គឺ នឹង មានសទ្ធាមគពីណា

ប្រៀងដោយ:

ឧសក ឆា សុខា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ជីវិតប្រក្រតី
ភាគទី ២

មិនសេពគប់សប្បុរស

តើ ជិនមានសទ្ធាមកពីណា

១រោច ខែ ពិសាខ ឆ្នាំ ថោះ ត្រីស័ក ព.ស.២៥៥៥

រៀបរៀងដោយ
ឧបាសក នា ស៊ុខា

បានស្កានឡើងវិញសម្រាប់ជាធម្មទាន
ដែលបានអនុញ្ញាតដោយ ឧបាសក នា សុខា

Scan by:

www.5000-years.org

ជីវិតប្រក្រតី

ភាគទី ២

មិនសេពគប់សប្បុស តើ នឹងមានសទ្ធាមកពីណា

សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះអ្នក ដែលបានយកចិត្តទុកដាក់ ជួយផ្ទៀងផ្ទាត់កែសម្រួល នូវអក្ខរាវិរុទ្ធ និងពាក្យបាលី ដោយមានព្រះភិក្ខុ **ឡាយ សារិន្ធិ** គង់នៅវត្ត សំពៅមាស ឧបាសក **ដាំ កុយ** ជាសមាជិកសមាគមទ្រទ្រង់ អក្សរសាស្ត្រ និងវិប្បធម៌ខ្មែរ ព្រមទាំងពុទ្ធបរិស័ទអ្នកចូលរួម ជួយឧបត្ថម្ភ និងខិតខំប្រមូលប្រាក់ ដើម្បីធ្វើឱ្យដំណើរការបោះ ពុម្ពសៀវភៅ "ជីវិតប្រក្រតីភាគទី២" បានសម្រេចជាស្ថាពរ ។

សូមសិរីសួស្តី ចូរមានដល់អ្នកគ្រប់ពេលកុំបីអាក់ខានឡើយ ។

លេខទូរស័ព្ទ : ០១១ ៦៧ ៣៤ ០៦

អារម្ភកថា

កាលបើនឹករលឹកទៅដល់កុសលវិបាកបដិសន្ធិ ជីវិតមនុស្ស យើង គួរតែខំប្រឹងប្រែងបំពេញសេចក្តីល្អឱ្យបានច្រើន ទុកសម្រាប់ធ្វើដំណើរឆ្លងអន្លង់ទុក្ខទាំង៤ ព្រោះសង្សារវដ្តនេះ មានកាលមិនទៀងទាត់ ចេះតែវិលជុំវិញកង់បដិច្ចសមុប្បាទ អាស្រ័យពីកិលេសវដ្ត: កម្មវដ្ត: និងវិបាកវដ្ត:របស់តំណសង្ខារធម៌ជានិច្ចកាល មិនដឹងខាងដើមពីត្រីមណា និងខាងចុងគ្មានទីបញ្ចប់ក៏មិនចាំបាច់ទៅត្រិះរិះ ស្រាវជ្រាវតាមវិជ្ជាផ្លូវលោករបស់អ្នកវិទ្យាសាស្ត្រទំនើប នឹងមិនអាចបានសម្រេចជោគជ័យ ក្រៅពីព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងនូវការពិត គឺ ធម្ម យ៉ាងដូច្នោះ។

ដំណើរជីវិត ប្រព្រឹត្តទៅតាមបវេណីរបស់សភាវធម៌ដែលមានត្រឹមតែ**ធម្ម** ទោះបានជួបនូវអ្វីៗ ត្រូវតែប្រាស់ព្រាត់វិនាសទៅវិញ មិនអាចឃាត់ឃាំង ឬចាប់ទុកយកមកធ្វើជារបស់ខ្លួនបានដែរ ព្រោះហេតុដូចបានជម្រាបជូនមកនេះ ក៏យើងត្រូវសិក្សាស្វែងយល់នូវការពិតនោះ ហៅថា **សិក្ខេ និព្វានមគ្គោ** បានសេចក្តីថា សិក្សា ដើម្បីសេចក្តីសុខស្ងប់នូវព្រះនិព្វានដោយខ្លួនឯង ។

នេះជាក្រសែជីវិតក្នុងវដ្តទុក្ខរបស់សត្វលោក រស់នៅជាធម្មតាគ្រប់ៗគ្នាក្នុងភព ៣ គឺ កាមភូមិ រូបភូមិ និង អរូបភូមិ ដែលពុំមានភូមិណាមួយតាំងនៅឋិតថេរ រឿងរហូតនោះឡើយ ។

អាស្រ័យពីការយល់ឃើញក្នុងដំណើរផ្លូវវែងឆ្ងាយ ដូចបានលើកឡើងមកនេះ យើងខ្ញុំសូមជម្រាបជូននូវការពិតនោះដែលបានដកស្រង់ចេញពីក្នុងគម្ពីរក្បួនច្បាប់ មានព្រះត្រៃបិដក និង អដ្ឋកថា ជាដើម ទៅតាមការចេះដឹងខ្លះៗ ទុកជាជំនួយដល់កិច្ចបដិបត្តិឱ្យកើតប្រយោជន៍ក្នុងព្រះពុទ្ធសាសនា ។

សូមសម្តែងនូវការគោរពកោតក្រែង ចំពោះលោកគ្រូអគ្គបណ្ឌិត ជាទីកក់ក្តៅ និងរង់ចាំទទួលការជួយកែសម្រួលពីសម្ងាត់អ្នកសិក្សាទាំងឡាយ ដោយសេចក្តីអនុគ្រោះ ។

រាជធានីភ្នំពេញ

ថ្ងៃ ពុធ ០១ រោច ខែ ពិសាខ

ឆ្នាំ ថោះ ត្រីស័ក ព.ស.២៥៥៥

រៀងរៀងដោយ

ឧបាសក **ឆា សុខា**

បញ្ជីមាតិកា

ល.រឿង	ចំណងមាតិកា	ទំព័រ
០១	ជីវិតប្រក្រតី	០១
០២	មូលហេតុនាំឱ្យកើតមង្គលបញ្ហា	០៥
០៣	មង្គលសូត្រ	១១
០៤	អដ្ឋកថា	១៤
០៥	ពណ៌នាគាថាទី១ អសេវនា ច	១៧
០៦	ពណ៌នាគាថាទី២ ថា បដិរូបទេសវាសោ ច	៣៣
០៧	ពណ៌នាគាថាទី៣ ថា ពាហុសច្ចញ្ច	៣៨
០៨	ពណ៌នាគាថាទី៤ ថា មាតាបិតុឧបដ្ឋានំ	៤៤
០៩	ពណ៌នាគាថាទី៥ ថា ទានញ្ច	៥១
១០	ពណ៌នាគាថាទី៦ ថា អារតី	៥៥
១១	ពណ៌នាគាថាទី៧ ថា គារវោ ច	៥៩
១២	ពណ៌នាគាថាទី៨ ថា ខន្តី ច	៦៧
១៣	ពណ៌នាគាថាទី៩ ថា តបោ ច	៧៣
១៤	ពណ៌នាគាថាទី១០ ថា ផុដ្ឋស្សលោកធម្មេហិ	៧៦

១៥	ពណ៌នាគាថា ឯតាទិសានិ	៧៩
១៦	សង្ខេបសេចក្តីក្នុងព្រះគាថា	៨៦
១៧	ដំណើរប្រព្រឹត្តទៅចេញចាកលោក	៩១
១៨	សេចក្តីអធិប្បាយ	៩៧
១៩	កុណ្ឌលិយសូត្រ	១១៣
២០	អដ្ឋកថា កុណ្ឌលិយសូត្រ	១១៩
២១	សតិប្បដ្ឋាន	១២៥
២២	អដ្ឋកថា	១៣២
២៣	ព្រៃខ្មោច ៩ យ៉ាង	១៣៧
២៤	អរិយសច្ចៈក្នុងនវសីវថិកា	១៣៩
២៥	សេចក្តីអធិប្បាយ	១៣៩
២៦	មហាវគ្គ មគ្គកថា	១៤៩
២៧	ការប្រសូតរបស់ព្រះមហាបុរស	១៥៤
២៨	រឿងពាណិជ ៧00 នាក់	១៦0
២៩	ប្រវត្តិសង្ខេបរបស់ព្រះពុទ្ធឃោសាចារ្យ	១៦៦
៣0	ព្រះត្រៃសរណគមន៍ជាទីពឹង (កំណាព្យ)	១៨២
៣១	មតិបូកសរុប	១៨៣
៣២	ចប់	១៨៦

ជីវិតប្រក្រតី

ជីវិតប្រក្រតី ជាជីវិតរស់នៅក្នុង**ធម្ម** មាននាមរូបជាទីតាំងនៃសតិរលឹកដឹងទាន់ សម្រាប់ធ្វើកិច្ចការប្រចាំថ្ងៃ មានកុសល អកុសល និងអព្យាគត តាមខ្សែវិថីចិត្តរបស់បញ្ចទ្វារ និងមនោទ្វារ សន្សំទុកនៅក្នុងសន្តាន គឺ ជវនវិថីចិត្តដែលទទួលសោយអារម្មណ៍គ្រប់ ៧ ខណចិត្ត ទើបបញ្ជូនទៅឱ្យតទាលម្ភណចិត្ត រួចធ្លាក់ចុះកាន់ភវង្គដើមធ្វើកិច្ច ចំនួន៤វារៈ គឺ អតីតគ្គហណៈ សមូហគ្គហណៈ អត្ថគ្គអហណៈ និង នាមគ្គហណៈ ឬអតីតគ្គហណៈ សមូហគ្គហណៈ នាមគ្គហណៈ អត្ថគ្គហណៈ តាមសោតទ្វារ ហើយធ្វើកិច្ចការនេះរឿងរហូតជានិច្ចកាល ។

ដំណើរជីវិតរបស់រូបធម៌នាមធម៌ មានការមិនប្រកាន់នូវអ្វីៗទាំងពួង ទោះបីល្អប្រណីត ថោកទាប អាក្រក់ មិនសមរម្យយ៉ាងណា ក៏មានត្រឹមតែចិត្តកើតឡើងដឹងអារម្មណ៍ ហើយរលត់ទៅស្មើគ្នា ជាសាមញ្ញលក្ខណៈទុកបង្ហាញប្រាប់ពិភពលោកដែលកំពុងរស់នៅយ៉ាងសប្បាយរីករាយ ក្នុងគំនរទ្រព្យសម្បត្តិ មាស ប្រាក់ សម្ភារនិយម តាមការច្នៃប្រឌិតរបស់ពំនិតអ្នក

វិទ្យាសាស្ត្រដែលបញ្ជាក់ប្រាប់ថា ជាសម័យ ចម្រើន ខ្លាំងក្លា ខាងផ្នែកសម្ភារៈ ញ៉ាំងឱ្យតណ្ហា មានៈ ទិដ្ឋិ គ្របដណ្តប់ លើជីវិតសព្វសត្វ មិនសូវទទួលបាននូវភាពសុខសាន្ត ព្រោះត្រូវ ទន់ជ្រាយទៅតាមកម្លាំងខ្យល់តណ្ហាបក់បោកប៉ះខ្លប់ ដល់ផ្លូវចិត្ត បណ្តាលឱ្យមនុស្សម្នាមហាជនទាំងឡាយ ត្រេកត្រអាលភ្លើត ភ្លើនជួបនូវឧបទ្ទវហេតុ ឬឧបសគ្គផ្សេងៗ ជាច្រើនប្រការ ដោយ មិនដឹងពីមូលហេតុអ្វី ហើយក៏យល់ច្រឡំថា មកពីបុគ្គលនេះ ឬបុគ្គលនោះ ឬក្រុមនេះ ឬពួកនោះ ឬប្រទេសនេះ ឬ ព្រះអាទិទេព ដែលយើងយល់ថាជាអ្នកបង្កើតទឹកដី ភ្លើង ខ្យល់ ព្រៃភ្នំ ទន្លេ បឹងបួ សមុទ្រ សព្វសត្វ ឬ ព្រះអាទិត្យ ព្រះច័ន្ទ ព្រមទាំងជោគជាតិភាព គឺពន្លឺមានពួកផ្តាយក្នុងលំហអាកាស (មេឃ) ព្រោះពុំបានយល់ជ្រួតជ្រាបនូវការពិត។

ដោយប្រការនេះ បានជាត្រូវរៀបចំជីវិត ឱ្យមាន សុភមង្គលទៅតាមធម្មជាតិដែលមានព្រះពុទ្ធអង្គ ទ្រង់ត្រាស់ ដឹងឡើង ដើម្បីជួយស្រោចស្រង់សត្វ ឱ្យរួចពីទុក្ខកង្វល់គ្រប់យ៉ាង ។

នៅក្នុងសំយុត្តនិកាយ មហាវារវគ្គបិដកលេខ ៣៨/៣៣ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងថា:

ម្នាលអានន្ទ ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីរលឹក មិនមានវត្ថុដទៃជារលឹក មានធម៌ជាទីពឹង មានធម៌ជាទីរលឹក មិនមានវត្ថុដទៃជាទីរលឹកតើដូចម្តេច។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតីកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមដុតកម្តៅ កិលេស ជាអ្នកដឹងខ្លួន មានស្មារតីកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ម្នាលអានន្ទ ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីរលឹក មិនមានវត្ថុដទៃជាទីរលឹក មានធម៌ជាទីពឹង មានធម៌ជាទីរលឹក មិនមានវត្ថុដទៃជាទីរលឹក យ៉ាងនេះឯង ។

ម្នាលអានន្ទ ពួកជនឯណានិមួយមានខ្លួនជាទីពឹង មានខ្លួនជាទីរលឹក មិនមានវត្ថុដទៃជាទីរលឹក មានធម៌ជាទីពឹង មានធម៌ជាទីរលឹក មិនមានវត្ថុដទៃជាទីរលឹក ក្នុងកាលឥឡូវនេះ ឬថាក្នុងកាលជាអំណើះ អត់អំពីតថាគតទៅ ម្នាលអានន្ទ ពួកភិក្ខុណានិមួយ មានសេចក្តីប្រាថ្នានូវការសិក្សា ភិក្ខុទាំងនោះនឹងប្រាកដមានក្នុងចំណែកដ៏ប្រសើរក្រៃលែង ។

ជីវិតប្រក្រតី ជាជីវិតភ្លឺស្វាងប្រព្រឹត្តទៅគ្រប់តរិយាបថ ទាំង ៤ មានការទ្រទ្រង់បាត្រ និងចីវរជាដើម ក៏ដើម្បីអប់រំបញ្ញា ចេញចាកលោក ដូចជា នៅពេលភ្ញាក់ពីដំណេក វិថីចិត្តកើតឡើង ដឹងអារម្មណ៍តាមទ្វារ ៦ ណាមួយ នាំឱ្យមានការធ្វើអ្វីៗគ្រប់ យ៉ាង ។ មុនដំបូងចូលបន្ទប់ទឹក មានការសំអាតខ្លួនប្រាណ និង បន្ទោបង់ ឧបច្ចារៈ បស្សាវៈ ជាដើម ហើយក៏ស្លៀកពាក់ តុបតែងខ្លួនឱ្យបានស្អាតបាត បន្ទាប់មកចូលបន្ទប់ ទទួលទាន អាហារ រួចធ្វើដំណើរ ទៅស្តាប់ធម្មទេសនា ឬបំពេញការងារ តាមមុខជំនាញរៀងៗ ខ្លួន ។ ទាំងនេះ សុទ្ធតែជាកិច្ចការរបស់ នាមរូប អាស្រ័យពី វាយោធាតុដែលមានកិរិយាចិត្តជាសមុដ្ឋាន ដោយកាយានុបស្សនាសតិប្បដ្ឋាន ក្នុងតរិយាបថបព្វៈ ពុំមាន យើងអ្នកចូលរួមទេ ប៉ុន្តែដោយខ្វះការសិក្សា ក៏ប្រកាន់ថា មានគេយើង ដែលជាអំពើធ្វើផ្លូវដើរទៅរកជាតិ ជរា មរណៈ របស់ការអនុលោមទៅតាមបដិច្ចសមុប្បាទធម៌ ។ មនុស្ស គ្រប់គ្នាក្នុងលោក មានជាតិមកហើយ តែងប្រាថ្នាសេចក្តីសុខ ជាធម៌ នាំប្រយោជន៍មកឱ្យខ្លួន ពោល គឺ មិនចង់បានឱ្យមាន សេចក្តីទុក្ខ ទើបស្វែងរកអ្វីៗ មកជួយរំលែកនូវសភាពតានតឹង ក្នុងជីវភាព មានការសិក្សា រៀនសូត្រខាងមុខវិជ្ជាផ្លូវលោក

ទុកជាមធ្យោបាយ សម្រាប់ ដោះស្រាយ នូវការរកទ្រព្យ សម្បត្តិមកជួយផ្គត់ផ្គង់ជីវិតក្នុង គ្រួសារដល់សេចក្តីត្រូវការ ព្រោះគេយល់ថា នេះជាសុភមង្គល តែតាមពិតមិនមែន សិរីសួស្តីទាំងអស់ទេ គ្រាន់តែជាបច្ច័យ ឬឧបករណ៍ជួយបំពេញ សេចក្តីស្រេកឃ្លានមួយគ្រាៗ ប៉ុណ្ណោះ ។ ព្រោះហេតុដូច្នោះ បានជាមនុស្សជាតិលើសាកលលោក (ក្នុងជម្ពូទ្វីប) ខិតខំខ្នះខ្នែង ស្រាវជ្រាវរិះរកអ្វី ដែលជាទីពឹងពិតប្រាកដ ក្រៅពីទ្រព្យសម្បត្តិ រហូតដល់អ្នកខ្លះ ត្រូវបាត់បង់ជីវិត ដោយពុំទាន់បានទទួលដឹង នូវរសជាតិអ្វីនោះផង ។

មូលហេតុនាំឱ្យកើតមង្គលបញ្ហា

ក្នុងសម័យពុទ្ធកាលមនុស្សម្នាមហាជន នាំគ្នាជាពួកៗ គិតរកមង្គល សិរីសួស្តី តើអ្វីហ្ន៎ហៅថាមង្គល គឺសេចក្តីសុខចម្រើន ដែលមាននៅក្នុងអដ្ឋកថា ខុទ្ទកនិកាយ ខុទ្ទកបាឋៈលេខ ៣៥/ ១៦៣ ។ ពួកទេវតារក្សាមនុស្សលោកជ្រាបដឹងរឿង ពីពួក មនុស្សនោះហើយ ក៏ជ្រួលច្របល់ប្រជុំគ្នាគិតរកមង្គលដែរ ពួក ភូមិទេវតា ជាមិត្តរបស់ទេវតា ស្តាប់ដឹងរឿងពីអារក្ខទេវតា នាំគ្នាគិតរកមង្គលដូចគ្នា ចំណែកពួកអាកាសទេវតាជាមិត្តរបស់

ពួកភូមិទេវតា ពួកចាតុម្មហារាជិកាទេវតា ជាមិត្តនឹងអាកាសទេវតា ដោយឧបាយនេះ ដរាបដល់អកនិដ្ឋទេវតា ជាមិត្តរបស់សុទស្សីទេវតា ស្តាប់ដឹងរឿងពីសុទស្សីទេវតានោះហើយប្រកាន់ជាពួកៗ នាំគ្នាគិតរកមង្គលទាំងឡាយដែលបានកើតទូទៅផ្អើលគ្រប់ទីកន្លែងរហូតដល់ម៉ឺនចក្រវាល ។

ដំណើរនេះ ទោះបីនឹងវិនិច្ឆ័យថាយ៉ាងណាៗ មិនអាចដោះស្រាយបានដាច់ស្រេច ក៏តាំងនៅរហូតដល់ ១២ ឆ្នាំ ទាំងមនុស្សលោក ទាំងទេវតា ទាំងព្រហ្មផងគ្នា វ៉ៃវ៉ែព្រះអរិយសាវ័កពាពួក សូម្បីពួកណាមួយនឹងប្រាកដថាប៉ុណ្ណោះត្រូវឬ ប៉ុណ្ណោះត្រូវមិនបាន ដូច្នោះមង្គលកោលាហល (ការភ្ញាក់ផ្អើលរឿង មង្គល) កើតឡើងហើយក្នុងលោក ។

ឈ្មោះថា កោលាហលមាន ៥ គឺ កប្បកោលាហល១ ចក្កវិត្តិកោលាហល១ ពុទ្ធកោលាហល១ មង្គលកោលាហល១ មោនេយ្យកោលាហល១ ។ បណ្តាកោលាហលទាំង ៥ នេះ មានពួកទេវតាខ្លះ ដូចជា :

ពួកទេវតាថ្នាក់កាមាវចរ ប្រកបទង្គិចសិរសៈ រំសាយសក់ស្រែកយំយកដៃជូតទឹកភ្នែក ស្លៀកសំពត់ពណ៌ក្រហម ទ្រង់ភេទប្លែកៗ ត្រាច់ទៅក្នុងលំនៅមនុស្សលោក ស្រែកប្រាប់ថា

កន្លងទៅ ១ សែនឆ្នាំ កប្បប្រាកដលោកនេះ នឹងត្រូវវិនាស មហាសមុទ្ទ នឹង រឹងសូត មហាប្រឹថពី ស្តេចភ្នំសិនេរុ នឹងត្រូវ ភ្លើងឆេះ ហើយវិនាសរហូតដល់ព្រហ្មលោក ។ ម្នាលអ្នក និរទុក្ខ សូមអ្នកទាំងឡាយនាំគ្នាចម្រើនមេត្តា ចូរនាំគ្នាចម្រើនករុណា មុទិតា ឧបេក្ខាទុកចុះ អ្នកនិរទុក្ខ ចូរចំនុកបម្រុង មាតាបិតា ចូរកោតក្រែងអ្នកជាធំក្នុងត្រកូល ដាស់តឿន និងកុំប្រមាទគ្នា ឡើយ នេះឈ្មោះថា **កប្បកោលាហល** ។

ទេវតា ថ្នាក់កាមាវចរ ត្រាច់ទៅក្នុងលំនៅមនុស្សលោក ស្រែកប្រាប់ថា កន្លងទៅ ១ រយឆ្នាំ ស្តេចចក្រពត្តិនឹងកើតឡើង ក្នុងលោក នេះឈ្មោះថា **ចក្កវត្តិកោលាហល** ។

ចំណែកទេវតាថ្នាក់សុទ្ធាវាស ប្រដាប់អង្គដោយអាភរណព្រហ្ម ជូតក្បាលដោយសំពត់ព្រហ្ម មានព្រះកេសកើតបីតិបាមោជ្ជ ពោលព្រះពុទ្ធគុណ ត្រាច់ទៅក្នុងមនុស្សលោក ស្រែកប្រាប់ថា កន្លងទៅ ១000 ឆ្នាំ ព្រះពុទ្ធជាម្ចាស់ នឹងឧប្បត្តិឡើងក្នុងលោក នេះឈ្មោះថា **ពុទ្ធកោលាហល** ។

ពួកទេវតាថ្នាក់សុទ្ធាវាសនោះឯង ដឹងចិត្តរបស់ពួកមនុស្ស ត្រាច់ទៅក្នុងមនុស្សលោកបានស្រែកប្រាប់ថា កន្លងទៅ ១២ ឆ្នាំ

ព្រះសម្មាសម្ពុទ្ធជាម្ចាស់នឹងត្រាស់សម្តែងនូវមង្គល នេះ ឈ្មោះថា **មង្គលកោលាហល** ។

ពួកទេវតាថ្នាក់សុទ្ធាវាសនោះឯង ត្រាច់ទៅក្នុងមនុស្ស លោកស្រែកប្រាប់ថា កន្លងទៅ ៧ ឆ្នាំ ភិក្ខុមួយរូប សមាគម ជាមួយព្រះដ៏មានព្រះភាគជាម្ចាស់ នឹងទូលសួរមោនេយ្យបដិបទា នេះឈ្មោះថា **មោនេយ្យកោលាហល** ។ កោលាហលទាំង ៥ នេះ មង្គលកោលាហលរបស់ទេវតា និងមនុស្សទាំងឡាយ កើតឡើងហើយក្នុងលោក ។

គ្រានោះ ទេវតាថ្នាក់តាវត្តិង្ស គប់រកសមាគមជួយគ្នា បានទៅទូលសួរដល់សក្កទេវរាជ ជាអធិបតីរបស់ទេវលោក ទាំង ២ (ថ្នាក់ចាតុម្មហារាជិកា និងតាវត្តិង្ស) ថ្វាយបង្គំ កំពូលទេព ដែលមានព្រះសិរីៈដ៏មានសិរី ប្រកបដោយអាភរណ ប្រចាំព្រះអង្គយ៉ាងសមគួរដល់ខណៈនោះ ព្រមទាំងមានពួក ទេពអប្សរ ២៥០ កោដិ បែហមអម ទ្រង់ប្រថាប់នៅលើ បណ្ឌុកម្ពលសិលាអាសន៍ ខាងក្រោមដើមបារិច្ឆត្តកព្រឹក្ស ហើយ ឈរនៅទីដ៏ សមគួរ ១ កន្លែង ទូលថា សូមប្រទានព្រះវរោកាស ព្រះអង្គ អ្នកនិរទុក្ខ ប្រោសទ្រង់ជ្រាបចុះ ។ ឥឡូវនេះ មង្គល

បញ្ហាតាំងឡើងហើយ ដោយមានមនុស្សមួយពួកឈ្មោះ **ទិដ្ឋមង្គលិក:** ពោលថា រូបដែលបានឃើញ ជាមង្គល ពួកមួយទៀតឈ្មោះ **សុតមង្គលិក:** ពោលថា សំឡេងដែលបានឮ ជាមង្គល ពួកមួយខាងក្រោយនេះ ឈ្មោះ **មុតមង្គលិក:** ពោលថា របស់ដែលបានជ្រាប ជាមង្គល ។ ក្នុងបណ្តាអ្នកទាំង ៣ នោះ ពួកខ្ញុំព្រះបាទនឹងអ្នកដទៃ មិនទាន់ទទួលថា ត្រឹមត្រូវគួរ សាធុទេ សូមព្រះអង្គប្រោសព្យាករតាមសេចក្តីពិត ដល់ពួកខ្ញុំម្ចាស់ទាំងអស់គ្នា ។ សក្កទេវរាជ តាមប្រក្រតីទ្រង់មានបញ្ហា ទើបត្រាស់ថា រឿងមង្គលនេះ កើតចេញពីទីណាមុន គេទូលថា ពួកខ្ញុំម្ចាស់ស្តាប់ពាក្យរបស់ពួកទេវតាថ្នាក់ចាតុម្មហារាជ ពួកទេវតាចាតុម្មហារាជ ឮពីពួកអាកាសទេវតា។ ឮពាក្យពីពួកភូមិទេវតា។ ឮពាក្យពីទេវតារក្សាមនុស្សលោក ពួកទេវតាអ្នករក្សាមនុស្សលោកពោលថា រឿងមង្គលកើតឡើងពី**មនុស្សលោក** ។ យ៉ាងដូចនេះហើយ សក្កទេវរាជ ត្រាស់សួរដល់ពួកទេវតាថា ព្រះសម្មាសម្ពុទ្ធទ្រង់ប្រថាប់នៅឯណា ពួកទេវតាក្រាបទូលថា ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ប្រថាប់នៅក្នុងមនុស្សលោក ទើបព្រះសក្កទេវរាជមានទេវឱង្ការ ប្រើ

ទេវបុត្រមួយអង្គឱ្យទៅទូលសួរព្រះដ៏មានព្រះភាគជាម្ចាស់ ។ ដូច្នោះហើយទេវបុត្រនោះ បានតាក់តែងអង្គ ប្រកបដោយគ្រឿងអលង្ការដ៏សមគួរយ៉ាងរុងរឿង មានពួកទេពបៃហាមនាំគ្នាយាងចុះទៅកាន់វត្តជេតវ័ន មហាវិហារ ថ្វាយបង្គំ ព្រះដ៏-មានព្រះភាគ ហើយឈរនៅទីដ៏សមគួរមួយ ទូលសួរពីមង្គលបញ្ហាដល់ព្រះដ៏មានព្រះភាគ ដោយបានពោលគាថា **ពហូ ទេវា មនុស្សា ច** ជាដើម ។

មង្គលសូត្រ

(នៅក្នុង ខុទ្ទកនិកាយ សុត្តនិបាត បិដកលេខ ៥៤/៨៤)

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

លុះគ្រានោះឯង មានទេវតាមួយអង្គ កាលរាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនជុំវិញទាំងអស់ឱ្យភ្លឺស្វាង ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ បានក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចឈរនៅទីដ៏សមគួរ ។ លុះទេវតានោះឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគនូវគាថាយ៉ាងដូច្នេះ

ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ ។

ប្រែថា : ទេវតា និងមនុស្សទាំងឡាយយ៉ាងច្រើន ប្រាថ្នានូវសួស្តី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់សម្តែងនូវ មង្គលដ៏ឧត្តម ។

ព្រះមានព្រះភាគទ្រង់សម្តែងថា :-

អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា
បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ ។

ប្រែថា: ការមិនសេពគប់បុគ្គលពាលទាំងឡាយ ១ ការសេពគប់បណ្ឌិតទាំងឡាយ ១ ការបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ (ទាំង ៣) នេះ ជាមង្គលដ៏ឧត្តម។

បដិរូបទេសវាសោ ច បុព្វេ ច កតបុញ្ញតា
អត្តសម្មាបណិធិ ច ឯតម្មង្គលមុត្តមំ ។

ប្រែថា : ការនៅក្នុងប្រទេសដ៏សមគួរ ១ ភាពនៃបុគ្គលបានធ្វើបុណ្យទុកក្នុងកាលមុន ១ ការតម្កល់ខ្លួនដោយប្រពៃ ១ (ទាំង៣) នេះ ជាមង្គលដ៏ឧត្តម ។

ពាហុសច្ចៈ ១ សិល្បសាស្ត្រ ១ វិន័យ ដែលសិក្សាដោយប្រពៃ ១ វាចាដែលពោលត្រឹមត្រូវ ១ (ទាំង៤) នេះ ជាមង្គលដ៏ឧត្តម ។

ការបម្រើមាតា១ បម្រើបិតា ១ សេចក្តីសង្គ្រោះបុត្រ និងភរិយា១ ការងារទាំងឡាយមិនច្របូកច្របល់ ១ (ទាំង៤) នេះ ជាមង្គល ដ៏ឧត្តម ។

ទាន ១ ការប្រព្រឹត្តិធម៌ ១ ការសង្គ្រោះពួកញាតិ ១ ការងារមិនមានទោស ១ (ទាំង៤) នេះ ជាមង្គលដ៏ឧត្តម ។

ការមិនត្រេកអរក្នុងបាបនិងកិរិយាវៀរចាកបាប ១ សេចក្តីសង្រួមចាកកិរិយាធឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ (ទាំង៣) នេះ ជាមង្គលដ៏ឧត្តម ។

សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព ១ ការប្រព្រឹត្តិបន្ទាបខ្លួន ១ សេចក្តីត្រេកអរចំពោះរបស់ដែលមាន ១ ភាពនៃបុគ្គលអ្នកដឹងឧបការគុណ ដែលអ្នកដទៃបានធ្វើដល់ខ្លួន ១ ការស្តាប់ធម៌តាមកាល ១ (ទាំង៥) នេះ ជាមង្គលដ៏ឧត្តម ។

សេចក្តីអត់ធន់ ១ ភាពនៃបុគ្គលដែលប្រដៅងាយ ១ ការបានឃើញបានជួបសមណៈទាំងឡាយ ១ ធម្មសាកច្ឆាតាមកាល ១ (ទាំង៤) នេះ ជាមង្គលដ៏ឧត្តម ។

សេចក្តីព្យាយាមដុតបាបធម៌ ១ ការប្រព្រឹត្តិនូវធម៌ដ៏ប្រសើរ ១ ការឃើញនូវអរិយសច្ចធម៌ទាំងឡាយ ១ ការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ១ (ទាំង៤) នេះ ជាមង្គលដ៏ឧត្តម ។

ចិត្តនៃបុគ្គលណា ដែលលោកធម៌ពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្តីសោក ១ មានធូលី គឺរាគៈទៅប្រាសហើយ ១ ចិត្តក្សេមក្សាន្ត ១ (ទាំង៤) នេះ ជាមង្គលដ៏ឧត្តម ។

ទេវតា និងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសួស្តីក្នុងទីទាំងពួង (ម្នាលទេវតា អ្នកចូរប្រកាន់ជឿថា) មង្គលទាំង

៣៨ ប្រការ មានការមិនសេពគប់បុគ្គលពាលជាដើម របស់ទេវតា និងមនុស្សទាំងអម្បាលណោះ ជាមង្គលដ៏ឧត្តម ។

អដ្ឋកថា

(ខុទ្ទកបាឋៈ លេខ ៣៩/១៦៨)

ពណ៌នាគាថា **៣ហ្វូ ទេវា**

ពាក្យថា **៣ហ្វូ** សម្តែងចំនួនមិនជាក់លាក់ដោយហេតុនោះ ទើបអធិប្បាយថា ច្រើនរយ ច្រើនពាន់ ច្រើនសែន។ ឈ្មោះថា **ទេវៈ** ព្រោះលេង អធិប្បាយថា លេងជាមួយកាមគុណ ៥ ឬ រុងរឿងដោយសិរីរបស់ខ្លួន ។ ម្យ៉ាងទៀត បទថា **ទេវា** បានដល់ ទេពទាំង ៣ គឺ សម្មតិទេព ឧប្បត្តិទេព និងវិសុទ្ធិទេព ដូចយ៉ាង ដែលលោកពោលទុកថា :

បទថា **ទេវា** បានដល់ ទេព ៣ គឺ សម្មតិទេព ឧប្បត្តិទេព និងវិសុទ្ធិទេព ។ បណ្តាទេពទាំង ៣ នោះ ព្រះរាជា ព្រះរាជទេវី ព្រះរាជកុមារ ឈ្មោះថា **សម្មតិទេព** ។ **ទេព** ចាប់តាំងពីថ្នាក់ ចាតុម្មហារាជិកា និងថ្នាក់ខ្ពស់ជាងនេះទៅ ឈ្មោះថា **ឧប្បត្តិទេព** ចំណែកព្រះអរហន្ត ឈ្មោះថា វិសុទ្ធិទេព ។

ពួកទេពទាំង ៣ ក្នុងសូត្រនេះ លោកប្រាថ្នាយក ឧប្បត្តិ-ទេព ។ ឈ្មោះថាមនុស្ស ព្រោះជាអ្នកមានចិត្តខ្ពង់ខ្ពស់ ។ មនុស្ស មាន ៤ ពួក គឺ ប្រជាជនជម្ពូទ្វីប ប្រជាជនអបរគោយានិទ្វីប ប្រជាជនឧត្តរកុរុទ្វីប និងប្រជាជនបុព្វវិទេហទ្វីប ក្នុងសូត្រ នេះ លោកកាន់យកប្រជាជនក្នុងជម្ពូទ្វីប ។ ឈ្មោះថា **មង្គល** ព្រោះសត្វចម្រើនរុងរឿងដោយគុណ អធិប្បាយថា សត្វ មាន សេចក្តីសម្រេច និងចម្រើន ។ បទថា **អចិន្តយុំ** ប្រែថា គិតគ្នា ហើយ ។ បទថា **អាគន្ត្វមានា** បានដល់ គោលបំណងប៉ង ប្រាថ្នា សង្ឃឹម ។ បទថា **សោត្ថានំ** ប្រែថា : សូស្តី អធិប្បាយ ថា ធម៌ទាំងឡាយប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងចំណែកខាងមុខ គ្រប់យ៉ាង ។ បទថា **ព្រូហិ** បានដល់ សម្តែង ប្រកាស ប្រាប់ ផ្សាយ ចែក ធ្វើឱ្យងាយ ។ បទថា **មង្គលំ** បានដល់ ហេតុនៃ សេចក្តីសម្រេច សេចក្តីចម្រើន ហេតុនៃសម្បត្តិគ្រប់យ៉ាង ។ បទថា **ឧត្តមំ** បានដល់ វិសេស ប្រសើរ នាំប្រយោជន៍សុខមក ឱ្យលោកទាំងពួងដូចពោលមកនេះ ដែលជាការពណ៌នា តាម លំដាប់បទនៃគាថាទាំងឡាយ ។

រួមសេចក្តីថា ទេវបុត្រទាំងនោះ ឃើញពួកទេវតាមួយ ម៉ឺនចក្កវាឡជុំនុំគ្នាក្នុងចក្កវាឡនេះ ដើម្បីប្រាថ្នានឹងស្តាប់នូវ មង្គលបញ្ហា ក៏នាំគ្នានិមិត្តអត្តភាពយ៉ាងតូចល្អិតបំផុតស្មើ ១០ ចុងរោមទ្រាយខ្លះ ២០ ខ្លះ ៣០ ខ្លះ ៤០ ខ្លះ ៥០ ខ្លះ ៦០ ខ្លះ ៧០ ខ្លះ ៨០ ខ្លះ ឈរចោមរោមព្រះដ៏មានព្រះភាគជាម្ចាស់ ដែលទ្រង់ ប្រថាប់នៅលើពុទ្ធអាសនដ៏ប្រសើរ ទ្រង់បញ្ចេញ ព្រះរស្មីគ្របសង្កត់លើទេវតាមារព្រហ្មទាំងអស់ ដោយព្រះសិរី និងព្រះតេជះ ហើយទ្រង់ព្រះបរិវិតក្កៈដឹងចិត្តពួកមនុស្សក្នុង ជម្ពូទ្វីប ដែលមិនបានមកប្រជុំក្នុងសម័យនោះ ទើបពោលគាថា ដើម្បីដកកូនសរ គឺសេចក្តីសង្ស័យ របស់ទេវតា និងមនុស្សទាំង ពួងថា :-

ទេវតានិងមនុស្សជាច្រើនប្រាថ្នា សិរីសួស្តី បាននាំគ្នា គិត រកនូវមង្គលទាំងឡាយ សូមព្រះអង្គប្រោសត្រាស់ប្រាប់នូវមង្គល ដោយអនុគ្រោះ ។

បពិត្រព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះអង្គជាអ្នកដែលខ្ញុំ ព្រះអង្គទូលសួរហើយ តាមអនុមតិរបស់ទេវតាទាំងនោះ នឹង អនុគ្រោះមនុស្សទាំងឡាយ មង្គលណាជាឧត្តមខ្ពស់បំផុត ព្រោះនាំមកនូវប្រយោជន៍សុខដល់ខ្ញុំព្រះអង្គទាំងអស់គ្នា អាស្រ័យ

ព្រះករុណាគុណ សូមប្រោសត្រាស់ប្រាប់មង្គលនោះដល់ខ្ញុំព្រះអង្គ ទាំងឡាយ ។

ពណ៌នាគាថាទី ១ ថា អសេវនា ច

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានស្តាប់ពាក្យរបស់ទេវបុត្រយ៉ាងនេះហើយ ទើបត្រាស់ព្រះគាថា អសេវនា ច ពាលានំ ជាដើម ។ ក្នុងព្រះគាថានេះ បទថា អសេវនា បានដល់ការមិនសេពគប់ មិនចូលទៅជិតតែមិនឈ្មោះថា សួរប់ខ្ចីមឡើយ ។

បទថា **ពាលានំ** សេចក្តីថា ឈ្មោះថា ពាល ព្រោះជាអ្នករស់នៅ បានត្រឹមតែដកដង្ហើមចេញចូល អធិប្បាយថា មិនជាអ្នករស់នៅប្រកបដោយ បញ្ញា ។

បទថា **បណ្ឌិតានំ** សេចក្តីថា ឈ្មោះថា បណ្ឌិត ព្រោះដំណើរទៅ អធិប្បាយថា ដំណើរទៅដោយគតិ គឺ ដឹងក្នុងប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍ខាងមុខ (សម្បរាយភព) ។

បទថា **សេវនា** បានដល់ ការសេពគប់ ការចូលទៅជិត ការមានបណ្ឌិតជាមិត្ត ជាមិត្តភក្តិ សេចក្តីព្រមព្រៀងដោយបណ្ឌិតនោះ។

បទថា **បូជា** បានដល់ ការធ្វើសក្ការៈ គោរពរាប់រក ការសំពះ ។

បទថា **បូជនីយានំ** ប្រែថា អ្នកគួរដល់ដោយការបូជា ។

បទថា **ឯតម្មង្គលមុត្តមំ** សេចក្តីថា ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ប្រមូលការមិនគប់ពាល ១ ការគប់បណ្ឌិត ១ ការបូជាអ្នកដែលគួរបូជា ១ ទាំង ៣ នេះ ទ្រង់ត្រាស់ថា **ឯតម្មង្គលមុត្តមំ** លោកអធិប្បាយថា ពាក្យណាលោកសួរថា សូមប្រោសត្រាស់ប្រាប់មង្គលដ៏ឧត្តម ដោយអនុគ្រោះ លោកចូរប្រកាន់ពាក្យនេះថា មង្គលដ៏ឧត្តមក្នុងសេចក្តីនោះមុន នេះជាការពណ៌នាបទនៃគាថា។

ចំណែកការពណ៌នាសេចក្តីនៃបទ គប្បីជ្រាបយ៉ាងដូច្នេះ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ស្តាប់ពាក្យរបស់ទេវបុត្រនោះហើយ ទើបទ្រង់ត្រាស់ព្រះគាថានេះថា **អសេវនា ច ពាលានំ** ជាដើម ។

ក្នុងសេចក្តីនេះមាន ៤ គាថា គឺ បុច្ឆិតគាថា អបុច្ឆិតគាថា សានុសន្ធិកគាថា អនន្តរសន្ធិកគាថា ។ បណ្តាគាថាទាំង ៤ នោះ គាថាដែលត្រូវសួរ ឈ្មោះថា **បុច្ឆិកគាថា** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **បុច្ឆាមិ តំ គោតម ភូរិបញ្ញា កថំករោ វិសាខកោសាធុ ហោតិ** ប្រែថា: ព្រះគោតម អ្នកមាន បញ្ញាទូលំទូលាយ ដូចផែនដី ខ្ញុំម្ចាស់សូមសួរថា តើសាវ័កធ្វើយ៉ាងណា បានជាមនុស្សល្អ និងប្រយោគថា **កថំ នុ ក្វំ មារិស ឱយមត្រិ** ប្រែថា: អ្នកនិរទុក្ខ ព្រះអង្គឆ្លងឱឃៈយ៉ាងណា ។

គាថាដែលព្រះអង្គមិនត្រូវសួរ តែទ្រង់ត្រាស់តាមព្រះអធ្យាស្រ័យរបស់ព្រះអង្គឯង ឈ្មោះថា អបុច្ឆិតគាថា បានក្នុងប្រយោគយ៉ាងនេះថា **យំ បរេ សុខតោ អាហុតទ្វិយា អាហុ ទុក្ខតោ** ប្រែថា: អ្នកដទៃៗ ពោលនូវរបស់ណាថាជាសុខ ព្រះអរិយទាំងឡាយពោលនូវរបស់នោះថា ជាទុក្ខ ។ គាថា របស់ព្រះពុទ្ធទាំងឡាយ សូម្បីទាំងអស់ ឈ្មោះថា សានុសន្ធិកគាថា ព្រោះ បាលីថា **សនិទានាហំ ភិក្ខវេ ធម្មំ ទេសេស្សាមិ** ប្រែថា: ម្នាលភិក្ខុទាំងឡាយយើងនឹងសម្តែង

ធម៌មាននិទាន គឺ ហេតុយ៉ាងដូច្នេះ ។ ដែលឈ្មោះថា អនសុសន្ធិក-គាថា គឺគាថា មិនមានហេតុ មិនមានក្នុងព្រះសាសនានេះ ក៏បណ្តាគាថាដូចពោលមកនេះ ឈ្មោះថា បុច្ឆិតគាថា ព្រោះជាគាថាដែលព្រះដ៏មានព្រះភាគត្រូវទេវបុត្រទូលសួរ ទើបទ្រង់ត្រាស់ឆ្លើយ ។ គាថានេះ ប្រាប់អ្នកដែលមិនគួរសេពគប់ ក្នុងអ្នកដែលគួរគប់ និងមិនគួរសេពគប់ ហើយប្រាប់អ្នកដែលគួរគប់ ប្រៀបដូចបុរសឆ្លាតដឹងផ្លូវ និងដឹងទាំងមិនមែនផ្លូវត្រូវសួរកផ្លូវ ទើបប្រាប់ផ្លូវដែលគួរវៀរ ក្រោយមកប្រាប់ផ្លូវត្រង់ដែលគួរប្រកាន់ទុក ក្នុងទីមានផ្លូវបែកជាពីរ ។ ផ្លូវបែកជាពីរនោះ ចូរវៀរផ្លូវខាងឆ្វេងចេញ កាន់យកផ្លូវខាងស្តាំ ក៏ព្រះដ៏មានព្រះភាគជាម្ចាស់ប្រៀបដូចបុរសអ្នកឆ្លាតក្នុងផ្លូវ ដែលទ្រង់ត្រាស់ទុកថា :-

ម្ហាលតិស្សៈ ពាក្យថា បុរសអ្នកឆ្លាតក្នុងផ្លូវ នេះជាឈ្មោះរបស់តថាគតអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ តថាគត ឆ្លាតដឹងលោកនេះ ឆ្លាតដឹងលោកដទៃ ឆ្លាតដឹងតំបន់មច្ចុ ឆ្លាតដឹងទាំងមិនមែនកន្លែងមច្ចុ ឆ្លាតដឹងអន្ទាក់មារ ឆ្លាតដឹងទាំងមិនមែនកម្រងនៃមារ ។

ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ពេលត្រាស់ប្រាប់ដល់បុគ្គលដែលមិនគួរសេពគប់ជាមុន ទើបត្រាស់ថា ការមិនសេពគប់ពាល ត្រូវសេពគប់បណ្ឌិត។ ការពិតមនុស្សពាលទាំងឡាយ មិនគួរគប់ មិនគួរចូលទៅជិតដូចផ្លូវដែលគួរវៀរ ប៉ុន្តែគួរគប់ គួរចូលទៅជិតបណ្ឌិតវិញ ប្រៀបដូចផ្លូវដែលគួរប្រកាន់ទុក ។ អ្នកជំទាស់ ពោលថា ព្រោះហេតុអ្វីបានជាព្រះដ៏មានព្រះភាគជាម្ចាស់ ពេលត្រាស់មង្គល ទើបត្រាស់ការមិនគប់ពាល ឱ្យគប់បណ្ឌិតជាមុនទៅវិញ ព្រោះពួកទេវតានិងមនុស្ស ប្រកាន់ការឃើញថា ជាមង្គលក្នុងរបស់ដែលឃើញ ហើយជាដើម ដោយគួរដល់ការសេពគប់ទាំងការគប់ពាលនោះមិនមែនជាមង្គល ដូច្នោះព្រះដ៏មានព្រះភាគ ពេលនឹងទ្រង់ទិត្បែនការសមាគមគ្នា ជាមួយអ្នកដែលមិនមែនជាកល្យាណមិត្ត ព្រោះនាំឱ្យខូចប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ ហើយទ្រង់សរសើរការសមាគម ជាមួយកល្យាណមិត្ត ដែលធ្វើឱ្យសម្រេចប្រយោជន៍ដល់លោកទាំងពីរ ទើបទ្រង់ត្រាស់ ការមិនសេពគប់ពាលឱ្យសេពគប់តែបណ្ឌិតជាមុនដល់ពួកទេវតា និងមនុស្សទាំងនោះ ។

សត្វទាំងឡាយគ្រប់គ្នា ប្រកបដោយអកុសលកម្មបថ មានបាណាតិបាត (សម្លាប់សត្វ) ជាដើមឈ្មោះថា ពាល។ ក្នុងចំនួនពាលនិងបណ្ឌិត ពួកពាលនឹងអាចដឹងបាន ដោយអាការទាំងឡាយ ដូចយ៉ាងដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ទុកក្នុងព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយ លក្ខណៈរបស់ពាល មាន ៣ ប្រការប៉ុណ្ណោះ ដូចបានជម្រាបពីខាងដើមរួចមកហើយ។ ម្យ៉ាងទៀត គ្រូទាំង ៦ មាន បូរណកស្សបៈ ជាដើម និងសត្វដទៃៗទៀត ដូចយ៉ាង ទេវទត្ត កោកាលិកៈ កដមោទកៈ តិស្សខណ្ឌទេវីបុត្រ សមុទ្ទទត្តៈ នាងចិញ្ចាមាណវិកា ជាដើម និងបងប្រុសរបស់ទីឃវិទៈ ពីអតីត គប្បីជ្រាបថា ពាល ។

ពាលនោះឯង រមែងញុំាងខ្លួនឯង និងពួកអ្នកដែលធ្វើតាមពាក្យរបស់ខ្លួនឱ្យវិនាសដោយទិដ្ឋគតៈ ការឃើញដែលខ្លួនប្រកាន់ទុកមិនល្អ ដូចផ្ទះដែលត្រូវភ្លើងឆេះ ដូចបងប្រុសរបស់ទីឃវិទៈដួលដេកផ្ងារ ដោយអត្តភាពប្រមាណ ៦០ យោជន៍ ឆេះនៅក្នុងមហានរកប្រមាណដល់ ៤ ពុទ្ធន្តរ និង ៥០០ ត្រកូល ដែលពេញចិត្ត នឹងទិដ្ឋិរបស់ទីឃវិទៈនោះ ព្រោះរស់នៅរួមជាមិត្តរបស់បងប្រុសទីឃវិទៈ ក៏ឆេះនៅក្នុងមហានរក ដូច្នោះឯង សមពិតដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ទុកថាៈ-

ម្នាលភិក្ខុទាំងឡាយ ភ្លើងឆេះចេញពីផ្ទះឈើ ឬផ្ទះស្លឹក រមែងឆេះដល់កំពូល ហើយឆាបឆេះពីខាងក្នុង និងខាងក្រៅ ប្រៀបបានយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភ័យគ្រប់យ៉ាងរមែងកើតយ៉ាងនោះដូចគ្នា ភ័យទាំងអស់កើតចេញពីពាល មិនកើតពីបណ្ឌិត ។ ឧបទ្ទវៈគ្រប់យ៉ាងរមែងកើត ។ល។ ឧបសគ្គគ្រប់យ៉ាងរមែងកើត ។ល។ មិនកើតចេញពីបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ ដូច្នោះ ពាលជាភ័យ បណ្ឌិតមិនជាភ័យ ពាលជាឧបទ្ទវៈ បណ្ឌិតមិនជា ឧបទ្ទវៈ ពាលជាឧបសគ្គ បណ្ឌិតមិនជាឧបសគ្គយ៉ាងដូច្នោះ ។

ម្យ៉ាងទៀត ពាលប្រៀបដូចត្រីស្អុយ កាលបើអ្នកសេពគប់ពាលក៏ដូចកញ្ចប់ស្លឹកឈើដែលខ្ចប់រុំចត្រីស្អុយ រមែងជួបប្រទះនូវភាវៈដែលវិញ្ញូជនលះបង់ ហើយស្អប់ខ្ពើមមិនចូលចិត្ត សមដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា:-

បូតិមច្ឆំ កុសគ្គេន យោ នរោ ឧបនយ្ហតិ

កុសាបិ បូតិ ភាយន្តិ ឯវំ ពាលូបសេវនា ។

ប្រែថា : នរជនណា ចងត្រីស្អុយ ដោយចុងស្មៅ សូម្បីស្មៅរបស់នរជននោះ ក៏មានក្លិនស្អុយជាប់តាមដែរ ការសេពគប់ពាល

ក៏យ៉ាងដូច្នោះឯង។ ម្យ៉ាងទៀតពេលសក្កទេវរាជទ្រង់ប្រទានពរដល់មនុស្សអកិត្តិបណ្ឌិត បានពោលយ៉ាងនេះថា :

ពាលំ ន បស្សេ ន សុណេ ន ច ពាលេន សំវសេ

ពាលេនល្លាបសល្លាបំ នករេ ន ច រោចយេ។

ប្រែថា : មិនគួរជួបពាល មិនគួរស្តាប់ពាល មិនគួរនៅរួមជាមួយពាល មិនគប្បីធ្វើការចរចាប្រាស្រ័យជាមួយពាល និងមិនគួរចូលចិត្តពាល ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ពេលទ្រង់ទិតៀនការគប់ពាលដោយអាការទាំងពួងយ៉ាងនេះហើយ ទើបត្រាស់ថា ការមិនគប់ពាលជា **មង្គល** ឥឡូវនេះទ្រង់សរសើរការគប់បណ្ឌិត ទើបត្រាស់ថា ការគប់បណ្ឌិតជា **មង្គល**។

សត្វគ្រប់គ្នា ត្រូវប្រកបដោយកុសលកម្មបថ ១០ មានចេតនា វៀរចាកបាណាតិបាត (វៀរសម្លាប់សត្វ) ជាដើម ឈ្មោះថា បណ្ឌិតក្នុងជំពូកពាលនិងបណ្ឌិតនោះ ។

បណ្ឌិតទាំងនោះនឹងគប្បីដឹងបានដោយអាការ ៣ យ៉ាង ដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកក្នុងព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយ លក្ខណៈរបស់បណ្ឌិតមាន ៣ យ៉ាងប៉ុណ្ណោះ ។

ម្យ៉ាងទៀត ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ ព្រះអសីតិមហាសាវក ព្រះសាវ័កដទៃរបស់ព្រះតថាគត និង បណ្ឌិត មាន សុនេត្តសាស្តា មហាគោវិន្ទសាស្តា ព្រះវិធូរបណ្ឌិត សរភង្គតាបស ព្រះមហោសថ សុតសោមបណ្ឌិត ព្រះបាទ និមិរាជ អយោឃរកុមារ និងអភិត្តិបណ្ឌិតជាដើម គប្បីជ្រាប ថា ជាបណ្ឌិត។ បណ្ឌិតទាំងនោះ អាចកម្ចាត់ភ័យឧបទ្ទវៈ និងឧបសគ្គគ្រប់យ៉ាង ដល់អ្នកដែលធ្វើតាមពាក្យរបស់ខ្លួន អាច ជួយការពារក្នុងពេលមានភ័យ ប្រៀបដូចដួងប្រទីបក្នុងរវៅ ងងឹត ឬប្រៀបបាននឹង បបរជាដើម ក្នុងពេលមានទុក្ខ គឺសេចក្តី ស្រេកឃ្លានគ្របសង្កត់។ ពិតប្រាកដហើយ ព្រោះអាស្រ័យ ព្រះតថាគត ពួកទេវតា និងមនុស្សរាប់មិនបាន ប្រមាណមិន កើត បានសម្រេចគុណធម៌ជាទី អស់អាសវៈ បិតនៅក្នុង ព្រហ្មលោក ទាំងនៅក្នុងទេវលោក កើតក្នុងសុគតិលោក ៨ ម៉ឺនត្រកូល ធ្វើចិត្តឱ្យជ្រះថ្លាក្នុងព្រះ សារីបុត្តត្ថេរៈ ហើយទំនុក បម្រុងព្រះថេរៈដោយបច្ច័យ ៤ ក៏ទៅកើតក្នុងឋានសួគ៌ ។ ត្រកូលទាំងឡាយ ធ្វើចិត្តឱ្យជ្រះថ្លាក្នុងព្រះ មហាសាវក ទាំងពួង រាប់តាំងពីព្រះមហាមោគ្គល្លាន ព្រះមហាកស្សបជាដើមទៅ ក៏យ៉ាងនោះដូចគ្នា ។ សាវ័កទាំងឡាយរបស់សុនេត្តសាស្តា

ពួកខ្លះបានកើតក្នុងព្រហ្មលោក ពួកខ្លះជាមិត្ត របស់ពួកទេព ថ្នាក់បរនិម្មិតវសវត្តី ។ ល។ ពួកខ្លះជាមិត្តរបស់គហបតី មហាសាលយ៉ាងនេះឯង ព្រះដ៏មានព្រះភាគបានត្រាស់ទុក ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មិនមានភ័យពីបណ្ឌិត មិនមាន ឧបទ្ទវៈពីបណ្ឌិត និងមិនមានឧបសគ្គពីបណ្ឌិត។

ម្យ៉ាងទៀតបណ្ឌិតដូចរបស់ក្រអូប មានក្លិនក្រស្នា និងផ្កា ជាដើម អ្នកសេពគប់នឹងបណ្ឌិតដូចខ្ចប់គ្រឿងក្រអូបមានក្រស្នា និងផ្កា ញុំាងឱ្យបានជួបប្រទះនូវភាវៈដែលវិញ្ញូជនសរសើរ និង ពេញចិត្ត សូម្បីព្រះដ៏មានព្រះភាគក៏បានត្រាស់ទុកថា :-

តគរញ្ច បលាសេន យោ នរោ ឧបនយ្ហតិ

បត្តាបី សុរភី ទាយន្តិ ឯទំ ធីរូបសេវនា។

ប្រែថា : នរជនណាវេចខ្ចប់ក្រស្នាទុកដោយស្លឹកឈើ សូម្បីស្លឹកឈើរបស់នរជននោះ ក៏ជាប់ក្លិនក្រអូបដែរ ឯការ សេពគប់បណ្ឌិតក៏យ៉ាងនោះដូចគ្នា ។

មួយទៀត ពេលសក្កកំពូលទេពប្រទានពរដល់ អភិត្តិបណ្ឌិត ក៏ពោលថា :

ធីរំ បស្ស សុណេ ធីរំ ធីរេន សហ សំវរេ

ធីរេនល្ហាបសល្លាបំ កំ ករេ តញ្ញ រោចយេ ។

ប្រែថា : គួរសេពគប់បណ្ឌិត គួរស្តាប់បណ្ឌិត គួរនៅរួមជាមួយបណ្ឌិត គួរធ្វើការសន្ទនា ប្រាស្រ័យជាមួយបណ្ឌិត និងគួរពេញចិត្តបណ្ឌិត ។

អកិត្តិបណ្ឌិត ឆ្លើយថា :

ឧយំ ឧយតិ មេធាវី អធុរាយំ ឧ យុញ្ជតិ

សុនយោ សេយ្យសោ ហោតិ សម្ភា ខុត្តោ ឧ កុប្បតិ

ឥនយំ សោ បជានាតិ សាធុ តេន សមាគមោ ។

ប្រែថា : បណ្ឌិតរមែងណែនាំរឿងដែលគួរណែនាំ មិនទាញអ្នកទៅក្នុងកិច្ចមិនមែនធុរៈ ណែនាំឱ្យល្អ ពោលដោយល្អ មិនក្រោធ បណ្ឌិតនោះដឹងវិន័យ សមាគមជាមួយបណ្ឌិតជាការល្អប្រពៃ ។

ព្រះដ៏មានព្រះភាគ ពេលទ្រង់សរសើរការគប់បណ្ឌិតដោយធម៌ទាំងពួងយ៉ាងនេះហើយ ទើបទ្រង់ត្រាស់ថា ការសេពគប់បណ្ឌិតជាមង្គល ។ ឥឡូវនេះ ទ្រង់សរសើរការបូជាបុគ្គលដែលគួរបូជាដោយលំដាប់ ព្រោះការមិនគប់ពាល និងគប់បណ្ឌិតនោះហើយទើបទ្រង់ត្រាស់ថា **បូជា ច បូជនីយានំ**

មង្គលំ ប្រែថា : ការបូជា អ្នកដែលគួរបូជា នេះជាមង្គល ។ ព្រះដ៏មានព្រះភាគជាម្ចាស់ឈ្មោះថា **បូជនេយ្យៈ** ព្រោះទ្រង់វៀរចាក ទោសគ្រប់យ៉ាង និងប្រកបដោយគុណគ្រប់យ៉ាង ក្រៅពីនោះ មានព្រះបច្ចេកពុទ្ធជាម្ចាស់ ព្រះអរិយសាវ័ក ទាំងឡាយ ឈ្មោះថា **បូជនេយ្យៈ** ។ ការពិត ការបូជា បូជនេយ្យ-បុគ្គលទាំងនោះ សូម្បីតិចក្តីក៏ជាប្រយោជន៍សុខរហូតកាលយូរ ។ ក្នុងសេចក្តីនេះ មានរឿងនាយសុមនមាលាការនិងនាងមល្លិកាជាដើម សូមលើកយកតែរឿង ១ មកជាតួយ៉ាងក្នុង ២ រឿងនោះ ។

សេចក្តីថា ព្រឹកថ្ងៃមួយ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់អន្តរវាសក ហើយទ្រង់កាន់យកបាត្រនិងចីវរ ស្តេចយាងចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ខណៈនោះ នាយក្រងផ្កា ឈ្មោះសុមនមាលាការ កំពុងដើរកាន់ផ្កាសម្រាប់ ព្រះបាទពិម្ពិសារ បានឃើញព្រះដ៏មានព្រះភាគជាម្ចាស់ ស្តេចយាងមកដល់មាត់ទ្វារក្រុង ប្រកបដោយសម្រស់ស្រស់ថ្លា គួរឱ្យជ្រះថ្លាដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ និងព្រះអនុព្យញ្ជនៈ ៨០ ប្រការ រុងរឿងដោយព្រះពុទ្ធសិរី ។ លុះឃើញហើយក៏គិតថា ព្រះរាជា

ទ្រង់ទទួលផ្កាពីយើងហើយនឹងប្រទានទ្រព្យ ១០០ ឬ ១០០០ ក៏មិន ជាសេចក្តីសុខត្រឹមលោកនេះប៉ុណ្ណោះ ប៉ុន្តែការបូជាព្រះដ៏មានព្រះភាគជាម្ចាស់ រមែងមានផលប្រមាណមិនបាន រាប់មិនអស់ នាំប្រយោជន៍សុខមកឱ្យអស់កាលយូរ ។ ល្អើយចុះ យើងសុខចិត្ត បូជាផ្កាទាំងនេះដល់ព្រះដ៏មានព្រះភាគជាម្ចាស់វិញ ។ ដោយសេចក្តីជ្រះថ្លាយ៉ាងដូច្នេះហើយ គេបានចាប់ផ្កាមួយក្តាប់បាចទៅចំពោះ ព្រះភក្ត្ររបស់ព្រះដ៏មានព្រះភាគពីចម្ងាយ ផ្កាទាំងនោះហើរក្នុងអាកាស ទៅប្រតិស្ថានជាពិតានផ្កានៅចំពីលើព្រះដ៏មានព្រះភាគជាម្ចាស់ ។ ចំណែកនាយមាលាការឃើញនូវអានុភាពនោះហើយ ក៏រីងរឹតតែជ្រះថ្លាក្រៃលែងឡើង ក៏ចាប់បាចផ្កាមួយក្តាប់ ជាលើកទី២ ផ្កាទាំងនោះបានទៅប្រតិស្ថានធ្វើជាក្រោះ យ៉ាងនោះហើយនាយមាលាការចាប់បាចផ្កាថែម ៨ ក្តាប់ជាចុងក្រោយ ផ្កានោះទៅប្រតិស្ថាន កើតជាផ្ទះ មានដំបូលជាផ្កាវិញម្តង ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ប្រថាប់នៅក្នុងផ្ទះនោះ មហាជនជំនុំគ្នា ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ទតព្រះនេត្រឃើញនាយមាលាការ ទ្រង់មានការញញឹម ឃើញដូច្នោះ ព្រះអានន្តត្ថេទូលសួរដល់ហេតុដែលទ្រង់ញញឹមនោះ ដោយគិតថា

ព្រះពុទ្ធជាម្ចាស់ទាំងឡាយ មិនមានហេតុ មិនមានបច្ច័យ ក៏មិនទ្រង់ញញឹមដែរ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា អានន្ទ នាយមាលាការនោះ នឹងអន្តោលទៅក្នុង ទេវតា និង មនុស្ស ១ សែនកប្ប ដោយអានុភាពរបស់ការបូជា ទីបំផុតនឹង បានជាព្រះបច្ចេកពុទ្ធព្រះនាមថា សុមនិស្សរៈ ហើយក៏បានត្រាស់ ព្រះគាថាទុក ដើម្បីទ្រង់សម្តែងធម៌ថា :-

កញ្ញ កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ ។

ប្រែថា : បុគ្គលធ្វើកម្មណាហើយ មិនក្តៅក្រហាយជា ខាងក្រោយ បុគ្គលមានចិត្តល្អ ជ្រាបពេញសព្វហើយ សោយផល របស់កម្មណា កម្មនោះធ្វើល្អរួចហើយ ។

លុះចប់ព្រះគាថា ពួកសត្វ ៨៤.000 បានសម្រេចធម៌ ព្រោះការបូជា ដល់បូជនេយ្យបុគ្គលទាំងនោះ សូម្បីតិចក្តីគប្បី ជ្រាបថា មានប្រយោជន៍សុខអស់កាលយូរ ដោយប្រការ យ៉ាងដូច្នេះ ។ ការបូជានោះត្រឹមតែអាមិសបូជា នឹងពោលទៅ យ៉ាងណា ក្នុងបដិបត្តិបូជា ព្រោះកុលបុត្រណាបូជាចំពោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ដោយការទទួលសរណាគមន៍

និងសិក្ខាបទ មានការសមាទាន អង្គឧបោសថ និងដោយគុណទាំងឡាយរបស់ខ្លួន ដូចជា ចតុប្បារិសុទ្ធិសីល ជាដើម អ្នកណានឹងពណ៌នា នូវផលនៃការបូជារបស់បុគ្គលទាំងនោះបានដោយថា កុលបុត្រទាំងនោះ លោកពោលថា បូជាចំពោះព្រះតថាគតដ៏កំពូល ដូចយ៉ាងដែលព្រះដ៏មានទ្រង់ត្រាស់ទុកថា:-

ម្នាលអានន្ទ អ្នកណា មិនថា ជាភិក្ខុ ភិក្ខុនី ឧបាសក ឬ ឧបាសិកា ជាអ្នកបដិបត្តិធម៌សមគួរដល់ធម៌ បដិបត្តិយ៉ាងប្រពៃក្រៃលែង ប្រព្រឹត្តតាមធម៌ អ្នកនោះឈ្មោះថា សក្ការៈ គោរពរាប់អានបូជាកោតក្រែង គោរពប្រតិបត្តិដោយការបូជាយ៉ាងកំពូល សូម្បីការបូជាព្រះបច្ចេកពុទ្ធជាម្ចាស់ ឬ ព្រះអរិយសាវ័កទាំងឡាយ តែងនាំមកនូវប្រយោជន៍សុខ គប្បីជ្រាបតាម គន្លងនេះចុះ ។

ម្យ៉ាងទៀតសម្រាប់គ្រហស្ថ គប្បីជ្រាបនូវបូជនេយ្យបុគ្គលក្នុងសេចក្តីថា អ្នកចម្រើនរាប់តាំងពីបងប្រុស បងស្រី ឈ្មោះថា បូជនេយ្យបុគ្គលរបស់ប្អូន មាតាបិតា ជា បូជនេយ្យបុគ្គលរបស់បុត្រ ស្វាមី ឪពុកក្មេក ម្តាយក្មេក ជាបូជនេយ្យបុគ្គល របស់ត្រកូលស្ត្រីទាំងឡាយ ដោយថា ការបូជាបូជនេយ្យបុគ្គលទាំងនោះ ក៏ជាមង្គលដែរ ព្រោះរាប់ថា ជាកុសលធម៌ និងព្រោះ

ជាហេតុចម្រើនអាយុជាដើម ។ ព្រះដ៏មានព្រះភាគជាម្ចាស់
មានព្រះពុទ្ធតម្រាស់ទុកដូច្នេះថា ជនទាំងនោះជាអ្នកទំនុក
បម្រុង ត្រកូលមាតាបិតា ពួកសមណៈ ពួកព្រាហ្មណ៍ ជាអ្នក
គោរពរាប់អានអ្នកជាធំក្នុងត្រកូល ប្រកាន់យកនូវកុសលធម៌
មកបដិបត្តិ ក៏នឹងចម្រើន ទាំងអាយុ ទាំងវណ្ណៈ ព្រោះហេតុ
សមាទាន កុសលធម៌ទាំងនោះ ។

ព្រោះហេតុដែលខ្ញុំម្ចាស់ តាំងមាតិកានាំមុខក្នុងវគ្គទុក
ដើម្បីពោលពីសមុដ្ឋាននាំឱ្យកើតមង្គល ហើយកំណត់មង្គលនោះ
និងបង្ហាញឱ្យឃើញជាក់ច្បាស់នូវសេចក្តីរបស់មង្គលនោះ ដូច្នោះ
ទើបសូមលើកឡើងយ៉ាងដូច្នេះ ។ ព្រះដ៏មានព្រះភាគជាម្ចាស់
ទ្រង់ត្រាស់ព្រះគាថានេះ ទុក ៣ មង្គលគឺ ការមិនសេពគប់ពាល១
ការសេពគប់បណ្ឌិត១ និងការបូជាអ្នកដែលគួរបូជា ១ ដោយ
ប្រការយ៉ាងដូច្នេះ ។ ក្នុងមង្គលទាំង ៣ នោះ គប្បីជ្រាបថា
ការមិនសេពគប់ពាល ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍
របស់លោកទាំងពីរ និងហេតុជួយការពារនូវភ័យដែលកើតមាន
ឡើង ។ ការសេពគប់បណ្ឌិតនិងការបូជាអ្នក ដែលគួរបូជា
ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃនិព្វាននិងសុគតិ ដោយន័យ
ដែលពោលទុកហើយក្នុងការពណ៌នាសេចក្តីបង្កើតឡើងនូវផល

របស់ការគប់បណ្ឌិត និងការបូជាអ្នកដែលគួរបូជានោះឯង ។ ប៉ុន្តែខ្ញុំម្ចាស់ នៅមិនទាន់សម្តែងនាំវគ្គតពីនេះទៅ ដោយកំណត់ចំណុចដែលជាមង្គលយ៉ាងនេះ និងលើកឡើងឱ្យឃើញជាក់ច្បាស់នូវសេចក្តីក្នុងវគ្គនោះជាមង្គល ។

ពណ៌នាគាថាទី ២ ថា បដិរូបទេសវាសោ ច

ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រូវទេវបុត្រសូមមង្គលតែមួយថា **ព្យាហិ មង្គលមុត្តមំ** សូមប្រោសត្រាស់ប្រាប់នូវមង្គលដ៏ឧត្តម ក៏បានត្រាស់ដល់ទៅ ៣ មង្គល ដោយគាថាតែមួយប្រៀបដូច បុរសចិត្តទូលាយត្រូវគេសូមពីតិចតែឱ្យច្រើន ធ្វើឱ្យទ្រង់ផ្តើមត្រាស់មង្គលដទៃទៀត ដោយគាថាទាំងឡាយថា **បដិរូបទេសវាសោ ច** ជាដើម ព្រោះទេវតាទាំងនោះប្រាថ្នាស្តាប់ នូវមង្គលទាំងឡាយដែលមាននិងព្រោះមង្គលណាៗ តែងជួយគាំទ្រដល់សត្វណាៗ ក៏ទ្រង់មានពុទ្ធប្រាថ្នាប្រកបសត្វនោះៗ ទុកក្នុងមង្គលនោះ ដូចបានពោលក្នុងគាថាមុនដំបូង ។ បទថា **បដិរូបោ** ប្រែថា : សមគួរ ឱកាសជាទីនៅអាស្រ័យរបស់សត្វទាំងឡាយគ្រប់កន្លែង មិនថាជាភូមិក្តី និគមក្តី នគរក្តី ជនបទក្តី ក៏ឈ្មោះថា **ទេសៈ** ដែរ ។ ការនៅអាស្រ័យក្នុង

ទេសៈនោះ ឈ្មោះថា **ទាសៈ** ។ បទថា **បុរេ** ប្រែថា ពីមុន គឺ ក្នុងជាតិដែលកន្លងរួចមកហើយ ។ ភាពជាអ្នកមានកុសលសន្សំមកហើយ ឈ្មោះថា ភាពជាអ្នកមានបុណ្យបានធ្វើទុកហើយ ។ ចិត្ត ឬអត្តភាពទាំងអស់ ហៅថា អត្តៈ ។ ការប្រកបទុក គឺការតាំងសេចក្តីប្រាថ្នារបស់ខ្លួនទុកដោយប្រពៃ លោកអធិប្បាយថា ការតាំងខ្លួនដោយប្រពៃ ឈ្មោះថា សម្ភាបណិធិ ប្រែថា: ការតាំងទុកដោយប្រពៃ ។ ពាក្យក្រៅពីនេះមានន័យដែលពោលហើយទាំងនោះ នេះជាការពណ៌នាបទក្នុងគាថាមុន ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូចនេះ ។

ក្នុងប្រទេសណាមានបរិស័ទ ៤ ជំពូក ស្គាក់អាស្រ័យនៅ អាចបំពេញបុញ្ញកិរិយាវត្ថុ មានទានជាដើម នវង្គសត្ថុសាសន៍ ធ្វើឱ្យរុងរឿង ប្រទេសនោះឈ្មោះថា **បដិរូបទេស** ។ ការនៅអាស្រ័យក្នុងបដិរូបទេសនោះ ទ្រង់ត្រាស់ថាជាមង្គល ព្រោះជាបច្ច័យដល់ការធ្វើបុណ្យរបស់សត្វទាំងឡាយ ។ ក្នុងសេចក្តីនេះ មានប្រជាជនអ្នកនេសាទត្រីដែលចូលទៅញ៉ាំងកោះសិង្គលៈជាតួយ៉ាង ។

ម្យ៉ាងទៀត ប្រទេសដែលជាទីត្រាស់ដឹងព្រះពោធិញ្ញាណ (ទីត្រាស់ដឹងព្រះពុទ្ធជាម្ចាស់ហៅពោធិមណ្ឌលស្ថាន) ប្រទេស

ដែលប្រកាសព្រះធម្មចក្រ ប្រទេសគឺគល់ដើមស្វាយ របស់នាយគណ្ឌៈ ដែលទ្រង់សម្តែងយមកបាដិហារិយ៍ បំផ្លាញ សេចក្តីវង្វេងរបស់ពួកតិរ្ថិយទាំងពួងពាក់កណ្តាលបរិស័ទ ប្រមាណ ១២ យោជន៍. ប្រទេសដែលស្តេចចុះចាកទេវលោក ឬប្រទេសណាដែលជាទីប្រថាប់របស់ព្រះពុទ្ធជាម្ចាស់ មាន ក្រុងសាវត្ថី ក្រុងរាជគ្រឹះជាដើម ប្រទេសនេះឈ្មោះថា បដិរូបទេស ។ ការនៅអាស្រ័យ ក្នុងបដិរូបទេសនោះ ទ្រង់ត្រាស់ថា **ជាមង្គល** ព្រោះជាបច្ច័យដល់ការបាននូវ អនុត្តរិយៈ ៦ របស់សត្វទាំងឡាយ ។

ន័យម្យ៉ាងទៀត ទិសបូព៌ា តាំងពីកជង្គលនិគម ចុះមកដល់មហាសាលា បរិវេណខាងក្រៅ ជាបច្ចន្តិមជនបទ បរិវេណខាងក្នុង ជាមជ្ឈិមជនបទ ។ ទិសអាគ្នេយ៍ តាំងពីទន្លេគង្គាសល្លវតីចុះមក បរិវេណខាងក្រៅជាបច្ចន្តិមជនបទ បរិវេណខាងក្នុងជាមជ្ឈិមជនបទ ។ ទិសទក្សិណ តាំងពីសេតកណ្ណិកនិគមចុះមក បរិវេណខាងក្រៅជាបច្ចន្តិមជនបទ បរិវេណខាងក្នុងជាមជ្ឈិមជនបទ។ ទិសបស្ចឹម (ខាងលិច)តាំងពីថូណៈតំបន់ផ្ទះព្រាហ្មណ៍ចុះមក បរិវេណខាងក្រៅ ជាបច្ចន្តិមជនបទ បរិវេណខាងក្នុងជាមជ្ឈិមជនបទ ។ ទិសឧត្តរ តាំងពីភ្នំឧសីរធជៈចុះមក បរិវេណខាងក្រៅ ជាបច្ចន្តិមជនបទ បរិវេណខាងក្នុងជា

មជ្ឈិមជនបទ ។ នេះជាមជ្ឈិមប្រទេសមាន បណ្តោយ ៣០០ យោជន៍ និងទទឹង ២៥០ យោជន៍ ដោយជុំវិញ ៩០០ យោជន៍ ។ មជ្ឈិមប្រទេសនេះ ឈ្មោះថា បដិរូបទេស ។

ស្តេចចក្រពត្តិទាំងឡាយ អ្នកគ្រប់គ្រងឥសរិយាធិបត្យ នៃទ្វីបធំទាំង ៤ ទ្វីបតូច ២.០០០ រមែងកើតក្នុងបដិរូបទេសនោះ ព្រះមហាសាវ័កទាំងឡាយ មានព្រះសារីបុត្រ និង ព្រះមោគ្គល្លានជាដើម បំពេញបារមីមក ១ អសង្ខ្យៃកប្ប និង ១ សែនកប្បក៏កើតក្នុងបដិរូបទេសនោះ ព្រះបច្ចេកពុទ្ធទាំងឡាយ បំពេញបារមីមក ២ អសង្ខ្យៃកប្ប និង ១ សែនកប្បក៏កើតក្នុងបដិរូបទេសនោះដែរ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់បំពេញបារមីមក ៤ អសង្ខ្យៃកប្ប ១ សែនកប្បខ្លះ ៨ អសង្ខ្យៃកប្ប ១ សែនកប្បខ្លះ ១៦ អសង្ខ្យៃកប្ប ១ សែនកប្បខ្លះ ក៏ស្តេចឧប្បត្តិក្នុង បដិរូបទេសនោះទាំងអស់ដូចគ្នា ។ បណ្តាលោកទាំងនោះសត្វទាំងឡាយ ទទួលឱវាទពីស្តេចចក្រពត្តិឱ្យតាំងនៅក្នុងសីល ៥ ហើយ ក៏មានឋានសួគ៌នៅខាងមុខ តាំងនៅក្នុងឱវាទរបស់ព្រះបច្ចេកពុទ្ធដូចគ្នា ។ ចំណែកសត្វទាំងឡាយតាំងនៅក្នុងឱវាទរបស់ព្រះពុទ្ធជាម្ចាស់ របស់សាវ័កព្រះពុទ្ធជាម្ចាស់ រមែងមានឋានសួគ៌នៅខាងមុខ មានព្រះនិព្វាននៅខាងមុខ ព្រោះ

ដូច្នោះការរស់នៅក្នុង បដិរូបទេសនោះទ្រង់ត្រាស់ថា **ជាមង្គល** ព្រោះជាបច្ច័យនៃ សម្បត្តិទាំងនោះ ។

ភាពជាអ្នកប្រារព្ធព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និងព្រះខីណាស្រព សាងសន្សំកុសលទុកក្នុងជាតិកន្លងមកហើយ ឈ្មោះថា ភាពជាអ្នកបានធ្វើបុណ្យទុកក្នុងកាលមុន សូម្បីភាពជាអ្នកបានធ្វើបុណ្យទុកក្នុងកាលមុននោះ ក៏ជាមង្គល ព្រោះហេតុអ្វី អធិប្បាយថា ភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន រមែងឱ្យបានសម្រេចព្រះអរហត្ត ។ ពេលចប់គាថា ៤ បទ ដែលសម្តែងចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធជាម្ចាស់ និងព្រះបច្ចេកពុទ្ធជាម្ចាស់ឬស្តាប់ចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធជាម្ចាស់ ឬសាវ័ករបស់ព្រះពុទ្ធជាម្ចាស់ក៏មនុស្សណាបានសាងបារមីទុក មានកុសលមូលក្រាស់ក្រែលពីមុនមក មនុស្សនោះធ្វើវិបស្សនាឱ្យកើតឡើងរមែងសម្រេចធម៌ ដោយអស់អាសវៈមានកុសលមូលជាហេតុនោះឯង ដូចព្រះបាទមហាកប្បិន និងអគ្គមហេសី។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា ភាពជាអ្នក បានធ្វើបុណ្យទុកក្នុងកាលមុនជា **មង្គល** ។

មនុស្សខ្លះក្នុងលោកនេះ រមែងធ្វើខ្លួនដែលទ្រុស្តសីលឱ្យតាំងនៅក្នុងសុសីល អ្នកដែលមិនមានសទ្ធា ឱ្យតាំងនៅក្នុង

សទ្ធាសម្បទា អ្នកដែលកំណាញ់ឱ្យតាំងនៅក្នុងចាគសម្បទា ការតាំងខ្លួនដូចពោលមកនោះឈ្មោះថា តាំងខ្លួនទុកប្រពៃ ។ ការតាំងខ្លួនទុកប្រពៃ ហៅថា អត្តសម្ចាបណិធិ ។ អត្តសម្ចាបណិធិនេះឯងជាមង្គល ព្រោះហេតុអ្វី ព្រោះជាហេតុលះនូវវេរាដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងខាងមុខ ហើយនឹងជួបនូវអានិសង្សផ្សេងៗ ច្រើនយ៉ាង ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ក្នុងគាថានេះទុក ៣ មង្គល គឺការនៅក្នុងបដិរូបទេស ១ ភាពជាអ្នកបានធ្វើបុណ្យទុកក្នុងកាលមុន ១ និងការតាំងខ្លួនទុកប្រពៃ ១ ដោយប្រការដូច្នេះ ។

ពណ៌នាគាថាទី ៣ ថា ពាហុសច្ចញ្ច

ភាពជា ពហុស្សុត ឈ្មោះថា ពាហុសច្ចៈ ក្នុងបទនេះ ថា **ពាហុសច្ចញ្ច** ។ សេចក្តីឆ្លាតក្នុងការងារដោយដៃគ្រប់យ៉ាង ឈ្មោះថា សិល្បៈ ។ ការហ្វឹកហាត់ កាយវាចាចិត្ត ឈ្មោះថា វិន័យ ។ បទថា **សុសិក្ខិតោ** ប្រែថា : ដែលគេសិក្សាបានល្អហើយ ។ បទថា **សុភាសិតា** ប្រែថា ដែលគេពោលបានល្អហើយ ។ សព្ទថា **យា** សម្តែង សេចក្តីមិនពិតប្រាកដ ។

ពាក្យថ្លែងការនិយាយ ឈ្មោះថា វាចា ពាក្យដែលនៅសល់មានន័យដូចពោលមកហើយនោះឯង ។ នេះជាការពណ៌នាបទក្នុងគាថា **ពាហុសច្ចញ្ច** នេះ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូចនេះ

ភាពជាអ្នកទ្រទ្រង់ទុកនូវ សត្ថុសាសន៍ ដែលទ្រង់ពណ៌នាទុក ដោយន័យជាដើមយ៉ាងនេះថា ជាអ្នកទ្រទ្រង់សុតៈ សន្សំសុតៈ និង ថាភិក្ខុរូបខ្លះក្នុងព្រះធម្មវិន័យនេះ មានសុតៈច្រើន គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ ជាដើម ឈ្មោះថា ជាពហុស្សូត ។ ភាពជា ពហុស្សូតនោះ ទ្រង់ត្រាស់ថា **ជាមង្គល** ព្រោះជាហេតុលះ អកុសល បានជួបប្រសព្វនូវកុសល និង ព្រោះជាហេតុធ្វើឱ្យជាក់ច្បាស់នូវបរមត្ថសច្ចៈតាមលំដាប់ សមពិតដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកដូច្នេះថា :-

ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកស្តាប់ហើយ រមែងលះអកុសល ចម្រើនកុសល រមែងលះរបស់មានទោស ចម្រើនរបស់មិនមានទោស បរិហារ (ដោះស្រាយ) ខ្លួនឱ្យបរិសុទ្ធដូច្នេះ ។

ព្រះតម្រាស់មួយទៀតទ្រង់ត្រាស់ថា :-

រមែងពិចារណាសេចក្តីរបស់ធម៌ទាំងឡាយ ដែលទ្រង់ចាំទុកនូវធម៌ទាំងឡាយ រមែងអត់ធន់ចំពោះការសម្លឹងពិនិត្យរបស់អ្នកពិចារណាសេចក្តី ។ ពេលធម៌អត់ធន់របស់ការសម្លឹងពិនិត្យ ឆន្ទៈរមែងកើតឡើង ឆន្ទៈកើតហើយក៏ឧស្សាហៈ ពេលឧស្សាហៈក៏ថ្លឹងថ្លែងពិនិត្យ ពេលថ្លឹងថ្លែងពិនិត្យ ក៏តាំងសេចក្តីព្យាយាម ពេលតាំងសេចក្តីព្យាយាម រមែងធ្វើឱ្យជាក់ច្បាស់នូវបរមត្ថសច្ចៈដោយកាយ (នាមកាយ) និងរមែងឃើញធ្លុះធ្លាយដោយបញ្ញាយ៉ាងដូច្នេះ ។

ម្យ៉ាងទៀត សូម្បីពាហុសច្ចៈភាពជាពហុស្សូតរបស់គ្រហស្ថណាមិនមានទោសនោះ ក៏គប្បីជ្រាបថា ជា **មង្គល** ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំងពីរ ។

សិល្បៈរបស់គ្រហស្ថ និងសិល្បៈរបស់បព្វជិតឈ្មោះថា សិល្បៈ ។ បណ្តាសិល្បៈទាំង ២ នោះ កិច្ចកម្មមានការងាររបស់ជាងកែវមណី និងជាងមាសជាដើម ដែលវៀរចាក ការបំផ្លាញជីវិតសត្វដទៃ វៀរចាកអកុសល ឈ្មោះថា អគារិកសិប្បៈ ជាសិល្បៈ របស់គ្រហស្ថ ។ អគារិកសិប្បៈនោះ ឈ្មោះថា ជា **មង្គល** ព្រោះ នាំមកនូវប្រយោជន៍ក្នុងលោកនេះ ។

ការចាត់ធ្វើសមណបរិក្ខារមានការប៉ាន់ស្មាននិងដេរចីវរ ជាដើម ដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សរសើរទុកក្នុងទីនោះៗ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ កិច្ចដែលគួរធ្វើអ្វីៗ របស់សព្រហ្មចារី មិនថាខ្ពស់ទាបយ៉ាងណា ភិក្ខុជាអ្នកខំព្យាយាមក្នុងកិច្ចដែលគួរធ្វើនូវអ្វីៗនោះ ដែលត្រាស់ថា ជានាថករណធម៌ (ធម៌ធ្វើនូវទីពឹង) ឈ្មោះថា អនាគារិកសិប្បៈជាសិល្បៈរបស់បព្វជិត ។ សិល្បៈរបស់បព្វជិតនោះ គប្បីជ្រាបថាជា **មង្គល** ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំងពីរដល់ខ្លួនឯង និងអ្នកដទៃ ។

វិន័យរបស់គ្រហស្ថ និងវិន័យរបស់បព្វជិត ឈ្មោះថា វិន័យ ។ បណ្តាវិន័យទាំង ២ នោះ ការវៀរអកុសលកម្មបថ ១០ ឈ្មោះថា វិន័យរបស់គ្រហស្ថ ។ វិន័យរបស់គ្រហស្ថនោះ គ្រហស្ថបានសិក្សាល្អហើយក្នុងវិន័យនោះ ឈ្មោះថា ជា **មង្គល** ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំងពីរ ដោយមិនត្រូវសិង្គិលេស ការសៅហ្មង និងការកំណាត់គុណគឺ អាចារៈ ។

ការមិនត្រូវអាបត្តិ ៧ កង ឈ្មោះថា **វិន័យរបស់-បព្វជិត** ។ សូម្បីវិន័យរបស់បព្វជិត ដែលបព្វជិតសិក្សាបានល្អ

ដោយន័យដែលពោលមកហើយ ឬបាវិសុទ្ធិសីល ៤ ឈ្មោះថា វិន័យរបស់បព្វជិត ។ វិន័យរបស់បព្វជិត ដែលបព្វជិតសិក្សាល្អ តាមប្រការដែលតាំងនៅក្នុងបាវិសុទ្ធិសីល ៤ នោះហើយ នឹងសម្រេចព្រះអរហត្តបាន គប្បីជ្រាបថា ជា **មង្គល** ព្រោះជាហេតុជូបនូវសុខទាំងលោកិយៈ និងលោកុត្តរៈ ។

វាចាដែលវៀរចាកទោសមានមុសាវាទជាដើម ឈ្មោះថា **ភាចាសុភាសិត** ដូចយ៉ាងដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ ជាវាចា សុភាសិត ឬថា វាចាដែលចរចាមិនផ្តេសផ្តាសក៏ឈ្មោះថា វាចាសុភាសិតដែរ ដូចយ៉ាងដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា :-

សុភាសិតំ ខុត្តម្ហាហុ សន្តោ
ធម្មំ ភណេ នាធម្មំ តំ ទុតិយំ
បិយំ ភណេ នាប្បិយំ តំ តតិយំ
សច្ចំ ភណេ នានិកំ តំ ចតុត្ថំ ។

ប្រែថា : បុរសទាំងឡាយពោលថា វាចាសុភាសិត ជាវាចាខ្ពស់បំផុត ជាប្រការទី ១ បុគ្គលគប្បីពោលតែធម៌ មិន

ពោល អធម្ម ជាប្រការទី ២ គប្បីពោលតែពាក្យគួរជាទីស្រឡាញ់ មិនពោលពាក្យមិនជាទីស្រឡាញ់ ជាប្រការទី ៣ ពោលតែពាក្យសត្យ មិនពោលពាក្យឡេះឡស់ ជាប្រការទី ៤ ។

សូម្បី វាចាសុភាសិតនោះ គប្បីជ្រាបថា ជា មង្គល ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំងពីរ ប៉ុន្តែព្រោះហេតុតែវាចាសុភាសិតជាប់ទាក់ទងក្នុងវិន័យ ដូច្នោះទោះបីមិនសង្គ្រោះវាចាសុភាសិតទុកដោយវិន័យសព្វ គប្បីជ្រាបថាជាវិន័យដែរ ។ យ៉ាងដូច្នោះ វាចាមានការសម្តែងធម៌ដល់អ្នកដទៃជាដើម គួរជ្រាបថា ជាវាចាសុភាសិត ។ សេចក្តីពិត វាចាសុភាសិត ទ្រង់ត្រាស់ថា ជា **មង្គល** ព្រោះជាហេតុជួបប្រសព្វសុខក្នុងលោកទាំងពីរនិងព្រះនិព្វានរបស់សត្វទាំងឡាយ ក៏ដូចជាការរស់នៅក្នុងបដិរូបទេស ។ ព្រះវង្គីសត្ថេរៈពោលទុកថា :-

យំ ពុទ្ធោ ភាសតី ខាចំ ខេមំ និព្វានបត្តិយា

ទុក្ខស្សន្តកិរិយាយ សារេ ខាចានមុត្តមា ។

ប្រែថា : ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ព្រះវាចាណាដែលក្សេម ដើម្បីចាក់ធ្លុះឃើញព្រះនិព្វាន ដើម្បីធ្វើទីបំផុតទុក្ខ ព្រះវាចានោះឯង ជាកំពូលលើវាចាទាំងឡាយ ។

ព្រះពុទ្ធទ្រង់ត្រាស់ក្នុងគាថានេះ ទុក ៤ មង្គល គឺ ពាហុសច្ចៈ១ សិប្បៈ ១ វិន័យដែលសិក្សាល្អហើយ ១ និងវាចាសុភាសិត ១ ដោយប្រការដូច្នេះ ។

ពណ៌នាគាថាទី ៥ ថា មាតាបិតុឧបដ្ឋានំ

ពណ៌នាក្នុងគាថានេះថា មាតាបិតុឧបដ្ឋានំ ។ មាតានិងបិតា ហេតុនោះឈ្មោះថា មាតានិងបិតា ។ បទថា **ឧបដ្ឋានំ** ប្រែថា: ការទំនុកបម្រុងបុត្រផង ភរិយាទាំងឡាយផង ឈ្មោះថា បុត្រ និងភរិយា ការសង្គ្រោះ ឈ្មោះថា សង្គហៈ។ ការងារគឺកិច្ចកម្មច្របូកច្របល់មិនមាន ឈ្មោះថា មិនច្របូកច្របល់ ពាក្យដែលនៅសល់មានន័យ ដែលពោលមកហើយនោះឯង នេះជាការពណ៌នាបទ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ ស្ត្រីអ្នកបង្កើតបុត្រឈ្មោះថា មាតា បិតាក៏ដូចគ្នា ។ ការធ្វើឧបការៈដោយការលាងជើងគក់ច្រមាច់ ឱ្យងូតទឹក និងជូនបច្ច័យ ៤ ឈ្មោះថា ការទំនុកបម្រុង ។ ក្នុងការទំនុកបម្រុងនោះ ព្រោះហេតុមាតានិងបិតាមានឧបការៈច្រើន ស្វែងរកប្រយោជន៍អនុគ្រោះបុត្រទាំងឡាយ ។ មាតាបិតាទាំងនោះណាក្រលេក

ឃើញបុត្រទាំងឡាយលេងនៅខាងក្រៅ ដើរមកមានខ្លួន
ប្រឡាក់ធូលី ក៏បបោសជូតធូលី រួចថើបថ្នមដោយសេចក្តីស្រឡាញ់ ។
បុត្រទាំងឡាយខ្លះ ទោះបីលើកទូលមាតាបិតាដាក់នៅលើក្បាល
ទុកឱ្យបាន ១ រយ ឆ្នាំ ក៏មិនអាចនឹងធ្វើបដិការៈតបស្នងគុណ
របស់ មាតាបិតានោះបាន ព្រោះហេតុតែមាតាបិតា ជាអ្នក
ថែរក្សា ទំនុកបម្រុងចិញ្ចឹមបុត្រ ដែលលោកនេះសម្មតិថា ជាព្រហ្ម
ថាជា បុព្វាចារ្យ ។ ដូច្នោះការទំនុកបម្រុងមាតាបិតា រមែង
នាំមក នូវការសរសើរក្នុងលោក និងលះលោកនេះទៅនាំមក
នូវសុខក្នុងឋានសួគ៌ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា ជា
មង្គល សមពិត ដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថាៈ-

មាតាបិតា លោកហៅថា ជាព្រហ្ម ថា បុព្វាចារ្យ ជា
អាហុណេយ្យបុគ្គលរបស់បុត្រ ជាអ្នកអនុគ្រោះបុត្រ ព្រោះ
ដូច្នោះ បណ្ឌិតគប្បីប្រតិបត្តិ និងគប្បីទំនុកបម្រុងមាតាបិតា
នោះ ដោយ បាយ ទឹក សំពត់ ទីដេក ឱ្យងូតទឹក និងលាង
ជើង ព្រោះការប្រតិបត្តិចំពោះមាតាបិតា បណ្ឌិតទាំងឡាយ
ទ្រង់ សរសើរគេក្នុងលោកនេះ លុះគេលះលោកនេះទៅ នឹង
បានទៅសោយសុខ ក្នុងឋានសួគ៌ ។

ន័យមួយទៀត កិច្ចកម្ម ៥ យ៉ាង មានការចិញ្ចឹមថែរក្សា មាតាបិតា ជួយធ្វើកិច្ចការរបស់លោក រក្សាវង្សត្រកូលជាដើម ឈ្មោះថាការទំនុកបម្រុង ។ ការទំនុកបម្រុងនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍សុខក្នុងបច្ចុប្បន្ន ៥ យ៉ាង មានការហាមមិនឱ្យបុត្រធ្វើអំពើបាបជាដើម សមពិតដូច ដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា :-

ម្នាលបុត្រគហបតី ទិសខាងមុខ គឺ មាតាបិតាដែលបុត្រគប្បីទំនុកបំរុងដោយស្ថាន ៥ យ៉ាង ព្រោះយើងលោកចិញ្ចឹមមកហើយ នឹងត្រូវចិញ្ចឹមមើលថែលោកវិញ ជួយធ្វើកិច្ចរបស់លោក រក្សាវង្សត្រកូល និងបដិបត្តិខ្លួនឱ្យសមគួរជាទាយាទ ពេលលោករំលត់ខន្ធកន្លងផុតទៅ នឹងធ្វើបុណ្យឧទ្ទិសជូនទៅឱ្យលោក ។ ម្នាលបុត្រគហបតី ទិសខាងមុខគឺមាតាបិតាដែលបុត្រទំនុកបម្រុងដោយស្ថាន ៥ ទាំងនោះហើយ រមែងអនុគ្រោះបុត្រដោយស្ថាន ៥ យ៉ាងវិញ គឺហាមបុត្រចាកសេចក្តីខុស ឱ្យបុត្រតាំងនៅក្នុងអំពើល្អ ឱ្យសិក្សាសិល្បៈ និងរកភរិយាដ៏សមរម្យ ហើយប្រគល់ទ្រព្យសម្បត្តិមរតកឱ្យក្នុងវេលាដ៏សមគួរ ។

ម្យ៉ាងទៀត អ្នកណាទំនុកបម្រុងមាតាបិតា ដោយធ្វើឱ្យកើតសេចក្តីជ្រះថ្លាក្នុងវត្ថុ (រតនៈ) ទាំងបី ដល់ព្រមដោយសីល

ដោយការបព្វជ្ជា អ្នកនោះជាកំពូលរបស់អ្នកទំនុកបម្រុងមាតាបិតា ។ ការទំនុកបម្រុងមាតាបិតារបស់អ្នកនោះ ជាការតបស្នង នូវឧបការគុណដែលមាតាបិតាធ្វើរួចមកហើយ ទ្រង់ត្រាស់ថា ជា **មង្គល** ព្រោះជាបទដ្ឋាននៃប្រយោជន៍ទាំងឡាយ ទាំងបច្ចុប្បន្ន ទាំងចំណែកខាងមុខយ៉ាងច្រើន ទាំងបុត្រធីតា ដែលកើតចេញពីខ្លួនក៏រាប់ថា ជាបុត្រក្នុងពាក្យថា **បុត្តទារស្ស** នេះ ។

បទថា **ទារ** បានដល់ភរិយា ២០ ជំពូក ក្នុងជំពូកណាមួយ ។ បុត្រនិងភរិយាឈ្មោះថា **បុត្តទារៈ** គឺបុត្រ និងភរិយានោះ ។ បទថា **សង្គហោ** បានដល់ ការធ្វើឧបការៈដោយការលើកសរសើរជាដើម ។ ការឧបការៈនោះ គប្បីជ្រាបថា ជា **មង្គល** ព្រោះជាហេតុនៃប្រយោជន៍សុខក្នុងបច្ចុប្បន្ន មានភាពជាអ្នកធ្វើការងារល្អជាដើម សេចក្តីពិតព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សង្គ្រោះ បុត្រភរិយាដែលទ្រង់លើកឡើងសម្តែងថា ទិសខាងក្រោយ គប្បីជ្រាបថា គឺបុត្រភរិយាទុកដោយភរិយាស័ព្ទ ទើបត្រាស់ទុកដូច្នេះថា :-

ម្នាលគហបតីបុត្រ ទិសខាងក្រោយគឺ ភរិយា ដែលស្វាមី គប្បីទំនុកបម្រុងដោយស្ថាន ៥ យ៉ាង គឺ ដោយការលើកសរសើរ មិនមើលងាយ មិនក្បត់ចិត្ត ប្រគល់ភាពជាធំឱ្យក្នុងគ្រួសារ ប្រគល់ គ្រឿងប្រដាប់អលង្ការឱ្យ ។ ម្នាលគហបតីបុត្រ ទិសខាងក្រោយ គឺភរិយាដែលស្វាមីទំនុកបម្រុងដោយស្ថាន ៥ យ៉ាង ទាំងនោះហើយ រមែងអនុគ្រោះស្វាមីដោយស្ថាន ៥ យ៉ាង វិញដែរ គឺ ធ្វើ ការងារ ល្អ សង្គ្រោះអ្នកជិតខាង មិនក្បត់ចិត្ត រក្សាទ្រព្យដែលស្វាមីរកបាន ឧស្សាហ៍មិនខ្ជិលច្រអូសក្នុងកិច្ចការគ្រប់យ៉ាង ។

នៃយមួយទៀត បទថា **សង្គហោ** បានដល់ការសង្គ្រោះដោយការឱ្យទាន មានវាចាគួរស្រឡាញ់ អត្ថចរិយា ការបំពេញប្រយោជន៍ដែលជាធម៌ មានការជូនស្បៀងអាហារ ក្នុងថ្ងៃឧបោសថ ការឱ្យទៅមើលបុណ្យនក្ខត្តឫក្ស ការធ្វើមង្គលក្នុងថ្ងៃមង្គល ការឱ្យឱវាទទូន្មានក្នុងប្រយោជន៍ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននិងទៅខាងមុខ ការសង្គ្រោះនោះ គប្បីជ្រាបថា ជា **មង្គល** ព្រោះហេតុនៃប្រយោជន៍ក្នុងបច្ចុប្បន្ន និង

ប្រយោជន៍ទៅខាងមុខ ព្រោះទេវតាទាំងឡាយគោរព សំពះ
ដូចយ៉ាង ដែលសក្កៈកំពូលទេពត្រាស់ទុកថា :-

យេ គហដ្ឋា បុញ្ញករា សីលវន្តោ ឧបាសកា
ធម្មេន ទារំ បោសេន្តិ តេ នមស្សាមិ មាតលិ ។

ប្រែថា: ម្នាលមាតលិ គ្រហស្ថពួកណាធ្វើបុណ្យ មានសីល
ជាឧបោសថ ចិញ្ចឹមថែរក្សាភរិយាដោយធម៌ យើងរមែងគោរព
ប្រតិបត្តិនូវគ្រហស្ថទាំងនោះ ។

ការងារទាំងឡាយ មានកសិកម្មធ្វើស្រែចម្ការ គោរក្ខកម្ម
ចិញ្ចឹមគោ និងវាណិជ្ជកម្ម លក់ដូរជាដើម វៀរចាកភាវៈច្របូក
ច្របល់មានការខ្ជះខ្ជាយពេលវេលា ការធ្វើមិនសមគួរនិង
ការងារមិនត្រឹមត្រូវជាដើម ព្រោះជាអ្នកដឹងពេលវេលា ជាអ្នក
ធ្វើសមគួរ មិនខ្ជិលច្រអូសនិងព្រោះមិនវិនាស ហេតុដល់ព្រម
ដោយការឧស្សាហ៍ព្យាយាម ឈ្មោះថាការងារមិនច្របូក
ច្របល់ ។ ទាំងអស់នោះ ដែលបុគ្គលប្រកបបានយ៉ាងនេះ ក៏ព្រោះ
អាស្រ័យពីខ្លួន គឺ បុត្រ ភរិយា ឬ ទាសៈនិងកម្មករជាអ្នកឆ្លាត
ទើបទ្រង់ត្រាស់ថា ជា **ធន្តល** ព្រោះជាហេតុឱ្យបានទ្រព្យនិង
សេចក្តីចម្រើន ក្នុងបច្ចុប្បន្ន សមពិតដូចដែលព្រះដ៏មានព្រះភាគ
ទ្រង់ត្រាស់ដូច្នេះថា:-

អ្នកមានធុរៈ ធ្វើសមគួរ ឧស្សាហ៍ព្យាយាម រមែងបានទ្រព្យ ហើយពោលថា :-

អ្នកចូលចិត្តដេកលក់កណ្តាលថ្ងៃ ស្អប់ខ្ពើមការយកចិត្តទុកដាក់ពេលយប់ ជាអ្នកស្រវឹងប្រចាំ ជាអ្នកលេង នឹងមិនអាចគ្រប់គ្រងផ្ទះបាន ចំណែកប្រយោជន៍ទាំងឡាយ រមែងកន្លងហួសទៅ ។ ពួកមនុស្សវ័យក្មេងមិនយកចិត្តទុកដាក់ និងការងារដោយអាងថា រងាណាស់ ក្តៅណាស់ ត្រជាក់ពេក ។ អ្នកណាមិនកត់សម្គាល់ភាពត្រជាក់និងក្តៅជាងស្មៅ អ្នកនោះពិតជាកូនប្រុសមិនវិនាសចាក សេចក្តីសុខ ។

ហើយពោលថា :-

ពេលអ្នកប្រមូលភោគទ្រព្យ ដូចឃ្មុំប្រមូលទឹកផ្អែមភោគទ្រព្យរមែងសន្សំជាគំនរ ដូចដំបូកដែលសត្វកណ្តៀរកពូនឡើងយ៉ាងដូច្នោះ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ព្រះគាថានេះទុក ៤ មង្គល គឺការទំនុកបម្រុងមាតា ១ បិតា ១ ការសង្គ្រោះបុត្រភរិយា ១ និងការងារមិនច្របូកច្របល់ ១ ឬ ៥ មង្គល ព្រោះចែកការសង្គ្រោះបុត្រ និងភរិយាជា ២ ឬ ៣ មង្គល ព្រោះរួមការទំនុកបម្រុងមាតា និងបិតា ជាប្រការ ១ ។

ពណ៌នាគាថាទី ៥ ថា ទានញ្ច

ឈ្មោះថា ទាន ព្រោះគេឱ្យដោយវត្ថុ លោកអធិប្បាយថា គេប្រគល់ទ្រព្យរបស់ខ្លួនឱ្យដល់អ្នកដទៃ ។ ការប្រព្រឹត្តិធម៌ ឬ ការប្រព្រឹត្តិមិនប្រាសចាកធម៌ ឈ្មោះថា **ធម្មចរិយា** ។ ឈ្មោះ ថា ញាតិ ព្រោះអ្នកណាៗ ក៏ដឹងថា អ្នកនោះជាពួកក្រុមរបស់ យើង។ មិនមានទោស ឈ្មោះថា អនវជ្ជៈ លោកអធិប្បាយថា អ្នកណាៗ និន្ទាមិនបាន ទិទ្បៀនមិនបាន ។ ពាក្យដែលនៅសល់ មានន័យ ដែលពោលមកហើយនោះឯង ។ នេះជាការពណ៌នាបទ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបយ៉ាងដូចនេះ ។ ចេតនា ជាហេតុបរិច្ចាគទានវត្ថុ ១០ មានបាយទឹកជាដើម ដែលមាន ការដឹង ជាប្រធាននាំមុខចំពោះអ្នកដទៃ ឬសេចក្តីមិនលោភ ប្រកបដោយចាគចេតនានោះ ឈ្មោះថា **ទាន** ។ តាមពិត បុគ្គល រមែង ប្រគល់វត្ថុនោះឱ្យដល់អ្នកដទៃ ដោយសេចក្តីមិនលោភ ដោយហេតុនោះ ខ្ញុំម្ចាស់ទើបពោលថា ឈ្មោះថា **ទាន** ព្រោះ គេឱ្យទានដោយវត្ថុនេះ ទ្រង់ត្រាស់ថា ជា **មង្គល** ព្រោះជា ហេតុជួបនូវផលពិសេសដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននិងខាងមុខ

ជាអ្នកដែលជន ច្រើននាក់ស្រឡាញ់រាប់អាន និងពេញចិត្ត ។ ក្នុងរឿងទាននេះ គប្បីរលឹកដល់សូត្រទាំងឡាយជាដើម យ៉ាងនេះថា ម្នាល សីហៈ ទានបតីអ្នកទាយករមែង ជាទីស្រឡាញ់ពេញចិត្តរបស់ជនជាច្រើន ។

ន័យមួយទៀត ឈ្មោះថា ទានមាន ២ គឺ អាមិសទាន និង ធម្មទាន ក្នុងទានទាំង ២ នោះ អាមិសទាន បានពោលមកហើយ ។ ចំណែកការសម្តែងធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសហើយ នាំមកនូវការអស់ទុក្ខ បានសុខក្នុងលោកនេះ និងលោកខាងមុខ ព្រោះសម្គាល់ថា នឹងផ្តល់ប្រយោជន៍ដល់អ្នកដទៃៗ ឈ្មោះថា ធម្មទាន ។ ម្យ៉ាងទៀត បណ្តាទានទាំង ២ នេះ ធម្មទាន ជាទានមួយយ៉ាងប្រសើរលើសទានទាំងពួង ដូចយ៉ាងដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ទុកថា :-

សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ
សព្វរតឹ ធម្មរតិ ជិនាតិ តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ

ប្រែថា : ការឱ្យធម៌ឈ្នះការឱ្យទាំងពួង រសនៃព្រះធម៌ឈ្នះអស់រសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ឈ្នះសេចក្តីត្រេកអរទាំងពួង ការអស់ទៅនៃតណ្ហាឈ្នះអស់ទុក្ខទាំងពួង ។

ក្នុងព្រះសូត្រនិងគាថានោះ ក៏ទ្រង់ត្រាស់សេចក្តីដែលអាមិសទាន ជាមង្គលប៉ុណ្ណោះ ចំណែកធម្មទានទ្រង់ត្រាស់ថា ជា **មង្គល** ព្រោះជាបទដ្ឋាននៃគុណទាំងឡាយ មានការជ្រួតជ្រាបនូវអត្ថជាដើម សមពិតដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកដូច្នេះថា:-

ម្នាលភិក្ខុទាំងឡាយ ភិក្ខុសម្តែងធម៌តាមដែលធ្លាប់ស្តាប់មក តាមដែលធ្លាប់រៀនមក ដោយពិស្តារដល់អ្នកដទៃ។ ដោយប្រការណា។ ភិក្ខុនោះរមែងជាអ្នកជ្រួតជ្រាបនូវអត្ថ និង ជ្រាបនូវធម៌ក្នុងធម៌នោះ ដោយប្រការនោះ។ យ៉ាងនេះជាដើម។

ការប្រព្រឹត្តិនូវកុសលកម្មបថ ១០ ឈ្មោះថា **ធម្មចរិយា** ដូចយ៉ាង ដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកយ៉ាងនេះថា ម្នាលគហបតីទាំងឡាយ ការប្រព្រឹត្តិធម៌ ការប្រព្រឹត្តិរឿយ។ មាន ៣ យ៉ាង ។ ក៏ការប្រព្រឹត្តិធម៌នោះ គប្បីជ្រាបថា ជា **មង្គល** ព្រោះជាហេតុចូលដល់លោកសួគ៌ ។ សមពិតដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា ម្នាលគហបតីទាំងឡាយ ព្រោះហេតុដែលប្រព្រឹត្តធម៌ ប្រព្រឹត្តរឿយ។ សត្វពួកខ្លះ ក្នុងលោកនេះ ខាងមុខពីសេចក្តីស្លាប់ ព្រោះកាយបែកធ្លាយ រមែងចូលដល់សុគតិសួគ៌ ។

ជនអ្នកជាប់ទាក់ទងខាងមាតាឬបិតា រហូតដល់ ៧ តំណ ដូនតា ឈ្មោះថា ញាតិ ។ ការសង្គ្រោះញាតិទាំងនោះអ្នកត្រូវ អស់ភោគៈ ព្រោះជួនកាលគ្មានជម្ងឺ ទើបរត់មករកយើងដោយ អាហារ ដោយគ្រឿងស្លៀកពាក់ និងបាយទឹក ឬអង្ករជាដើម ទ្រង់ត្រាស់ថា ជា **មង្គល** ព្រោះជាហេតុនាំឱ្យបានជួបនូវផល ពិសេសក្នុងបច្ចុប្បន្ន មានការលើកសរសើរនិងទៅខាងមុខ មាន សុគតិជាឋានសុខ ។ ការងារសុចរិតតាមផ្លូវកាយ ផ្លូវវាចា និងផ្លូវ ចិត្ត ដូចមានការសមាទានអង្គឧបោសថ ការធ្វើសេចក្តីខ្វល់ខ្វាយ ការដាំសួន ឬកសាងស្ពានជាដើម ឈ្មោះថា ការងារមិនមាន ទោស ។ ការងារមិនមានទោសទាំងនោះ ទ្រង់ត្រាស់ថា ជាមង្គល ព្រោះជាហេតុឱ្យជួបនូវប្រយោជន៍សុខច្រើនប្រការ ។ គប្បី រលឹកដល់ព្រះសូត្រទាំងឡាយដូចមានយ៉ាងនេះថា ម្នាល វិសាខា ស្ត្រី ឬបុរសខ្លះក្នុងព្រះសាសនានេះ សមាទានឧបោសថ ប្រកបដោយ អង្គ ៨ ប្រការ ខាងមុខពីសេចក្តីស្លាប់ទៅព្រោះ កាយបែកធ្លាយ គប្បីចូលដល់ជាមិត្តរបស់ទវយទេពថ្នាក់ចាតុ-ម្មហារាជិកា ដែលជាឋានៈប្រព្រឹត្តទៅបាន ។

ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់គាថានេះ ទុក ៤ មង្គល គឺ ទាន ១ ធម្មចរិយា ១ ការសង្គ្រោះញាតិ ១ ការងារមិនមានទោស ១ ដោយប្រការដូច្នេះ សេចក្តីដែលជាមង្គលទាំងនោះបានបញ្ជាក់ទុកក្នុងមង្គល នោះឯង ។

ពណ៌នាគាថាទី ៦ ថា អារតី

នឹងពណ៌នាក្នុងព្រះគាថា **អារតី វិរតី** ។ ឈ្មោះ ថា **អារមណៈ** ព្រោះលះបង់ ។ ឈ្មោះថា **វិរមណៈ** ព្រោះវៀរ ។ នយម្យ៉ាងទៀត **វេកតា** ឈ្មោះថា **វិរតិ** ព្រោះជាគ្រឿងដែលសត្វវៀរចេញ ។ បទថា **បាបា** បានដល់ ចាកអកុសល ។ ឈ្មោះថា **មជ្ជៈ** ព្រោះអត្ថថា ជាទីតាំងនៃ សេចក្តីស្រវឹង ។ ការផឹក មជ្ជៈ ឈ្មោះថា **មជ្ជបានៈ** ។ ការប្រុងប្រយ័ត្នឈ្មោះថា **សំយមៈ**។ សេចក្តីមិនប្រមាទឈ្មោះថា **អប្បមាទៈ**។ បទថា **ធម្មេសុ** បានដល់ ក្នុងកុសលទាំងឡាយ ។ ពាក្យដែលនៅសល់ មានន័យ ដូចដែលពោលហើយនោះឯង នេះជាការពណ៌នាបទ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបយ៉ាងដូច្នេះ ។ សេចក្តីមិនត្រេកអរខ្លាំងរបស់បុគ្គលអ្នកឃើញទោសក្នុងបាប ឈ្មោះថា **អារតី** ។ ការវៀរចាកផ្លូវកាយ វាចា ដោយកម្ម និងទ្វារ ឈ្មោះថា **វិរតិ** ។

តាមធម្មតា **វិរតិ** មាន ៣ គឺ សម្បត្តវិរតិ១ សមាទាន-វិរតិ១ សមុច្ឆេទវិរតិ១ ។ ក្នុងវិរតិទាំង ៣ នោះ វិរតិចេតនាវៀរចាកវត្ថុ ដែលបានជួបប្រទះនូវអ្វីណាមួយរបស់កុលបុត្រ ដោយន័យត្រង់ចំណុច ដែលយើងនឹងសម្លាប់នឹងលួចទ្រព្យ ជាដើម ពេលនឹកដល់ជាតិត្រកូល ឬគោត្ររបស់ខ្លួន ក៏មិនសមគួរដល់យើងឡើយ វិរតិចេតនាវៀរនេះឈ្មោះថា **សម្បត្តវិរតិ** ។ កុលបុត្រ មិនបានធ្វើបាបមានបាណាតិបាតជាដើម តាំងពីប្រព្រឹត្តវិរតិណាមួយ វិរតិនោះ ប្រព្រឹត្តទៅដោយសមាទានសិក្ខាបទ ឈ្មោះថា **សមាទានវិរតិ** ។ ភ័យ វេរ ៥ យ៉ាង របស់ព្រះអរិយសាវក បានស្ងប់រម្ងាប់បាត់ទៅតាំងពីប្រព្រឹត្តវិរតិណាមួយ វិរតិនោះប្រកបដោយ អរិយមគ្គ ឈ្មោះថា **សមុច្ឆេទវិរតិ** ។ បាបអកុសលនោះមាន ៤ យ៉ាង ពោលគឺកម្មកិលេសដែលព្រះដ៏-មានព្រះភាគទ្រង់ត្រាស់ទុកដោយពិស្តារយ៉ាងនេះថា ម្នាលបុត្រ

គហបតី កម្មកិលេស គឺបាណាតិបាត កម្មកិលេស គឺអទិន្នាទាន ។ល។ កម្មកិលេស គឺមុសាវាទ ដូចនេះហើយ ទ្រង់សង្ខេបទុក ដោយគាថាយ៉ាងនេះថា:-

បាណាតិបាតោ អទិន្នាទានំ មុសាវាទោ ច តុច្ឆតិ
បរទារគមនញ្ចេវ នប្បសំសន្តិ បណ្ឌិតា ។

ប្រែថា : លោកពោលកម្មកិលេស ៤ គឺ បាណាតិបាត, អទិន្នាទាន, មុសាវាទ និងការល្មើសភរិយារបស់អ្នកដទៃ, បណ្ឌិតទាំងឡាយ មិនសរសើរឡើយ ។

ការវៀរចាកបាបអកុសល ការវៀរទាំងអស់នោះ ទ្រង់ត្រាស់ថា **ជាមង្គល** ព្រោះជាហេតុជួបប្រទះនូវផលពិសេសច្រើនប្រការ មានការលះភ័យវេរា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងខាងមុខជាដើម ។ ក្នុងចំណុចនេះ គប្បីរលឹកដល់ព្រះសូត្រទាំងឡាយដោយន័យថា ម្នាលបុត្រគហបតី អរិយសាវ័កវៀរចាកបាណាតិបាតនោះឯង ។

នឹងពណ៌នា ពីការសង្រួមចាកការបរិភោគគ្រឿងស្រវឹង ពាក្យនោះជាឈ្មោះរបស់ចេតនា វៀរចាកទីតាំងនៃសេចក្តីប្រមាទ គឺ ផឹកគ្រឿងស្រវឹង បានដល់សុរា និងមេរ័យ បានពោលទុកមុនរួចហើយ ព្រោះហេតុដែលអ្នកផឹកគ្រឿងស្រវឹង រមែងមិនដឹង

អត្ថ មិនដឹងធម៌ រមែងធ្វើអន្តរាយដល់មាតាបិតា សូម្បីដល់ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និងព្រះសាវ័ករបស់ព្រះតថាគត រមែងជួបនូវការទិតៀនក្នុងភពបច្ចុប្បន្ន និងទុគ្គតិក្នុងភពខាងមុខ និងជួបនូវសភាពឆ្កួតលេលាក្នុងភពតៗ ទៅ ។ ចំណែក ការសង្រួមចាកគ្រឿងស្រវឹង រមែងសម្រេចការរម្ងាប់ទោសទាំងអស់នោះ និងការដល់ព្រមដោយគុណ ។ ដូច្នោះការសង្រួមចាកផឹក គ្រឿងស្រវឹង គប្បីជ្រាបថា **ជាមង្គល** ។

ការមិនប្រាសចាកសតិក្នុងកុសលធម៌ទាំងឡាយ ដោយអត្ថជាបដិបក្ស ដល់សេចក្តីប្រមាទ ដែលលោកពោលទុកក្នុងបាលីនេះថា ការធ្វើអ្វីៗមិនគោរព ការធ្វើមិនញឹកញាប់ ការធ្វើមិនមាំទាំ ការប្រព្រឹត្តិតិចតួចឬស្ទាក់ស្ទើរ ការខ្វះឆន្ទៈ ការមិនរីរវល់ ការមិនសេព ការមិនចម្រើន ការមិនធ្វើឱ្យច្រើន ការមិនតាំងចិត្ត ការមិនប្រកបរឿយៗ ការមិនប្រុងប្រយ័ត្នក្នុងការអប់រំកុសលធម៌ទាំងឡាយ ការប្រមាទ សេចក្តីធ្វេសប្រហែស ភាពជាអ្នកមិនប្រយ័ត្ន ឃើញដូចយ៉ាងនេះ ហៅថាប្រមាទ ។ ឈ្មោះថា ការមិនប្រមាទក្នុងកុសលធម៌ទាំងឡាយ សេចក្តីមិនប្រមាទក្នុងកុសលធម៌នោះ ទ្រង់ត្រាស់ថា ជា **មង្គល**

ព្រោះជាហេតុជួបនូវកុសលច្រើនប្រការ និងបានសម្រេចអមតធម៌ ។ ក្នុងចំណុចនោះ គប្បីរលឹកដល់ពាក្យទូន្មានរបស់ព្រះសាស្តាយ៉ាងនេះថា អ្នកមិនប្រមាទ អ្នកមានសេចក្តីព្យាយាម នឹងថាសេចក្តីមិនប្រមាទ ជាអមតបទដូច្នេះ ។

ព្រះដ៏មានជាម្ចាស់ទ្រង់ត្រាស់ព្រះគាថានេះទុក ៣ មង្គល គឺ ការវៀរចាកបាប១ ការសង្រួមចាកការផឹកគ្រឿងស្រវឹង ១ ការមិនប្រមាទក្នុងកុសលធម៌ ១ ដោយប្រការដូច្នេះ ។

ពណ៌នាគាថាទី ៧ ថា តារវោ ច

នឹងពណ៌នា ក្នុងគាថា ថា តារវោ ច នេះ ។ បទថា តារវោ បានដល់ ភាពជាអ្នកធ្ងន់ (ការណ៌) ។ បទថា និវាតោ បានដល់ ការប្រព្រឹត្តិបន្ទាបខ្លួន ។ បទថា (សន្តុដ្ឋី) ប្រែថា សេចក្តីសន្តោស ។ ការដឹងឧបការគុណដែលលោកធ្វើទុក ឈ្មោះថា **កតញ្ញុតា** ។ បទថា កាលេន ប្រែថា ខណៈសម័យ ។ ការស្តាប់ធម៌ឈ្មោះ ធម្មស្សវនៈ ពាក្យដែលនៅសល់មានន័យដូចពោលមកហើយនោះឯង នេះជាការពណ៌នាបទ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបយ៉ាងដូចនេះ ។

ការគោរព ការធ្វើសេចក្តីគោរព ភាពជាអ្នកមានសេចក្តីគោរពតាមសមគួរក្នុងព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ ព្រះសាវ័ករបស់ព្រះតថាគត អាចារ្យ ឧបជ្ឈាយ៍ មាតាបិតា បងប្រុស បងស្រីជាដើម ជាអ្នកគួរ ប្រកបសេចក្តីគោរពឈ្មោះថា **គារវៈ** ។ គារវៈនោះជាហេតុនាំទៅសុគតិជាដើម ដូចយ៉ាងដែលទ្រង់ត្រាស់ទុកថា :-

បុគ្គលធ្វើសេចក្តីគោរពចំពោះអ្នកដែលគួរគោរព សក្ការៈដល់អ្នកដែលគួរសក្ការៈ រាប់អានអ្នកដែលគួររាប់អាន បូជាអ្នកដែលគួរបូជា ព្រោះកម្មនោះ ដែលប្រកាន់ទុកបរិបូរយ៉ាងនេះ ខាងមុខពីសេចក្តីស្លាប់ទៅព្រោះកាយបែកធ្លាយ គេរមែងចូលដល់សុគតិលោកសួគ៌ ប្រសិនបើគេមិនចូលដល់សុគតិលោកសួគ៌ គេក៏មកកើតជាមនុស្ស នឹងជាអ្នកមានត្រកូលខ្ពង់ខ្ពស់ក្នុងប្រទេសយ៉ាងដូច្នេះ ដូចដែលទ្រង់ត្រាស់ទុកយ៉ាងនេះថា :-

ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីតាំងនៃសេចក្តីមិនវិនាស ៧ ប្រការ តើធម៌ ៧ ប្រការទាំងនោះយ៉ាងដូចម្តេច? ធម៌ ៧ ប្រការ ភាពជាអ្នកមានសេចក្តីគោរពក្នុងព្រះសាស្តា ដូច្នេះជាដើម ទើបត្រាស់ថា ជាមង្គល ។

ភាពជាអ្នកមានការប្រព្រឹត្តិបន្ទាបខ្លួន និងមានចិត្តមិនភ្លើតភ្លើន ឈ្មោះថា ជាអ្នកបន្ទាបខ្លួន ។ បុគ្គលប្រកបដោយការបន្ទាបខ្លួនយ៉ាងណា បានដល់ កម្ចាត់មានះបាន កម្ចាត់ភាពរឹងត្អឹងបាន ទុកដូចជាសំពត់ជូតជើង ស្មើដោយគោឧសភអត់ស្នែង ដូចសត្វពស់ដកចង្កូមហើយ រមែងជាអ្នកល្អិតល្អន់ បរិសុទ្ធស្អាតដោយសុខភាព ជាអ្នកបន្ទាបខ្លួន ជាអ្នកស្ងាត់ស្ងៀមស្លូតបូត សភាពស្លូតបូតនេះទ្រង់ត្រាស់ថា ជា **មង្គល** ព្រោះជាហេតុបានគុណ មានយសជាដើម ។ ម្យ៉ាងទៀតទ្រង់ត្រាស់ថា អ្នកមានការបន្ទាបខ្លួន មិនរឹងធ្អឹង អ្នកនោះរមែងជាអ្នកមានយស ។

ការសន្តោសដោយបច្ច័យតាមមាន តាមបាន (បច្ច័យ៤) ឈ្មោះថា សន្តុដ្ឋី ។ សន្តោសនោះមាន ១២ យ៉ាងគឺ ក្នុងចីវរ ៣ យ៉ាង គឺ យថាលាភសន្តោស (សន្តោសតាមមាន) យថាពលសន្តោស (សន្តោសតាមកម្លាំង) យថាសារុប្បសន្តោស (សន្តោសតាមសមគួរ) ។ ក្នុងបិណ្ឌបាតជាដើមយ៉ាងនេះ ។

នឹងពណ៌នាពីប្រភេទសន្តោសដូចតទៅនេះ :-

ភិក្ខុក្នុងធម្មវិន័យនេះ បានចីវរល្អ ឬមិនល្អ ភិក្ខុនោះក៏ញុំាងអត្តភាព ឱ្យប្រព្រឹត្តទៅដោយចីវរនោះ មិនប្រាថ្នាចីវរដទៃ ប្រសិនបើបានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងចីវររបស់ភិក្ខុនោះ ។

មួយទៀត ភិក្ខុអាពាធពេលត្រងចីវរធ្ងន់ រមែងបង្អោនខ្លួនចុះឬលំបាក ទើបប្តូរចីវរនោះជាមួយភិក្ខុដែលប្រើចីវរស្រាលវិញ ដើម្បីញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងចីវរនោះ ក៏ជាអ្នកសន្តោស នេះឈ្មោះថា **យថាពលសន្តោស** ក្នុងចីវររបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត ជាអ្នកបានបច្ច័យប្រណីត បានចីវរល្អជាដើមយ៉ាងណាមួយដែលមានតម្លៃច្រើន ហើយគិតថា ចីវរនេះសមគួរដល់ព្រះថេរៈអ្នកបួសយូរនិងពហុស្សុត ទើបប្រគេនចីវរ ដល់ព្រះភិក្ខុនោះ ចំណែកខ្លួនឯងវិសេសយកសំពត់សេសសល់ពីគំនរសំរាម ឬពីទីដទៃៗទៀត សម្រាប់ធ្វើសង្ឃាដីទុកត្រង ក៏ជាអ្នកសន្តោស ឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងចីវររបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានបិណ្ឌបាតសៅហ្មង ឬប្រណីត ក៏អាចញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងបិណ្ឌបាតនោះ

មិនប្រាថ្នាបិណ្ឌបាតដទៃទៀត សូម្បីពេលបានក៏មិនទទួល នេះ ឈ្មោះថា **យថាលាភសន្តោស** ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុអាពាធឆាន់ចង្ហាន់បិណ្ឌបាតសៅហ្មង រោគនិងកម្រើកខ្លាំង ទើបប្រគេនចង្ហាន់បិណ្ឌបាតនោះដល់ភិក្ខុ ដទៃ ហើយត្រូវឱ្យឆាន់ប្រេង ទឹកឃ្មុំ និងទឹកដោះគោស្រស់ជា ដើមវិញ សូម្បីធ្វើសមណធម៌ ក៏ជាអ្នកសន្តោស នេះជា **យថាពលសន្តោស** ក្នុង បិណ្ឌបាតរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត សេនាសនៈមកដល់ភិក្ខុក្នុងធម្មវិន័យនេះ អ្នក សន្តោសដោយសេនាសនៈនោះឯង មិនទទួលសេនាសនៈដទៃ សូម្បីល្អជាងដែលទើបមកដល់ថ្មីទៀតយ៉ាងណា នេះឈ្មោះថា **យថាលាភសន្តោស** ក្នុង សេនាសនៈរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានភេសជ្ជៈមិនថាផ្លែ សម៉ ឬផ្លែកន្ធតព្រៃ សម្រាប់ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅដោយ ភេសជ្ជនោះ មិនប្រាថ្នាភេសជ្ជៈដទៃ មានទឹកដោះថ្លា ទឹកឃ្មុំ ឬ ទឹកអំពៅជាដើម សូម្បីពេលបានអ្វីៗដទៃទៀត ក៏មិនទទួលដែរ នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងគិលានប្បច្ច័យរបស់ភិក្ខុ នោះ ។

សន្តោសទាំងអស់ មានប្រភេទយ៉ាងនេះហៅថា សន្តុដ្ឋី ។ សន្តោសនោះគប្បីជ្រាបថា ជា **មង្គល** ព្រោះជាហេតុជួបនូវការលះបាបធម៌ទាំងឡាយ ដែលមានសេចក្តីប្រាថ្នា លើសពីចំណែករបស់ខ្លួន និងសេចក្តីលោភ ព្រមទាំងប្រាថ្នាលាមកជាដើម ព្រោះជាហេតុនៃ សុគតិនិងជាហេតុនៃគ្រឿងអប់រំអរិយមគ្គ ទាំងជាហេតុនៃភាពជាអ្នករស់នៅដោយសប្បាយក្នុងទិសទាំង ៤ ដូចដែល ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា :-

ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ

សន្តុស្សមានោ តីតីរតរេន ។

ប្រែថា : អ្នកសន្តោសដោយបច្ច័យតាមមានតាមបាន រមែងជាអ្នករស់នៅដោយសប្បាយក្នុងទិសទាំង ៤ ហើយក៏មិនមានបដិឃៈដូច្នោះជាដើម ។

ការដឹងនូវឧបការគុណ ដែលបុគ្គលណាមួយបាន ធ្វើហើយមិនថាច្រើន ឬតិចដោយការរលឹកឿយៗ ឈ្មោះថា **កតញ្ញូតា** ។ ម្យ៉ាងទៀត បុណ្យទាំងឡាយ មានឧបការៈច្រើនដល់សត្វទាំងឡាយ ព្រោះជួយការពារនូវទុក្ខមានទុក្ខក្នុងនរកជាដើម ដូច្នោះ ការរលឹកដល់ឧបការៈរបស់បុណ្យទាំងនោះ គប្បីជ្រាបថា

ជា **កតញ្ញូតា** ។ កតញ្ញូតានោះទ្រង់ត្រាស់ថា ជា **មង្គល** ព្រោះជាហេតុជួបនូវផលវិសេសដោយប្រការផ្សេងៗ មានសប្បុរសទាំងឡាយគប្បីសរសើរជាដើម ទាំងព្រះដ៏មានព្រះភាគជាម្ចាស់ក៏ទ្រង់ត្រាស់ទុកថា :-

ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ជំពូកទាំងនេះ រកបានដោយកម្រក្នុងលោកគឺ **បុព្វការី ១ កតញ្ញូកតវេទី ១** ។

ការស្តាប់ធម៌ ដើម្បីបន្ទោបង់វិតក្កៈក្នុងកាលដែលចិត្តប្រកបដោយឧទ្ធច្ចៈ ឬចិត្តត្រូវវិតក្កៈទាំងឡាយ មានកាមវិតក្កៈជាដើមយ៉ាងណាមួយគ្របសង្កត់ ឈ្មោះថា ការស្តាប់ធម៌ តាមកាល ។ អាចារ្យមួយពួកទៀតពោលថា ការស្តាប់ធម៌គ្រប់ ៥ ថ្ងៃ ឈ្មោះថា ការស្តាប់ធម៌តាមកាល ដូចយ៉ាងដែលលោកពោលថា ព្រះអនុរុទ្ធ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គ អង្គុយប្រជុំគ្នាដោយធម៌ មានកថាពេលយប់ញុំាងដល់ពេលព្រឹក គ្រប់ៗ ៥ ថ្ងៃ ។

ម្យ៉ាងទៀត ក្នុងកាលណា ភិក្ខុចូលទៅរកកល្យាណមិត្តហើយ អាចស្តាប់ធម៌ដើម្បីបន្ទោបង់សេចក្តីសង្ស័យរបស់ខ្លួនចេញបាន ការស្តាប់ធម៌នោះ គប្បីជ្រាបថា ការស្តាប់ធម៌តាមកាល ដូចយ៉ាងដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា ភិក្ខុ

ចូលទៅរកកល្យាណមិត្តទាំងនោះ សាកសួរដេញដោលរហូតកាលតាមកាល ។ ការស្តាប់ធម៌តាមកាលនោះ ហៅថា ជា **ឧត្តល** ព្រោះជាហេតុជួបនូវផលវិសេសច្រើនប្រការ មានការលះនីវរណៈត្រូវបានអានិសង្ស ៤ និងសម្រេចធម៌ជាទីអស់អាសវៈជាដើម សមពិត ដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ទុកដូច្នេះថា :-

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ព្រះអរិយសាវ័កដាក់ចិត្តធ្វើឱ្យជាប្រយោជន៍ រួបរួមគ្រប់យ៉ាងទុកដោយចិត្ត ផ្ទៀងសោតៈស្តាប់ធម៌ ក្នុងសម័យនោះ និវរណៈ ៥ របស់ព្រះអរិយ-សាវ័កទាំងនោះ រមែងមិនមាន ហើយពោលថា :-

ម្នាលភិក្ខុទាំងឡាយ គប្បីប្រាថ្នាអានិសង្ស ៤ ប្រការ នៃធម៌ទាំងឡាយដែលទម្លាប់សោតៈ (ត្រង់ក្បៀក) ។ល។ ដែលចាក់ធ្លុះដោយល្អ ហើយពោលថា :-

ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ទាំងនេះ ដែលភិក្ខុអប់រំដោយប្រពៃ វិលជុំវិញទៅដោយប្រពៃ តាមកាល រមែងដល់ធម៌ជាទីអស់អាសវៈដោយលំដាប់ធម៌ ៤ ប្រការនោះគឺ ការស្តាប់ធម៌តាមកាលយ៉ាងនេះជាដើម ។

ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់គាថានេះ ទុក ៥ មង្គល គឺ សេចក្តីគោរព ១ ការបន្ទាបខ្លួន ១ ការសន្តោស ១ កតញ្ញូតា ១ និងការស្តាប់ធម៌តាមកាល ១ ដោយប្រការដូច្នេះ ។

ពណ៌នាគាថាទី ៨ ថា ខន្តី ច

នឹងពណ៌នាក្នុងគាថា ថា ខន្តី ច ។ សេចក្តីអត់ធន់ឈ្មោះ ថា ខន្តី ។ ឈ្មោះថា **សុវចៈ** មានសេចក្តីប្រដៅងាយ ជាអ្នក ប្រកាន់យកស្តាំ កម្មរបស់អ្នកប្រដៅងាយ ឈ្មោះថា **សោវចស្សតា** ។ ឈ្មោះថា **សមណៈ** ព្រោះ រម្ងាប់កិលេសទាំងឡាយបាន ។ បទថា **ឧស្សុនំ** បានដល់ ការសម្លឹងមើល ។ ការសន្ទនា ធម៌ ឈ្មោះថា **ធម្មសាកច្ឆា** ។ ពាក្យដែលនៅសល់ក៏មានន័យ ដែល ពោលមកហើយនោះឯង នេះជាការពណ៌នាបទ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូចនេះ ។

អធិវាសនខន្តី ឈ្មោះថា ខន្តី ដែលភិក្ខុអ្នកប្រកបដោយ ខន្តីនោះហើយ មិនមានអាការខុសប្រក្រតីដូចអ្នកមិនបានត្រេក អរនឹងបុគ្គលដែលជេរដោយអក្កោសវត្ថុ ១០ នឹងមិនឃើញ

បុគ្គលអ្នកប្រែតប្រែនដោយការសម្លាប់ និងការចងចាំជាដើម ដូចខន្តីវាទីតាបស ដូច្នោះព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា :-

អហុ អតីតមទ្ធានំ សមណោ ខន្តិទីបនោ

តំ ខន្តិយាយេវ ទិតំ កាសិរាជា ឯឆេទយិ ។

ប្រែថា : សមណៈ អ្នកសម្តែងខន្តី បានមានមកហើយ ក្នុងអតីតកាល ព្រះបាទកាសី បានទ្រង់បំផ្លាញសមណៈអ្នកតាំងនៅក្នុងខន្តីនោះឯង ឬរមែងដាក់ចិត្តថាគេធ្វើល្អហើយ ព្រោះមិនមានការខុសឆ្គងជាងនេះ ដូចព្រះបុណ្ណថេរៈ យ៉ាងដូច្នោះដែល លោកក្រាបទូលថា :-

បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើប្រជាជនសុនាបរន្តកៈនឹងជេរបរិភាស ខ្ញុំព្រះអង្គយ៉ាងណា ក្នុងប្រការនោះ ខ្ញុំព្រះអង្គនឹងដាក់ចិត្តថា ប្រជាជនសុនាបរន្តកៈទាំងនេះ ជាអ្នកចម្រើនហ្ន៎ អ្នកសុនាបរន្តកៈទាំងនេះជាអ្នកចម្រើនល្អហើយ អ្នកទាំងនេះមិនល្អព្រោះវាយខ្ញុំព្រះអង្គដោយដៃ ដូច្នេះជាដើម ហើយភិក្ខុដែលប្រកបដោយខន្តីនោះ រមែងជាអ្នកដែលសូម្បីពួកឥសី ទាំងឡាយគប្បីសរសើរ ដូចយ៉ាងសរភង្គឥសី ពោលទុកថា :-

ភោធំ ទធិត្វា ន កទាចិ សោចតិ

មក្ខប្បហានំ ឥសយោ វណ្ណយន្តិ

សព្ពេសំ ភុត្តំ ផរុសំ ខមេថ

ឯតំ ខន្តិ ខុត្តម្ហាហុ សន្តោ ។

ប្រែថា : អ្នកសម្លាប់សេចក្តីក្រោធបាន រមែងមិនសៅសោក ក្នុងកាលណា ឥសីទាំងឡាយ រមែងសរសើរការលះនូវការមើលងាយ ។ អ្នកគួរអត់ធន់ នូវពាក្យទាំងឡាយ ដែលអ្នកទាំងពួងពោលហើយ សប្បុរសទាំងឡាយសរសើរខន្តីនោះថា ខ្ពស់បំផុត រមែងជាអ្នកដែលទេវតាទាំងឡាយ ក៏សរសើរ ដូចយ៉ាងសក្កៈកំពូលទេពត្រាស់ទុកថា :-

យោ ហវេ ពលវា សន្តោ ទុព្ពលស្ស តិតិក្ខតិ

តមាហុ បរមំ ខន្តិ និច្ចំ ខមតិ ទុព្ពលោ ។

ប្រែថា : អ្នកណាជាអ្នក អត់ធន់ដល់អ្នកទន់ខ្សោយ សប្បុរសទាំងឡាយ សរសើរខន្តីរបស់អ្នកនោះថា ជាកំពូល ព្រោះអ្នកទន់ខ្សោយត្រូវមានការអត់ធន់ជាប្រចាំ រមែងជាអ្នកដែលព្រះពុទ្ធទាំងឡាយគប្បីសរសើរ ដូចជាទ្រង់ត្រាស់ទុកថា :-

អក្កោសំ វធពន្ធញ្ច អទុដ្ឋោ យោ តិតិក្ខតិ

ខន្តិពលំ ពលាណីកំ តមហំ ព្រូមិ ព្រាហ្មណំ ។

ប្រែថា : អ្នកណាមិនក្រោធ អត់សង្កត់ការដេរ ការសម្លាប់ និងការចងចាំបាន យើងហៅអ្នកនោះ ថាមានខន្តីជាកម្លាំង មានកងកម្លាំង ថា ជាព្រាហ្មណ៍ ។ ឯ ខន្តីនោះ គប្បីជ្រាបថា **ជាមង្គល** ព្រោះជាហេតុជួបនូវគុណទាំងនោះ និងគុណដទៃៗ ដែលទ្រង់សរសើរក្នុងទីនេះ ។

ពេលត្រូវសព្រហ្មចារីពោលធម៌ ក៏មិនរវើរវាយភាន់ភាំង ឬគិតដល់គុណនិងទោស ការសង្គ្រោះ ការគោរព និងមានចិត្តអន់ថយទៅខាងមុខ ទើបថ្លែងវាចាថា ល្អណាស់ណាសូមទទួលដូច្នេះឈ្មោះ **សោវចស្សតា** (ការប្រដៅងាយ) ។ សោវចស្សតានោះទ្រង់ត្រាស់ថា **ជាមង្គល** ព្រោះជាហេតុទទួលបាននូវឱវាទ និងអនុសាសន៍ពីសម្ដាក់សព្រហ្មចារីទាំងឡាយ និងព្រោះជាហេតុលះទោស និងសម្រេចគុណ ។

◈ ការចូលទៅបម្រើ ការរលឹក ការស្ដាប់ និងការឃើញអ្នកបួសទាំងឡាយរម្ងាប់កិលេសហើយ អប់រំកាយវាចាចិត្ត និងបញ្ញាប្រកបដោយសេចក្ដីស្ងប់យ៉ាងខ្ពស់ ឈ្មោះថា ការឃើញ

សមណៈទាំងឡាយ ។ ការឃើញសមណៈ លោកពោលថា **ឧស្សនៈ** ដោយទេសនាយ៉ាងពីរោះជក់ចិត្ត ។ ការឃើញសមណៈនោះ គប្បីជ្រាបថា **ជាមង្គល** ព្រោះជាហេតុនាំឱ្យមានឧបការៈច្រើន ។ សេចក្តីពិត ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ យើងពោលថា ការឃើញភិក្ខុទាំងនោះ មានឧបការៈច្រើន ព្រោះបុណ្យដែលកុលបុត្រអ្នកត្រូវការប្រយោជន៍ ។ លុះឃើញភិក្ខុទាំងឡាយ អ្នកមានសីលនិមន្តមកដល់មាត់ទ្វារផ្ទះ ប្រសិនបើមានទេយ្យធម៌ គប្បីគោរពទេយ្យធម៌តាមកម្លាំង ប្រសិនបើមិនមាន គប្បីសំពះដោយបញ្ចង្គប្រតិស្ឋ ធ្វើអញ្ជលីនមស្ការ ដោយចិត្តជ្រះថ្លា សម្លឹងមើលគួរស្រឡាញ់ ។ ដោយបុណ្យ ដែលមានការសម្លឹងមើលជាមួលយ៉ាងនេះ រោគឬទោស ឬអាចម៍ភ្នែកនឹងមិនមានក្នុងចក្ខុរហូតច្រើនពាន់ជាតិ ។ ចក្ខុទាំងពីរ នឹងថ្លាផូរផង់ មានសីរីមានវណ្ណៈ ៥ ដូចទ្វារកែវមណីក្នុង រតនវិមាន គេនឹងបានសម្បត្តិក្នុងទេវតា និងមនុស្សប្រមាណសែនកប្ប បានកើតជាមនុស្សក៏ជាអ្នកមានបញ្ញា ដោយបុណ្យសម្រេចមកពីការឃើញ សមណៈដែលគេប្រព្រឹត្តមកដោយប្រពៃ ហើយក៏មិនគួរអស្ចារ្យ ដែរ

សម្រាប់ពួកសត្វតិរច្ឆាន ។ បណ្ឌិតទាំងឡាយ ពណ៌នានូវ
វិបាកសម្បត្តិ របស់ការឃើញព្រះសង្ឃ ត្រឹមធ្វើសទ្ធាឱ្យកើត
ឡើងទុកយ៉ាងនេះ ក្នុងបាលីប្រទេសណា បាលីប្រទេសនោះ មាន
ថា :-

កូនសត្វស្លាបនៅហាលខ្យល់ អាស្រ័យនឹងទីវេទិយកបពិត
អស់កាលយូរអង្វែង កូនសត្វស្លាបនេះសុខពិតប្រាំ លុះឃើញ
ព្រះពុទ្ធដ៏ប្រសើរទើបភ្ញាក់ឡើងពីព្រលឹម ។

ខ្ញុំធ្វើចិត្តឱ្យជ្រះថ្លា ចំពោះព្រះភិក្ខុសង្ឃដ៏កំពូល នឹងមិន
ធ្លាក់ទៅក្នុងទុគតិដល់ ១ សែនកប្ប ខ្ញុំចុតិចាកទេវលោកដែល
កុសលកម្មដាស់តឿនហើយ នឹងបានជាព្រះបច្ចេកពុទ្ធ អ្នកមាន
អនន្តញ្ញាណប្រាកដ ព្រះនាមថា សោមនស្សៈ ដូច្នោះ ។

ក្នុងវេលាព្រលប់រនោច ឬព្រលឹមស្រាងៗ ភិក្ខុទ្រទ្រង់នូវ
ព្រះសូត្រ ២ រូប រមែងសន្ទនាព្រះសូត្រគ្នា ចំណែកខាងព្រះវិន័យ
ក៏សន្ទនាព្រះវិន័យគ្នា ចំណែកខាងព្រះអភិធម្ម ក៏សន្ទនាព្រះអភិ-
ធម្មគ្នា ចំណែកខាងជាតក ក៏សន្ទនាជាតកគ្នា ចំណែកខាង
ព្រះអដ្ឋកថា ក៏សន្ទនាអដ្ឋកថាគ្នា ឬសន្ទនាគ្នាក្នុងកាលនោះៗ
ដើម្បីជម្រះចិត្តដែលត្រូវសេចក្តីរួញរា សេចក្តីរវើរវាយសង្ស័យ
នាំទៅ ការសន្ទនាតាមកាលនេះ ឈ្មោះថា ការសន្ទនាធម៌តាម

កាល ដោយទ្រង់ត្រាស់ថា ជា **មង្គល** ព្រោះជាហេតុនៃគុណទាំងឡាយមានការឆ្លាតក្នុងអាគម គឺ និកាយទាំង ៥ ជាដើម ។

ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ ព្រះគាថានេះទុក ៤ មង្គលគឺ សេចក្តីអត់ធន់ ១ ភាពជាអ្នកប្រដៅងាយ ១ ការឃើញសមណៈ ១ និងការសន្ទនាធម៌តាមកាល ១ ដោយប្រការដូច្នេះ ។

ពណ៌នាគាថាទី ៩ ថា តតោ ច

នឹងពណ៌នាក្នុងគាថា តតោ ច នេះ ។ ឈ្មោះថា **តបៈ** ព្រោះដុតបាបធម៌ ការប្រព្រឹត្តទំនងព្រហ្ម ឬការប្រព្រឹត្តរបស់ព្រហ្មឈ្មោះថា ព្រហ្មចារ្យ អធិប្បាយថា ការប្រព្រឹត្តយ៉ាងប្រសើរ ។ ការឃើញអរិយសច្ចៈទាំងឡាយឈ្មោះថា អរិយ-សច្ឆាន ទស្សនំ ។ អាចារ្យពួកខ្លះពោលថា **អរិយសច្ឆានិ ឧស្សនំ** ដូច្នេះក៏មាន ។ ឈ្មោះថា និព្វាន ព្រោះចេញចាកវានៈគឺ តណ្ហា គ្រឿងដោតក្រង ។ ការធ្វើឱ្យជាក់ច្បាស់ឈ្មោះថា សច្ឆិកិរិយា ។ ការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានឈ្មោះថា និព្វានសច្ឆិកិរិយា ។ ពាក្យដែលនៅសល់ មានន័យដូចពោលមកហើយនោះឯង នេះជាការពណ៌នាបទ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូចនេះ ។

ឥន្ទ្រិយសំវរៈ ឈ្មោះថា តបៈ ព្រោះដុតអភិជ្ឈា និងទោមនស្ស ឬសេចក្តីព្យាយាម ឈ្មោះថា តបៈ ព្រោះដុតការខ្ជិលច្រអូស ។ បុគ្គលអ្នក ប្រកបដោយតបៈទាំងនោះ លោកហៅថា អាតាបី ។ តបៈនោះ គប្បីជ្រាបថា **ជាមគ្គលៈ** ព្រោះជាហេតុលះអភិជ្ឈា និងបាន ឈានជាអាទិ៍ ។

ឈ្មោះថា ព្រហ្មចារ្យជាឈ្មោះរបស់ មេថុនវិរតិ សមណធម៌ សាសនា និងមគ្គ។ ការពិត មេថុនវិរតិ លោកហៅថា ព្រហ្មចារ្យ បានក្នុងប្រយោគជាដើមថា **ព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ** ប្រែថា : លះមេថុនវិរតិ ជាព្រហ្មចារីយ៍ ។ សមណធម៌ ហៅថា ព្រហ្មចារីយ៍ បានក្នុងប្រយោគជាដើមយ៉ាងនេះថា **ភគវតិ នោ អាវុសោ ព្រហ្មចរិយំ វុស្សតិ** ប្រែថា: យើងប្រព្រឹត្តសមណធម៌ក្នុងសម្ពាក់ព្រះដ៏មានព្រះភាគជាម្ចាស់ ។

សាសនា ហៅថា ព្រហ្មចារ្យ បានក្នុងប្រយោគជាដើមយ៉ាងនេះថា **ន តាវាហំ ជាមិម បរិនិព្វាយិស្សាមិ យាវ មេ ឥទំ ព្រហ្មចរិយំ ន ឥទ្ធញ្ចេវ ភវិស្សតិ**

ជិតញ្ជា ទិត្ថារិកំ ពាហុឧញ្ញំ ប្រែថា : ម្នាលមារ ដរាបណា សាសនារបស់យើងនៅមិនទាន់ចម្រើនតាំងមាំចាក់ឬសផ្សាយ ទូលំទូលាយដឹងដល់មនុស្សច្រើនគ្នា យើងក៏នឹងមិនទាន់បរិនិញ្ចានដរាបនោះ ។

មគ្ត ហៅថា ព្រហ្មចារ្យ បានក្នុងប្រយោគជាដើមថា **អយមេវ ខោ ភិក្ខុ អរិយោ អដ្ឋង្គិកោ មគ្គោ ព្រហ្មចរិយំ សេយ្យថីទំ សម្មាទិដ្ឋិ** ប្រែថា : ម្នាលភិក្ខុ ទាំងឡាយ អរិយមគ្គមានអង្ត ៨ គឺ សម្មាទិដ្ឋិជាដើម ជា ព្រហ្មចារ្យ ។ ប៉ុន្តែក្នុងទីនេះ ព្រហ្មចារ្យគ្រប់យ៉ាង រមែងគួរ ព្រោះមគ្តលោកសង្ត្រោះដោយ អរិយសច្ចានទស្សនៈខាងមុខ ហើយ ក៏ព្រហ្មចារ្យនោះ គប្បីជ្រាបថា ជា **មន្តល** ព្រោះជា ហេតុជួបប្រសព្ធផលវិសេសច្រើនប្រការដល់ថ្នាក់ខ្ពស់ៗ ។

ការឃើញមគ្ត ព្រោះត្រាស់ដឹងនូវអរិយសច្ចៈ៤ ដែល ពោលទុកហើយក្នុងកុមារបញ្ហា ឈ្មោះថា អរិសច្ចានទស្សនៈ ។ អរិយសច្ចានទស្សនៈនោះ ទ្រង់ត្រាស់ថា ជា **មន្តល** ព្រោះជា ហេតុឆ្លងផុតទុក្ខក្នុងសង្សារវដ្ត ។

អរហត្តផល លោកប្រាថ្នាយកព្រះនិព្វាន ក្នុងទីនេះឈ្មោះថា និព្វានសច្ឆិកិរិយា គឺការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ការពិត អរហត្តផល លោកពោលថា និព្វាន ព្រោះចេញចាកតណ្ហាដែលយល់ថា វានៈ ព្រោះដោតក្រងទុកក្នុងគតិ ៥ ។ ការដល់ ឬការពិចារណាព្រះនិព្វាន ហៅថា សច្ឆិកិរិយា ប៉ុន្តែការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានខាងក្រៅនេះ សម្រេចពីការឃើញអរិយសច្ចៈ ៤ នោះឯង ។ ដោយហេតុនោះ គប្បីជ្រាបថា ជា **មង្គល** ព្រោះជាហេតុរស់នៅបានសុខ ក្នុងបច្ចុប្បន្នជាដើមដោយប្រការដូច្នោះ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់គាថានេះទុក ៤ មង្គល គឺ តបៈ ១ ព្រហ្មចរិយា ១ អរិយសច្ចានទស្សនៈ ១ និងនិព្វានសច្ឆិកិរិយា ១ ដោយប្រការដូច្នោះ ។

ពណ៌នាគាថាទី ១០ ថា ផុដ្ឋស្ស លោកធម្មេហិ

នឹងពណ៌នាក្នុងគាថា **ផុដ្ឋស្ស លោកធម្មេហិ** ។ បទថា **ផុដ្ឋស្ស** បានដល់ ត្រូវហើយ ជួបប្រទះហើយ ។ ធម៌ទាំងឡាយក្នុងលោក ឈ្មោះថា លោកធម៌ អធិប្បាយថា ធម៌ទាំងឡាយនឹងមិនវិលត្រឡប់ជាដរាប នៅតែធ្វើដំណើរទៅមុខជានិច្ច ។

បទថា **ចិត្តំ** បានដល់ មនោ មានស ។ បទថា យស្ស បានដល់ របស់ភិក្ខុថ្មី ភិក្ខុវ័យកណ្តាល ឬភិក្ខុអ្នកជាថេរៈ ។ បទថា **ន កប្បតិ** បានដល់ មិនញាប់ញ័រមិនកម្រើក ។ បទថា **អសោកំ** បានដល់ គ្មានសេចក្តីសោក ដកការសោកសៅចេញ ។ បទថា **វិរជំ** បានដល់ ប្រាសចាកលំអងកិលេស កម្ទាត់លំអងកិលេសហើយ ។ បទថា **ខេមំ** បានដល់ មិនមានភ័យ គ្មានឧបទ្ទវៈ ។ ពាក្យដែលនៅសល់មានន័យ ដែលពោលទុកហើយ នេះជាការពណ៌នាបទ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូចនេះ ។

ចិត្តរបស់អ្នកណាដែលលោកធម៌ ៨ មាន គឺមានលាភ ឥតលាភ ជាដើម ត្រូវគ្របសង្កត់ហើយ រមែងមិនញាប់ញ័រ មិនកម្រើក ឈ្មោះថា ចិត្តរបស់អ្នកនោះ គប្បីជ្រាបថា ជា **មង្គល** ព្រោះនាំមកនូវភាព ជាអ្នកខ្ពស់បំផុតលើលោកដែលធម៌អ្វីៗ មិនញាប់ញ័របាន ។

សួរថា ចិត្តរបស់អ្នកណា ត្រូវលោកធម៌ទាំងនោះពាល់ត្រូវហើយ មិនញាប់ញ័រ ឆ្លើយថា ចិត្តរបស់ព្រះអរហន្តខីណាស្រព

មិនមែនចិត្តរបស់អ្នកដទៃណាឡើយ ។ សេចក្តីពិត ព្រះដ៏មាន-ព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកដូច្នេះថា :-

សេលោ យថា ឯកគ្ឃនោ ទាតេន ន សមីរតិ
ឯវំ រូបា រសា សទ្ទា គន្ធា ផស្សា ច កេវលា
ឥដ្ឋា ធម្មា អនិដ្ឋា ច នប្បវេធេន្តិ តាទិនោ
ឋិតំ ចិត្តំ វិប្បមុត្តំ វយញ្ចស្សានុបស្សតិ ។

ប្រែថា : ភ្នំថ្មតាន់ រមែងមិនញាប់ញ័រដោយខ្យល់យ៉ាងណា រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម៌ទាំងអស់ទាំងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ រមែងធ្វើចិត្តអ្នកតាំងមាំ មិនឱ្យញាប់ញ័របានក៏យ៉ាងដូច្នោះ ដោយថាចិត្តរបស់លោកដែលតាំងមាំរួចផុតហើយ រមែងឃើញការវិនាសទៅរឿយៗ ។

ចិត្តរបស់ព្រះខីណាស្រពនោះ ឈ្មោះថា អសោកៈ គឺមិនសោកសៅ ។ ការពិត ចិត្តរបស់ព្រះខីណាស្រព ឈ្មោះថា អសោកៈ ព្រោះមិនមានសេចក្តីសោកសៅ ក៏លោកពោលដោយន័យជាដើមថា សេចក្តីសោកសៅ ភាពជាអ្នកសោកសៅ ការស្ងួតក្រៀមក្រំចិត្ត ការស្ងួតក្រៀមក្រំខាងក្នុង ការដែលត្រូវសេចក្តីសោកសៅដុតឆេះរោល ។ អាចារ្យពួកខ្លះពោល

ដល់ព្រះនិព្វាន ពាក្យនោះមិនបានជាប់តគ្នានឹងបទខាងដើម។ ។ ចិត្ត របស់ព្រះខីណាស្រពទាំងនោះ ឈ្មោះថា អសោកៈយ៉ាងណា ឈ្មោះថា វិរជៈ ខេមៈ ដូច្នោះ ការពិតចិត្តរបស់ព្រះខីណាស្រព ឈ្មោះថា វិរជៈ ព្រោះប្រាសចាកលំអងកិលេសមានរាគៈ ទោសៈ មោហៈ ជាដើម និងឈ្មោះថា ខេមៈ ព្រោះផុតចាកយោគៈទាំង ៤ ប្រព្រឹត្តចំពោះអារម្មណ៍នោះៗ ដោយអាការនោះៗ គប្បីជ្រាបថា **ជាមង្គល** ព្រោះនាំមកនូវភាពជាអ្នកខ្ពស់ផុតលើលោកដែលមានខន្ធមិនប្រព្រឹត្តទៅ (មិនកើតទៀត) និងព្រោះនាំមកនូវភាពជា **អាហុនេយ្យបុគ្គល** ជាដើម ។

ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ព្រះគាថានេះទុក ៤ មង្គល គឺ ចិត្តដែលមិនញាប់ញ័រដោយលោកធម៌ ជ្រាំបី ១ ចិត្តមិនសោកសៅ ១ ចិត្តប្រាសចាកលំអងកិលេស ១ ចិត្តក្សេម ១ ដោយប្រការដូច្នេះ ។

ពណ៌នាគាថា ឯតាទិសានិ

ព្រះដ៏មានព្រះភាគជាម្ចាស់គ្រាត្រាស់ មហាមង្គល ៣៨ ប្រការ ដោយគាថា ទាំង ១០ ដែលមាន **អសេវនា ច ពាលា នំ** ប្រែថា : ការមិនសេពគប់ពាលជាអាទិ៍យ៉ាងនេះ

ហើយ ក៏ពេលនឹងទ្រង់លើកសរសើរនូវមង្គល ដែលព្រះអង្គទ្រង់ត្រាស់ទាំងនោះ ទើបបានត្រាស់គាថា ចុងក្រោយ **ឯតាទិសានិ កត្វាន** ជាដើម ។

ពណ៌នាសេចក្តីនៃគាថាចុងក្រោយដូចនេះ ។ បទថា **ឯតាទិសានិ** ប្រែថា ដូច្នេះ ទាំងនេះ គឺមានការមិនសេពគប់ពាល ជាដើម តាមប្រការដែលយើងពោលមកហើយ ។ បទថា **កត្វាន** ប្រែថា: ធ្វើសេចក្តីពិត ពាក្យនេះមិនក្រៅពីសេចក្តីថា **កត្វាន កត្វា ក្រិត្វា** (ដែលប្រែថាធ្វើដូចគ្នា) ។ បទថា **សព្វត្ថមបរាជិតា** សេចក្តីថា សត្វទាំងឡាយធ្វើ **មង្គល** ទាំងនេះ យ៉ាងដូច្នេះ ដែលមានសត្រូវ ៤ ប្រភេទ គឺ ខន្ធមារ កិលេសមារ អភិសង្ខាមារ ទេវបុត្រមារ សូម្បីមួយប្រភេទណាធ្វើឱ្យបរាជ័យមិនបានក្នុងទីទាំងពួង លោកអធិប្បាយថា ញុំាងមារទាំង ៤ នោះឱ្យចុះចាញ់ដោយខ្លួនឯង ក៏ **ម** អក្សរក្នុងពាក្យថា សព្វត្ថមបរាជិតានេះ គប្បីជ្រាបថា ត្រឹមធ្វើការតបទ ។

បទថា **សព្វត្ថ សោត្ថឹ គច្ឆន្តិ** សេចក្តីថា សត្វទាំងឡាយ ធ្វើមង្គលដូចដែលពោលមកនេះ ជាអ្នកដែលមារទាំង ៤ ធ្វើឱ្យវិនាសមិនបានឡើយ រមែងដល់សិរីសួស្តីក្នុងទីទាំងពួង គឺ

ក្នុងលោកនេះ និងលោកខាងមុខ ទោះឈរ ឬដើរជាដើម ។ អាសវៈណា ដែលធ្វើឱ្យចង្អៀតចង្អល់ ក្តៅអន្ទះអន្ទែងនឹងកើតឡើង ព្រោះការសេពគប់ពាលជាដើម ហេតុមិនមានអាសវៈទាំងនោះ ទើបចូលដល់សវសតី (សិរីសួស្តី) លោកអធិប្បាយថា ជាអ្នក ដែលឧបទ្ទវៈមិនជំទាស់ ដែលឧបសគ្គក៏មិនទំនាស់ក្បែរផុតស្រឡះ មិនមានភ័យទៅខាងមុខ ។ ក៏និគ្គហិតក្នុងពាក្យថា **សព្ធត្ថ សោត្ថិ គច្ឆន្តិ** គប្បីជ្រាបថា ទ្រង់ត្រាស់ដើម្បីសម្រួលដល់ការចងគាថា ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បញ្ចប់ធម្មទេសនាដោយបទនៃគាថា **តំ តេសំ មង្គលមុត្តមំ** ។ ទ្រង់បញ្ចប់យ៉ាងណា ទ្រង់បញ្ចប់ថា ម្នាលទេវបុត្រ ព្រោះហេតុដែលជនអ្នកធ្វើ **មង្គល** រមែងមានសិរីសួស្តីក្នុងទីទាំងពួង ដូច្នោះលោកទើបពោលថា មង្គលទាំង ៣៨ ប្រការ មានការមិនសេពគប់ពាលជាដើម ខ្ពស់បំផុត ប្រសើរបំផុត ល្អបំផុតសម្រាប់ជនទាំងនោះ អ្នកធ្វើមង្គលដូចដែលពោលមកនេះ ។

ទេសនាចុងក្រោយដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បញ្ចប់យ៉ាងនេះ ទេវតា ១ សែនកោដិ សម្រេចព្រះអរហត្ត ។

ចំនួនអ្នកសម្រេចសោតាបត្តិផល សកទាគាមិផល អនាគាមិផល រាប់មិនបាន ។ លុះព្រឹកឡើង ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ហៅ ព្រះអានន្ទថេរៈមកត្រាស់ថា ម្នាលអានន្ទ ពេលយប់មិញ មានទេវតាមួយអង្គចូលមកសួរ មង្គលបញ្ហា យើងក៏បានពោលនូវមង្គល ៣៨ ប្រការ ដល់ទេវតាអង្គនោះ ម្នាល អានន្ទ អ្នកចូររៀនមង្គលបរិយាយនេះ កាលបើរៀនចេះហើយ ចូរទូន្មានភិក្ខុទាំងឡាយ ព្រះថេរៈរៀនហើយ ក៏ទូន្មានភិក្ខុទាំងឡាយទៀត ។ មង្គលសូត្រនេះ អាចារ្យនាំបន្តៗគ្នា ប្រព្រឹត្តទៅរហូតដល់ថ្ងៃនេះ គប្បីជ្រាបថា សាសនព្រហ្មចារ្យនេះបានចម្រើនតាំងមាំផ្សព្វផ្សាយឱ្យដឹងច្រើននាក់ យ៉ាងក្រាស់ក្រែលដែលទេវតានិងមនុស្សប្រកាសល្អហើយ ។

សត្វទាំងឡាយអ្នកប្រាថ្នាសេចក្តីសុខក្នុងលោកនេះ លោកខាងមុខ និងលោកុត្តរសុខ ត្រូវលះបង់ការសេពគប់ពាលចេញជាមុន ត្រូវអាស្រ័យនឹង **បណ្ឌិត** បូជាអ្នកដែលគួរបូជា ។ ការនៅក្នុងបដិរូបទេស និងភាពជាអ្នកធ្វើបុណ្យទុកពីមុន បានមកជួយដាស់តឿនក្នុងការបំពេញកុសល តាំងខ្លួនទុកប្រពៃមានអត្តភាពប្រដាប់ដោយពាហុសច្ចៈ សិល្បៈ និងវិន័យ ពោលនូវសុភាសិតដែលសមគួរដល់វិន័យ ។ នៅមិនទាន់លះភេទត្រហស្ថដរាប

ណា ក៏ត្រូវជម្រះបំណុលចាស់ដោយការទំនុកបម្រុងមាតាបិតា ប្រកបបំណុលថ្មី ដោយការសង្គ្រោះបុត្រនិងភរិយា ដល់ព្រម ដោយ ទ្រព្យនិងស្រូវឬបាយទឹក ភាពជាអ្នកមានការងារ មិន ច្របូកច្របល់ ប្រកាន់សារៈនៃភោគៈដោយការធ្វើទាននិងសារៈ នៃជីវិតដោយការប្រព្រឹត្តិធម៌ ធ្វើប្រយោជន៍សុខដល់ជនរបស់ ខ្លួន ដោយការសង្គ្រោះញាតិនិងប្រយោជន៍សុខ ជួយឧបត្ថម្ភដល់ អ្នកដទៃ ដោយការងារមិនមានទោសវៀរការបំផ្លាញប្រយោជន៍ អ្នកដទៃ ដោយការវៀរចាកបាប ចាកការបំផ្លាញខ្លួនឯង ដោយ ការប្រុងប្រយត្នមិនធីកគ្រឿងស្រវឹង កពូននូវកុសលដោយការ មិនប្រមាទក្នុងធម៌ទាំងឡាយ លះភេទគ្រហស្ថ ដោយភាពជា អ្នកធ្វើកុសល សូម្បីតាំងនៅក្នុងភាវបព្វជិត ក៏ញុំាងវត្តសម្បទា ឱ្យសម្រេច ដោយសេចក្តីគោរពក្នុងព្រះពុទ្ធជាម្ចាស់ សាវ័ករបស់ ព្រះពុទ្ធជាម្ចាស់ និងឧបជ្ឈាយាចារ្យជាដើម ដោយការដាក់ខ្លួន លះលោភៈក្នុងបច្ច័យដោយសន្តោស តាំងនៅក្នុងសប្បុរិសភូមិ ដោយភាពជា អ្នកកតញ្ញូ លះភាពជាអ្នកមានចិត្តរួញរាក្នុងការ ស្តាប់ធម៌ គ្របសង្កត់អន្តរាយគ្រប់យ៉ាងដោយខន្តី ធ្វើខ្លួនឱ្យមាន ទីពឹង ដោយភាពជាអ្នកប្រដៅងាយ ។ ត្រូវប្រកបការបដិបត្តិ ដោយឃើញសមណៈ បន្ទោបង់នូវការសង្ស័យក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីសង្ស័យ ដោយការសន្ទនាធម៌ ដល់សីល វិសុទ្ធិ ដោយតបៈ គឺឥន្ទ្រិយសំវរៈ ដល់ចិត្តវិសុទ្ធិ ដោយ

ព្រហ្មចារ្យ គឺ សមណធម៌ ហើយញុំាងវិសុទ្ធិទាំង ៤ ក្រៅនោះឱ្យដល់ព្រម ដល់ញាណទស្សនវិសុទ្ធិ ដែលជាបរិយាយនៃការឃើញអរិយសច្ចៈ ដោយបដិបទានេះ ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានដែលរាប់បានថា អរហត្តផល ។ នៅពេលធ្វើឱ្យជាក់ច្បាស់ហើយ ជាអ្នកមានចិត្តមិនញាប់ញ័រក្នុងលោកធម៌ ៨ ដូចភ្នំសិនេរុមិនញាប់ញ័រដោយខ្យល់និងភ្លៀង រមែងជាអ្នកមិនសោកសៅ ប្រាសចាកលំអងកិលេស មានសេចក្តីក្សេមផុតស្រឡះ រមែងជាអ្នក សូម្បីសត្រូវម្នាក់ធ្វើឱ្យបរាជ័យ មិនមានក្នុងទីទាំងពួង ព្រមទាំង ប្រកបដោយសិរីសួស្តីគ្រប់ទីកន្លែង ។

ដោយហេតុនោះ ព្រះដ៏មានព្រះភាគទើបទ្រង់ត្រាស់ថាៈ- សត្វទាំងឡាយធ្វើមង្គលដូចដែលពោលមកនេះ ជាអ្នកដែលមារធ្វើឱ្យបរាជ័យមិនបានក្នុងទីទាំងពួង រមែងមានសិរីសួស្តីគ្រប់ទីស្ថាន នេះជាមង្គលរបស់សត្វទាំងនោះ ។

◈ សរុបសេចក្តីទាំងអស់នេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា តថាគត មិនឃើញសួស្តីរបស់ពួកសត្វក្រៅអំពីៈ

នាញ្ញត្រ ពោជ្ឈង្គបសា នាញ្ញត្រ ឥន្ទ្រិយសំវរា
នាយត្រ សព្វនិស្សគ្គា សោត្ថី បស្សាមិ ជាណិនន្តិ ។

ប្រែថា : សួស្តីរបស់ពួកសត្វ មិនក្រៅអ្វីពី ពោជ្ឈង្គ និង តបោគុណ មិនក្រៅពីការសង្រួមឥន្ទ្រិយ និងមិនក្រៅពីការលះបង់នូវកិលេសទាំងអស់ទេ ។

ស្តាប់ព្រះគាថាចប់ហើយ សុព្រហ្មទេវបុត្រតាំងនៅក្នុងសោតាបត្តិផល ។

(ស្រង់ចាកសំ.សគាថវគ្គបិដកលេខ ២៩/១៤២)

ចប់ពណ៌នាមង្គលសូត្រ នៃបរមត្ថជោតិកា

អដ្ឋកថា ខុទ្ទកបាឋៈ

សង្ខេបសេចក្តីក្នុងព្រះគាថា

ហេតុយ៉ាងណា បានជាព្រះដ៏មានព្រះភាគ ទ្រង់សម្តែងនូវមង្គលទាំង ៣៨ ប្រការនេះ ព្រោះដើម្បីសេចក្តីសុខរបស់ទេវតា និងមនុស្សទាំងឡាយ ដូចបានជម្រាបជូនពីខាងដើមរួចមកហើយ នៅក្នុងព្រះគាថាទាំង ១០ ប្រការ ដែលមាន ៣៨ មង្គល ។ ក្នុងកាលៈទេសៈ ដែលមានរឿងហេតុបែបនេះ ក៏ជាការអស្ចារ្យយ៉ាងក្រៃលែង សម្រាប់បង្ហាញពីបាតុភូតធម្មជាតិ តែងកើតឡើងមានហេតុប្បច្ច័យគ្រប់គ្រាន់ក្នុងសម័យកាល ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់នៅជាធរមាន ហើយក៏ជាការកម្រយ៉ាងក្រៃលែងទៀត ព្រោះធ្វើឱ្យទេវតានិងមនុស្សមានឧបនិស្ស័យពីមុន ដោយបានសន្សំបុណ្យទុកមកច្រើនផង និងធ្លាប់បានជួបនូវ ព្រះសម្មាសម្ពុទ្ធមុនៗ ជាច្រើនព្រះអង្គផង ទើបផលសម្រេចពីបុណ្យនោះ នាំឱ្យបានមកជួបនូវមង្គល ៣៨ ប្រការ ដែលទ្រង់សម្តែងដោយព្រះសមន្តចក្ខុរបស់ព្រះដ៏មានព្រះភាគ ដើម្បីជួយស្រោចស្រង់សត្វ ឱ្យរួចពីអន្ទាក់មារ បានដល់ជាតិ ជរា ព្យាធិ និង មរណៈ ។

ការជួបប្រសព្វនូវភ័ព្វសំណាងដ៏អស្ចារ្យនេះ ធ្វើឱ្យពពួកសត្វសម្រេចមគ្គផលយ៉ាងច្រើន មានទាំងទេវតានិងមនុស្ស ដោយមានការរីកចម្រើនផ្លូវចិត្ត ខាងការដុសខាត់កិលេសឱ្យជ្រុះចេញពីក្នុងចិត្តសន្តាន នាំឱ្យមានពន្លឺរស្មីដ៏រុងរឿង ឃើញនូវអ្វីដែលមិនធ្លាប់ជួបប្រទះ ព្រោះធ្លាប់តែឋិតនៅក្នុងផ្ទុកនៃអន្លង់ទិដ្ឋិ អន្លង់កាម អន្លង់ភព និងអន្លង់អវិជ្ជារបស់វដ្តទុក្ខ ហើយក៏ទ្រាំទ្រស់នៅក្នុងរណ្តៅនរកបច្ចុប្បន្ន ងងឹតអាប់អួត្រឹមតែសេចក្តីសុខស្រួល និងអានិសង្ស របស់រូបបន្តិចបន្តួច។

ក្នុងការសម្តែងធម៌គ្រានោះ ព្រះសម្មាសម្ពុទ្ធបំផុតលោកទ្រង់បានត្រាស់នូវព្រះគាថាដ៏មានខ្លឹមសារយ៉ាងពីរោះក្បោះក្បាយដល់អ្នកស្តាប់ជក់ជាប់ចិត្ត ប្រឹងត្រងចាប់យកនូវធម្មរសសម្រាប់អ្នកមានឧបនិស្សយប្បច្ច័យ ក៏បានជ្រួតជ្រាបចូលទៅក្នុងដួងចិត្តរបស់ទេវតា និងមនុស្សទាំងឡាយដ៏ច្រើននាពេលនោះ ដោយបានបោះជំហានដើរទៅមុខមិនងាកក្រោយមើលលោក គឺបែរខ្នងដាក់លោកឆ្ពោះទៅកាន់ត្រើយនាយ ពោលគឺបរមសុខពុំមានសត្រូវពួកសង្គិលេសធម៌មកការាំង ធ្វើទារុណកម្មក្នុងអំណាចខ្លួនយ៉ាងក្សេមក្សាន្ត ដែលបានពណ៌នានូវព្រះគាថា

នីមួយៗ ក្នុងព្រះអដ្ឋកថា តាមការធ្វើបឋមសង្គាយនា ដូចតទៅនេះ :-

- **ព្រះគាថាទី ១:** អសេវនា ច មាន ៣ មង្គល គឺការមិនសេពគប់បុគ្គលពាលទាំងឡាយ១ ការសេពគប់បណ្ឌិតទាំងឡាយ១ និងការបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ១ ។
- **ព្រះគាថាទី ២:** បដិរូបទេសវាសោ ច មាន ៣ មង្គល គឺ ការនៅក្នុងប្រទេសដ៏សមគួរ១ ភាពនៃបុគ្គលបានធ្វើបុណ្យទុកក្នុងកាលមុន១ ការតម្កល់ខ្លួនដោយប្រពៃ ១ ។
- **ព្រះគាថាទី ៣:** ពាហុសច្ចញ្ច មាន ៤ មង្គល គឺ ពាហុសច្ចញ្ច១ សិល្បសាស្ត្រ១ វិន័យដែលបានសិក្សាដោយប្រពៃ១ និងវាចាដែលពោលត្រូវ១ ។
- **ព្រះគាថាទី ៤:** មាតាបិតុឧបដ្ឋានំ មាន ៤ មង្គល គឺការបម្រើមាតា១ ការបម្រើបិតា១ ការសង្គ្រោះបុត្រ សង្គ្រោះភរិយា១ និងការងារទាំងឡាយមិនច្របូកច្របល់១ ។

- **ព្រះគាថាទី ៥:** ទានញ្ច មាន ៤ មង្គល គឺទាន១ ការប្រព្រឹត្តធម៌១ ការសង្គ្រោះពួកញាតិ១ និងការងារមិនមានទោស១ ។
- **ព្រះគាថាទី ៦:** អារតី មាន ៣ មង្គល គឺការវៀរចាកបាប ១ សេចក្តីសង្រួម ចាកកិរិយាផឹកនូវទឹកស្រវឹង ១ និងសេចក្តីមិនប្រមាទ ក្នុងធម៌ទាំងឡាយ១ ។
- **ព្រះគាថាទី ៧:** គារវោ ច មាន ៥ មង្គល គឺសេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព១ ការប្រព្រឹត្តបន្ទាបខ្លួន១ សេចក្តីត្រេកអរចំពោះរបស់ដែលមាន១ ភាពនៃបុគ្គលអ្នកដឹងនូវឧបការគុណ ដែលអ្នកដទៃធ្វើដល់ខ្លួន១ និងការស្តាប់ធម៌តាមកាល១ ។
- **ព្រះគាថាទី ៨:** ខន្តី ច មាន ៤ មង្គល គឺសេចក្តីអត់ធន់ ១ ភាពនៃបុគ្គលដែលប្រដៅងាយ១ ការបានឃើញបានជួបនូវសមណៈទាំងឡាយ១ និងធម្មសាកច្ឆាតាមកាល១ ។
- **ព្រះគាថាទី ៩:** តបោ ច មាន ៤ មង្គល គឺសេចក្តីព្យាយាមដុតបាបធម៌១ ការប្រព្រឹត្តនូវធម៌ដ៏ប្រសើរ១ ការឃើញនូវអរិយសច្ចៈទាំងឡាយ១ និងការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន១ ។

- **ព្រះគាថាទី ១០:** ផុដ្ឋស្ស លោកធម្មេហិ មាន ៤ មង្គល គឺចិត្តនៃបុគ្គលណា ដែលលោកធម៌ពាល់ត្រូវហើយ មិនរំភើប ញាប់ញ័រ១ មិនមានសេចក្តីសោក១ មានធូលីគឺ រាគៈទៅប្រាស ហើយ១ និងចិត្តក្សេមក្សាន១។ សរុបមាន ១០ ព្រះគាថា ចែក ចេញជា ៣៨ មង្គល ដោយបរិបូណ៌ ។

កំណាត់សម្គាល់ នូវចំណុចទាំង ១១ ប្រការ :

១- មានមង្គលសិរីសួស្តី ព្រោះបានសេពគប់នឹងសប្បុរស

២- សម្បត្តិគ្រប់យ៉ាង កើតឡើងពីសិរីសួស្តី

៣- សួស្តីទាំងឡាយ នាំឱ្យមានជ័យជំនះលើអ្វីៗ ទាំងពួង

៤- សួស្តីជាទីស្រឡាញ់រាប់អានរបស់អ្នកប្រាជ្ញ

៥- មានសិរីសួស្តីនៅក្នុងខ្លួន គឺមានទីពឹងដ៏មាំមួន

៦- សេចក្តីចម្រើនគ្រប់យ៉ាង កើតពីសិរីសួស្តី

៧- បើស្រឡាញ់ខ្លួន ត្រូវធ្វើខ្លួនឱ្យមានមង្គលសួស្តី

៨- ការកើតឡើងនៃសួស្តី ដោយអំណាចសតិប្បដ្ឋាន និងវិបស្សនា

៩- មង្គលសិរីសួស្តី នាំឱ្យបានរួចផុតចាកទុក្ខទាំងពួង

១០- មង្គលសូត្រ ជាធម៌ដឹកនាំសត្វឱ្យបានដល់ព្រះនិព្វាន

១១- សិរីសួស្តី ជាធម៌របស់អ្នកស្ងប់រម្ងាប់ ។

ដំណើរប្រព្រឹត្តទៅចេញចាកលោក

ក្នុងព្រះពុទ្ធសាសនា មានបដិបទាដ៏កំពូលពិសេស លើសាសនាទាំងអស់ក្នុងលោក ព្រោះជាធម្មជាតិដែលព្រះអង្គទ្រង់រីកចេញពីស្រោមអវិជ្ជារបស់បដិច្ចសមុប្បាទធម៌ បានដល់ឧបាទានក្ខន្ធ ៥ ដោយការត្រាស់ដឹងនូវចតុរារិយសច្ច ។

កាលណាសិក្សាឱ្យបានឃ្មត់ចត់ល្អត្រឹមត្រូវនៅក្នុងសាច់ធម៌នីមួយៗ មិនក្រៅអ្វីពី ខន្ធ ធាតុ អាយតនៈ បានសេចក្តីថា ធម៌ទាំងឡាយទាំងពួង មិនគួរប្រកាន់ថាជារបស់មាំមួន អាស្រ័យបច្ច័យកើតឡើងហើយ ក៏រលត់ទៅវិញជាធម្មតា ឃើញដោយវិបស្សនាវិជ្ជា ។ ការដែលទ្រង់សម្តែង ព្រះធម្មទេសនាម្តងៗ ព្រះអង្គទ្រង់ជ្រាបដោយសមន្តចក្ខុ ឬ សព្វញ្ញុតញ្ញាណ ទៅតាមឧបនិស្ស័យរបស់សត្វ មានមនុស្ស ទេវតា និងពួកព្រហ្ម ឬពួកមារជាដើម សុទ្ធតែរស់នៅក្នុងសំណាញ់ញាណរបស់ព្រះតថាគតទាំងអស់ ឱ្យតែព្រះអង្គទ្រង់ចង់ជ្រាបនៅទីណា ឬពេលណាក៏បាន ដូចមាននៅក្នុងអដ្ឋកថា ទីឃនិកាយ បាដិកវគ្គ លេខ ១៥/២៤៧ ថាៈ សេចក្តីពិត ឈ្មោះថា របស់ដែលមិនមែន

វិស័យរបស់ព្រះពុទ្ធទាំងឡាយ រមែងមិនមាន ព្រោះព្រះបាលីថា ញាណមានប៉ុណ្ណា របស់ដែលព្រះអង្គ គប្បីដឹងក៏មានត្រឹមប៉ុណ្ណោះ របស់ដែលព្រះអង្គ គប្បីដឹងមានប៉ុន្មាន ញាណក៏មានប៉ុណ្ណោះ របស់ដែលព្រះអង្គ គប្បីដឹងមានញាណជាទីបំផុត ញាណក៏មានរបស់ដែលព្រះអង្គ គប្បីដឹងជាទីបំផុតក៏យ៉ាងដូច្នេះដែរ ។ មុនដំបូងបង្អស់ ព្រះអង្គទ្រង់លើកយកពី :

ការមិនសពគប់បុគ្គលពាលទាំងឡាយ ឱ្យសេពគប់បណ្ឌិតទាំងឡាយ និង ការបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ (ទាំង៣) នេះជាមង្គល ។

សេចក្តីនេះមានយ៉ាងណា ពាក្យថា មង្គល សរសេរនៅក្នុងវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោថា: (មង់-គល់) ន. (សំ-បាលី) សេចក្តីចម្រើន សេចក្តីសុខ ហេតុដែលនាំឱ្យកើតសេចក្តីសុខចម្រើន, ស្រីសួស្តី ។ មង្គលការ ការជាមង្គល ខ្មែរហៅចំពោះតែ << ការអាពាហ៍-ពិពាហ៍ >> មានមង្គលការ, រៀបមង្គលការ ។ មង្គលវាទ ឬ មង្គលកថា (ម៉ង-គៈលៈវាទ ឬ-កៈថា) ពាក្យថា មង្គល, ពាក្យឱ្យពរ ។ មង្គលសូត្រ (មង់-គ-លៈសូត្រ) ឈ្មោះព្រះសូត្រមួយជាពុទ្ធភាសិតសម្តែងអំពីមង្គល ៣៨ ប្រការ, ពួក

ពុទ្ធសាសនិកតែងសូត្រក្នុងវេលាធ្វើកិច្ចការជាមង្គលណាមួយ (ព.ពុ) ។ មង្គលាភិសេក (មង់-គៈលាៈភិសេក) ការស្រោចទឹកជាមង្គល, ការស្រោចទឹកឱ្យមានមង្គល ។ល។

ដើម្បីសិរីសួស្តីរបស់សត្វទាំងឡាយ ត្រូវប្រតិបត្តិឱ្យត្រូវត្រង់តាមក្បួនច្បាប់របស់សភាវៈ ដែលជាឫសគល់ក្នុងធម៌ទាំងឡាយ មិនច្របូកច្របល់លាយឡំជាមួយអំពើអកុសលព្រោះអំពីបាបធ្វើហេតុនាំទៅរកសេចក្តីវិនាស មិនចម្រើនន្លូវអ្វីៗគ្រប់យ៉ាង ទោះបីខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងកិច្ចការងារទាំងយប់ទាំងថ្ងៃស្ទើររកពេលសម្រាកគ្មាន ទីបំផុតនៅតែគ្មានបានប្រយោជន៍អ្វី ។ អាស្រ័យហេតុនេះ ព្រះសម្ចាសម្ពុទ្ធទ្រង់លើកយកព្រះគាថាទី១ មកសម្តែង ជាការបើកផ្លូវឱ្យសត្វលោកដើរ តាមកុសលធម៌ គឺ ចាប់កាច់ចង្កូតមុនដំបូងបង្អស់ ដោយឧបាយ សម្រាប់ធ្វើឱ្យទេវតា និងមនុស្សបានយល់ជ្រួតជ្រាបក្នុងមង្គល ៣៨ ប្រការនេះ ។ ឯការបានសម្រេចដល់ទីបំផុតទុក្ខនៅលើខ្លួនយើងម្នាក់ៗ ដែលធ្លាប់បានសិក្សាអប់រំចម្រើនសតិប្បដ្ឋាន ៤ មានការសិក្សាពី សីល សមាធិ បញ្ញា ដើម្បីព្រះនិព្វាន ដោយខ្លួនឯង ។ អ្វីទៅការសិក្សា ដើម្បីព្រះនិព្វានដោយខ្លួនឯង ?

ឆ្លើយថា ព្រោះបានសេពគប់នឹងសប្បុរស ទើបមានបញ្ញាជាតួបដិបត្តិ នាំឱ្យបានចាក់ធ្លុះនូវសភាវធម៌ពិត បានដល់អរិយ-សច្ចធម៌ ៤ ចំណែកបញ្ញាកើតឡើងពីសមុដ្ឋាន ៣ ដែលមាននៅក្នុង ទីឃនិកាយ បាដិកវគ្គ បិដកលេខ ១៩/១៤២ ក្នុងចង្កោមពួកធម៌បី៧ដូចតទៅ:-

១. **ចិន្តាមយា បញ្ញា** បញ្ញាសម្រេចមកពីការគិត

២. **សុតមយា បញ្ញា** បញ្ញាសម្រេចមកពីការស្តាប់

៣. **ភាវនាមយា បញ្ញា** បញ្ញាសម្រេចមកពីការចម្រើន។

សេចក្តីនេះបញ្ជាក់ថា ការមានបញ្ញាដែលប្រសូតចេញពីពួកធម៌បី៧ ជាការបើកផ្លូវឱ្យចូលទៅរកសប្បុរស ដើម្បីបានស្តាប់ធម៌ ទើបបញ្ញាអាចកើតឡើង ព្រោះបរតោឃោសៈ អារម្មណ៍ពីខាងក្រៅរបស់សប្បុរស នឹងប្រាកដតាមពេលវេលាអាស្រ័យពីការមានសទ្ធា ។ នៅក្នុងអង្គុត្តរនិកាយ ទសកនិបាត យមកវគ្គ បិដកលេខ ៥០/២៦១ ទ្រង់ត្រាស់ សម្តែងថា:-

-ម្នាលភិក្ខុទាំងឡាយ

សប្បុរិសសំសេវៈ ការសេពគប់សប្បុរសពេញបរិបូណ៌ រមែងញុំាងសទ្ធម្មស្សវនៈ(ការស្តាប់ធម៌)ឱ្យពេញបរិបូណ៌ ។

សទ្ធម្មស្សវៈ ពេញបរិបូណ៍ រមែងញ្ចុំងសទ្ធា(ការជ្រឿ) ឱ្យពេញបរិបូណ៍ ។

សទ្ធា ពេញបរិបូណ៍ រមែងញ្ចុំងយោនិសោមនសិការ (ការធ្វើទុកក្នុងចិត្តដោយឧបាយឆ្លាត) ឱ្យពេញបរិបូណ៍ ។

យោនិសោមនសិការ ពេញបរិបូណ៍ រមែងញ្ចុំងសតិសម្បជញ្ញៈ (ការរលឹកដឹងខ្លួន) ឱ្យពេញបរិបូណ៍ ។

សតិសម្បជញ្ញៈ ពេញបរិបណ៍ រមែងញ្ចុំងឥន្ទ្រីយសំវរៈ (ការសង្រួមឥន្ទ្រីយ) ឱ្យពេញបរិបូណ៍ ។

ឥន្ទ្រីយសំវរៈ ពេញបូរិបូណ៍ រមែងញ្ចុំងសុចរិត ៣ ឱ្យពេញបរិបូណ៍ ។

សុចរិត៣ ពេញបូរិបូណ៍ រមែងញ្ចុំង សតិប្បដ្ឋាន៤ ឱ្យពេញបរិបូណ៍ ។

សតិប្បដ្ឋាន៤ ពេញបរិបូណ៍ រមែងញ្ចុំង ពោជ្ឈង្គ៧ ឱ្យពេញបរិបូណ៍ ។

ពោជ្ឈង្គ៧ ពេញបរិបូណ៍ រមែងញ្ចុំងវិជ្ជា និង វិមុត្តិ ឱ្យពេញបរិបូណ៍ ដោយប្រការដូច្នេះឯង ។

ពាក្យថាពេញបរិបូណ៌ ជាឈ្មោះរបស់អាហារប្បច្ច័យ ព្រោះ ហេតុដូច្នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា:-

ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា វិជ្ជានិងវិមុត្តិ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ វិជ្ជានិងវិមុត្តិ គប្បីឆ្លើយថា ពោជ្ឈង្គ ៧ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ពោជ្ឈង្គ ៧ ប្រការប្រកប ដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជា អាហាររបស់ ពោជ្ឈង្គ ៧ ប្រការ គប្បីឆ្លើយថា សតិប្បដ្ឋាន ៤។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិប្បដ្ឋាន ៤ ប្រកប ដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជា អាហាររបស់សតិប្បដ្ឋាន ៤ គប្បីឆ្លើយថា សុចរិត ៣ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សុចរិត ៣ ប្រកបដោយ អាហារ មិនបានពោលថាឥតអាហារទេ។ ចុះអ្វីជាអាហាររបស់ សុចរិត ៣ គប្បីឆ្លើយថា ការសង្រួមឥន្ទ្រិយ ។ ម្នាលភិក្ខុទាំង ឡាយ តថាគតពោលថា ការសង្រួមឥន្ទ្រិយ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ការ សង្រួមឥន្ទ្រិយ គប្បីឆ្លើយថា សតិ និង សម្បជញ្ញៈ។ ម្នាលភិក្ខុ ទាំងឡាយ តថាគតពោលថា សតិ និង សម្បជញ្ញៈ ប្រកបដោយ

អាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សតិនិងសម្បជញ្ញៈ គប្បីឆ្លើយថា យោនិសោមនសិការ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា យោនិសោមនសិការ ប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់យោនិសោមនសិការ គប្បីឆ្លើយថា សទ្ធា។ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលថា សទ្ធា ប្រកបដោយ អាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ សទ្ធា គប្បីឆ្លើយថា សទ្ធម្មស្សវនៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលថា សទ្ធម្មស្សវនៈ ប្រកបដោយអាហារ មិនបាន ពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់ សទ្ធម្មស្សវនៈ គប្បីឆ្លើយថា សប្បុរិសសំសេវៈ ។

សេចក្តីអធិប្បាយ

ជីវិតប្រក្រតីមានយុត្តិធម៌ត្រឹមត្រូវល្អណាស់ ព្រោះជាធម្មជាតិកើតចាកហេតុប្បច្ច័យ អ្វីណាកើតពីហេតុប្បច្ច័យអ្វីនោះ ពុំមានតួខ្លួនសត្វបុគ្គលឡើយ មានត្រឹមតែរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ រួចធ្វើកិច្ចកម្មាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោក បានដល់ លោភៈ ទោសៈ មោហៈ ជាមូលនៃអកុសល

ធម៌ទាំងពួង ដោយសតិប្បដ្ឋានប្បដិបត្តិ ជាធម៌នាំសត្វចេញចាក លោកឱ្យបានទៅជួបនូវសុភមង្គលជានិច្ចនិរន្តរ៍ ព្រោះលះសេចក្តី ប្រកាន់ជាតទង្គប្បហាន ដើម្បីសម្រួលដល់ឥដ្ឋារម្មណ៍ និងអនិដ្ឋា-រម្មណ៍ មិនឱ្យមានខ្ពស់ទាប ប្រមូលរួមចូលទៅក្នុងអាយនសព្វៈ មួយមុខព្រមទាំងពង្រីកពង្រាយនូវពួកធម៌ទាំង១០នីមួយៗ ឱ្យ បានពិស្តារក្នុងការសិក្សាបដិបត្តិ និងបដិវេធៈដូចតទៅ :-

✵ **សប្បុរិសសំសេវៈ** (ការសេពគប់សប្បុរស) បាន ន័យថា ចូលទៅរកសប្បុរសហើយប្រាស្រ័យទាក់ទងជាមួយនឹង សប្បុរស ដោយសេចក្តីគោរពកោតក្រែងរាប់អានលោកឱ្យពេញ លេញ ដើម្បីស្នើសុំជួយបំភ្លឺនូវបញ្ហាណាមួយ ដែលខ្លួនត្រូវការ។ លុះការប្រាស្រ័យទាក់ទងចប់សព្វគ្រប់ហើយ ទើបរកទីកន្លែងដ៏ សមគួរ អង្គុយដោយស្បៃមស្ងាត់ច្បៀសវាងនូវការអង្គុយប្រកប ដោយទោស ៦ យ៉ាង ហើយសំងំរងចាំស្តាប់នូវការឆ្លើយ ដោះ ស្រាយតាមសំនួរនោះ ដូចយ៉ាងទេវតា នាំគ្នាចុះមកគាល់ ព្រះសម្មាសម្ពុទ្ធទូលសួរពី មង្គល ៣៨ ប្រការនេះឯង។ ប៉ុន្តែ ប្រសិនបើពុំមាន ព្រះសម្មាសម្ពុទ្ធទេ មានត្រឹមតែព្រះភិក្ខុ សង្ឃសាវ័ក ដែលជាព្រះរតនត្រ័យនោះ ឬជនជាសប្បុរស

(ពហុស្សុត) អ្នកចេះចាំនូវព្រះពុទ្ធវចនៈច្រើន ឬសេពគប់នឹងគម្ពីរព្រះត្រៃបិដកដែលជាព្រះពុទ្ធវចនៈ តម្កល់ទុកនៅក្នុងទូតាមបណ្ណាល័យណាមួយ យ៉ាងសប្បាយក៏បាន ។

✵ **សន្ធឫស្សវនៈ** (ស្តាប់ធម៌របស់សប្បុរស) បានន័យថា ស្តាប់ សំឡេង ដែលជាបរតោឃោសៈរបស់អ្នកប្រាជ្ញនោះ គឺ ផ្ទៀងត្រចៀកស្តាប់ដោយយកចិត្តទុកដាក់ជាទីបំផុត មានសេចក្តីព្យាយាម អត់សង្កត់ចិត្តយ៉ាងមាំទាំ ប្រុងប្រយ័ត្នការពារ កុំឱ្យចិត្តរវើរវាយរាយមាយ ព្រោះការរាយមាយចិត្តមិនអាចត្រងត្រាប់ចាប់យកសេចក្តីក្នុងខ្លឹមសារណាមួយបានទេ និងអាចឱ្យខាតពេលវេលាទៅទទេឥតប្រយោជន៍ ក៏ពុំមានអ្វីទុកសម្រាប់ទីពឹងដល់ខ្លួន ។ ក្នុងពេលកំពុងស្តាប់ធម៌ ត្រូវមានស្មារតីកត់ត្រាចំណាំនូវចំណុចសំខាន់ៗ យកមកផ្ទៀងផ្ទាត់នៅក្នុងក្បួនច្បាប់របស់ឫសគល់ធម៌ ដែលមាននៅក្នុង គម្ពីរព្រះត្រៃបិដក និងអដ្ឋកថា ។ កាលណាផ្ទៀងផ្ទាត់ទៅឃើញ ថា ត្រឹមត្រូវពិតប្រាកដហើយ ទើបយកមកសិក្សារៀនសូត្រ ដោយសេចក្តីគោរព ចងចាំដោយគោរព ពិចារណាដោយគោរព និងបដិបត្តិដោយគោរព ។ ប៉ុន្តែបើមិនត្រឹមត្រូវទៅវិញ ក៏នៅស្ងៀមមិនថា

អ្វីឡើយ ព្រោះអ្នកសម្តែងធម៌ ជាការក្រមួយ គឺ សម្បូណ៌តែអ្នក មិនចេះ សម្តែងធម៌ ហើយត្រូវចេះលើកទឹកចិត្តដល់អ្នកសម្តែង ថែមទៀត ព្រមទាំងជួយឧបត្ថម្ភគាំទ្រអ្នកនោះ ព្រោះជាអ្នក ជួយជ្រោមជ្រែងផ្សព្វផ្សាយធម៌ក្នុងព្រះពុទ្ធសាសនា ដូចមាន ការសរសេរសៀវភៅធម៌ ជាដើម ។

ម្យ៉ាងទៀតការស្តាប់ធម៌ គឺ ការសិក្សារៀនសូត្រ ព្រះបរិយត្តិ ដែលត្រូវធ្វើយ៉ាងណាឱ្យបានយល់ជម្រៅព្រះធម៌ ទោះបីស្តាប់ច្រើនថ្ងៃ ច្រើនខែ ច្រើនឆ្នាំ ច្រើនពេលវេលាតទៅ មុខរហូតរាប់មហាកប្ប ។ល។ ដូចជាមហាសតិប្បដ្ឋានសូត្រជា ដើម កម្រស្តាប់យល់ណាស់ ព្រោះសតិប្បដ្ឋានមានកិច្ចរលីកដឹង ទាន់ នូវសភាវធម៌កំពុងប្រាកដ (បច្ចុប្បន្ន) តាមលោក ៦ គឺ អារម្មណ៌ ៦ ណាមួយ ឯការឃើញរបស់ពិត (សច្ចធម៌) ដោយ វិបស្សនា ។ ប្រសិនបើស្តាប់មិនយល់ តើបានអ្វីជាសតិប្បដ្ឋាន-ប្បដិបត្តិ ដោយសេចក្តីថា កុំទាន់បដិបត្តិ ។

នេះជាគន្លងផ្លូវឆ្ពោះទៅរកសុខសន្តិភាព សម្រាប់សត្វ លោកដែលចាំបាច់ ត្រូវតែសេពគប់សប្បុរសមុនដំបូងបង្អស់ នឹង អាចបង្អោនចិត្តទៅរកគុណធម៌ដ៏កំពូល គឺអរហត្តផល ។

❋ **សទ្ធា** : ក្នុងទីនេះសំដៅទៅលើការជឿដល់ការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ ។

អត្ថនៃសទ្ធា (នៅក្នុងវិសុទ្ធិមគ្គ ខន្ធនិទ្ទេស លេខ ៣ ជំពូក ១) ទ្រង់ត្រាស់ថា :-

- **នយទី ១ :** បុគ្គលទាំងឡាយ រមែងជឿដោយធម្មជាតិ ហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា សទ្ធា (ប្រែថា ធម្មជាតិជាហេតុជឿ) ។

- **នយទី ២ :** ធម្មជាតិរមែងជឿឯង ហេតុនោះ ធម្មជាតិនោះទើបឈ្មោះថា សទ្ធា (ប្រែថា ធម្មជាតិអ្នកជឿ) ។

- **នយទី ៣ :** ធម្មជាតិត្រឹមតែជាការជឿប៉ុណ្ណោះ ហេតុនោះ ធម្មជាតិនោះទើបឈ្មោះថា សទ្ធា (ប្រែថា ការជឿ) ។

លក្ខណៈនៃសទ្ធា

សទ្ធា មានការជឿជាលក្ខណៈ ឬមានការដាក់ចិត្ត ជាលក្ខណៈក៏បាន ។ មានការធ្វើឱ្យថ្លា ជារស ដូចកែវឧទកបសាទកៈ (កែវធ្វើទឹកឱ្យថ្លា) ឬមានការត្រាច់ទៅ (តាមអារម្មណ៍ជាទីតាំងនៃការជឿ) ជារសក៏បាន ដូចត្រាច់ទៅ (គឺហូរតាមក្រសែទឹកតែមួយគត់) ក្នុងការឆ្លងអន្លង់ ដូច្នោះ ។ មានការមិនល្អក់ស្អាប់ជាបច្ចុប្បដ្ឋាន ឬថាមានអធិមុត្តិ (ការ

ដាច់ចិត្ត) ជាបច្ចុប្បដ្ឋានក៏បាន ។ មានសន្ទេយវត្ថុ (វត្ថុជាទីតាំង នៃការជឿ) ជាបទដ្ឋាន ឬមានសោតាបត្តិយង្គៈ និង សទ្ធម្មស្សវនៈ ជាដើម ជាបទដ្ឋានក៏បាន ។

សទ្ធា បណ្ឌិតគប្បីឃើញ ដូចជាដៃ ដូចជាទ្រព្យ និង ដូចជាពូជយ៉ាងដូច្នោះ ។

នៅក្នុងវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ ជួន-ណាត ជោតញ្ញាណោ សរសេរប្រាប់ថា សទ្ធា អានថា (សត័-ធា) ន. (បា, សំ.ត្រទ្ធា) ជំនឿ ។ ការជឿបុណ្យ, ជឿបាប, ជឿកម្ម, ជឿផល : មានសទ្ធាមុតមាំ, ឱ្យទានដោយសទ្ធា ។ សទ្ធាចេតសិក សទ្ធា ដែលរាប់ជាចេតសិកមួយក្នុងពួកចេតសិក ៥២ (ព.អ) ។ សទ្ធាធិក (បា. <សទ្ធា + អធិក <<ក្រៃលែង, លើសលប់>>) អ្នក ដែលអធិកដោយសទ្ធាគឺ ពោធិសត្វដែលបំពេញបារមី ដោយ សទ្ធាដ៏លើសលុប ។ សទ្ធាធិមុត្តិ (បា. <សទ្ធា + អធិមុត្តិ "ដែលបង្អោនទៅ, ដែលចុះចិត្តស៊ប់") អ្នកដែលចុះចិត្តស៊ុប ក្នុងសទ្ធា អ្នកដែលជឿស៊ុប ។

ដោយសង្ខេប : សទ្ធា មានការជឿចំពោះអារម្មណ៍ ជា លក្ខណៈ មានសេចក្តីជ្រះថ្លា ជាកិច្ច មានការមិនល្អក់ស្អាប់ ជា ផល មានវត្ថុជាទីតាំងនៃការជឿ ជា បទដ្ឋាន ។

✵ **យោនិសោមនសិការ** (ព.ធ.ទំព័រ៦៦៩) ពាក្យថា យោនិសោមនសិការ ប្រកបដោយ យោនិសោ + មនសិការ ។

យោនិសោ មកពី យោនិ ប្រែថា ហេតុខាងដើម ជាប្រភពនាំឱ្យកើតបញ្ញា ឬឧបាយ វិធី ផ្លូវ ។ ចំណែកមនសិការ ប្រែថា: ការធ្វើទុកក្នុងចិត្ត ការគិត ត្រិះរិះ នឹកដល់ ដាក់ចិត្ត ពិចារណា ។ សរុបចូលគ្នា បានជា យោនិសោមនសិការ ប្រែថា : ការធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនង ឬ ការធ្វើទុកក្នុងចិត្ត ដោយល្បិចឆ្លាត ។ ក្នុងគម្ពីរអដ្ឋកថា និង ដីកាបានខៃសេចក្តីទុក ដោយវិធីសម្តែងវចនៈ ឱ្យឃើញនូវសេចក្តីសម្គាល់ជាចំណុចៗ ដូចតទៅ:-

១- ឧបាយមនសិការ ប្រែថា : គិត ឬ ពិចារណាដោយ ឧបាយ គឺគិតមានវិធី ឬគិតត្រូវវិធី បានដល់ គិតឱ្យចូលដល់ ការពិតរហូតចូលគន្លងផ្លូវសច្ចៈ ធ្វើឱ្យដឹងនូវសភាវលក្ខណៈ និង សាមញ្ញលក្ខណៈរបស់ធម៌ទាំងឡាយ ។

២-បថមនសិការ ប្រែថា : គិតជាផ្លូវ ឬគិតត្រូវផ្លូវ គឺគិតទំនាក់ទំនងជាលំដាប់ ចាត់តាមលំដាប់បាន ឬ មានលំដាប់

មានថ្នាក់ ជាជួរតំបន់ ឬ ដង បានដល់ការគិតជារបៀបតាម ហេតុផលជាដើម មិនស្មុគ្រស្មាញច្របូកច្របល់ ។

៣- ការណមនសិការ ប្រែថា គិតតាមហេតុ គិតគួរ ហេតុ គិតតាមហេតុផល ឬគិតមានហេតុផល បានដល់ ការគិត ស្ទើប ស្រាវជ្រាវតាមខ្សែសម្ព័ន្ធនៃហេតុប្បច្ច័យ ស្រាវជ្រាវ រកហេតុ ឱ្យចូលដល់ដើមហេតុឬប្រភព ដែលមានផលទាក់ទង តាមលំដាប់ ។

៤-ឧប្បាទកមនសិការ ប្រែថា គិតឱ្យកើតផល គឺប្រើការ គិតឱ្យកើតផលដែលគប្បីប្រាថ្នាតម្រង់ទៅរកគោលដៅ បានដល់ ការគិតពិចារណាធ្វើឱ្យកើតកុសលធម៌ ដូចជា ធ្វើឱ្យកើតសេចក្តី ព្យាយាម ការដឹងនឹងគិតធ្វើឱ្យបាត់ខ្លាច ឱ្យបាត់ក្រោធការពិចារណា ធ្វើឱ្យមានសតិ ឬធ្វើឱ្យចិត្តសន្តានរឹងមាំ ជាដើម ។

សេចក្តីពិស្តារទាំង ៤ ចំណុចនេះ ប្រាប់ពីការសម្តែង លក្ខណៈ ផ្សេងៗរបស់ការគិតនៃយោនិសោមនសិការ ដែល កើតឡើង មួយគ្រាៗ អាចមានលក្ខណៈគ្រប់ទាំង ៤ ចំណុច ឬជិតនឹងគ្រប់ ទាំងអស់ ប្រសិនបើនឹងសរសេរលក្ខណៈទាំង ៤ ខ្លីៗ គង់បានសេចក្តីថា គិតត្រូវវិធី គិតមានរបៀប គិតមាន ហេតុផល គិតឱ្យកើតកុសល គ្រាន់តែយោនិសោមនសិការ

មិនមែនតួបញ្ញា ខ្លួនឯង ប៉ុន្តែជាបច្ច័យនាំឱ្យកើតបញ្ញា គឺឱ្យ កើតសម្មាទិដ្ឋិ ។ ក្នុងគម្ពីរមិលិន្ទបញ្ហា សម្តែងសេចក្តីចែក ផ្សែងគ្នារវាងយោនិសោ មនសិការជាមួយបញ្ញា ថាប្រការ ដំបូង សត្វតិរច្ឆានទាំងឡាយ ដូចជា ពពែ កេស គោ ក្របី ឱដ្ឋ លា មានមនសិការ (មនសិការ តែមិនជាយោនិសោ) ក៏មិនមាន បញ្ញា ។ ប្រការទី ២ មនសិការ មានលក្ខណៈ នឹកពិចារណា ចំណែកបញ្ញាមានលក្ខណៈដាច់ខាត មនសិការរួបចាប់ការគិត នាំឱ្យកើតបញ្ញាធ្វើការកម្ចាត់កិលេសបាន ដូចជាដៃជួយរើសកួរ ស្រូវទុក ឱ្យដៃស្តាំអ្នកប្រមូលត្រាតែ បានសម្រេច ។ ប្រសិន បើសម្លឹងមើលក្នុងទីនេះ យោនិសោមនសិការក៏គឺមនសិការ ជាប្រភេទធ្វើឱ្យកើតការប្រើ បញ្ញា ព្រមជាមួយ ធ្វើឱ្យបញ្ញា នេះចម្រើនដុះក្រៃលែងឡើង ។

យោនិសោមនសិការ ស៊ីសេចក្តីទូលំទូលាយ គ្របសង្កត់ តាំងតែពីការគិតនឹកក្នុងជួរផ្លូវរបស់សីលធម៌ ការគិតតាមគោល សេចក្តីល្អ និងគោលសេចក្តីពិតផ្សេងៗ ដែលខ្លួនបានសិក្សា ឬ ទទួលការអប់រំ នូវពាក្យទូន្មានកន្លងមក មានការដឹង និងការ យល់ ដូចជា គិតក្នុងផ្លូវចិត្ត គិតស្រឡាញ់ គិតប្រាថ្នាល្អ មានមេត្តា

គិតក្នុងផ្លូវដែលត្រូវជួយឧបត្ថម្ភ គិតក្នុងផ្លូវស្ងាបាប់ ធ្វើការពិត និងមិនចុះចាញ់ជាដើម។

រួមសេចក្តីថា យោនិសោមនសិការ បានដល់ការគិតកម្មាត់អវិជ្ជា និង តណ្ហា។ នៅក្នុងអដ្ឋកថាសំយុត្តនិកាយមហាវារវគ្គ លេខ ៣០/៩៧ យោនិសោមនសិការជាហេតុនាំឱ្យកើតអរិយមគ្គ។

សាវត្ថីនិទាន ម្នាលភិក្ខុទាំងឡាយ យើងមិនលែងឃើញធម៌ដទៃអ្វីមួយ ដែលជាហេតុឱ្យអរិយមគ្គប្រកបដោយអង្គ ៨ ប្រការដែលមិនទាន់កើត ឱ្យកើតឡើង ឬ កើតឡើងហើយរមែងដល់ការចម្រើនបរិបូរណ៍ ដូចជាការដល់ព្រមនៃការធ្វើទុកក្នុងចិត្តដោយឧបាយឆ្លាតឡើយ (ក្រៅពីយោនិសោមនសិការ) គប្បីសង្ឃឹម ឬប្រាថ្នាត្រង់ចំណុចនេះបានថា នឹងចម្រើនអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ និងធ្វើឱ្យច្រើននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកដល់ព្រមដោយការធ្វើទុកក្នុងចិត្ត ដោយឧបាយត្រូវទំនង (យោនិសោមនសិការ) រមែងចម្រើន អរិយមគ្គប្រកបដោយអង្គ ៨ ប្រការ យ៉ាងណា។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះរមែងចម្រើនសម្មាទិដ្ឋិ មានការកម្ចាត់ រាគៈ ជាទីបំផុតមានការកម្ចាត់ទោសៈជាទីបំផុត មានការកម្ចាត់មោហៈជាទីបំផុត។ ល។ រមែងចម្រើនសម្មាសមាធិ មានការកម្ចាត់រាគៈជាទីបំផុត មានការកម្ចាត់ទោសៈ ជាទីបំផុត មានការកម្ចាត់មោហៈជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកដល់ព្រមដោយការធ្វើទុកក្នុងចិត្ត ដោយឧបាយត្រូវទំនង រមែងចម្រើនអរិយមគ្គប្រកបដោយអង្គ ៨ ប្រការយ៉ាងនេះឯង ។

❋ **សតិសម្បជញ្ញៈ** (ការរលឹកដឹងខ្លួន) នៅក្នុងទីឃ-និកាយ បឋកលេខ ១៤/១៧៩ ទ្រង់ត្រាស់ថា បពិត្រ មហារាជ ឯភិក្ខុជាអ្នកប្រកដោយសតិនិងសម្បជញ្ញៈនោះ ដូចម្តេច។ បពិត្រមហារាជ ភិក្ខុក្នុងសាសនានេះ កាលឈានដើរទៅមុខ ឬឈានថយក្រោយ ក៏មានសេចក្តីដឹងខ្លួន កាលបត់លាដៃជើង ក៏មានសេចក្តីដឹងខ្លួន កាលទ្រទ្រង់នូវសង្ឃាដិ បាត្រនិងចីវរ ក៏មានសេចក្តីដឹងខ្លួន កាលបរិភោគ ផឹក ទំពា ជញ្ជក់ជញ្ជាប ក៏ មានសេចក្តីដឹងខ្លួន កាលបន្ទោបង់ ឧច្ចារៈ បស្សាវៈ ក៏មានសេចក្តីដឹងខ្លួន កាលដើរ ឈរ អង្គុយ ដេក ភ្ញាក់ពីដំណេក និយាយស្តី ឬ

ស្បៀម ក៏មានសេចក្តីដឹងខ្លួន។ បពិត្រមហារាជ ភិក្ខុជាអ្នក ប្រកប ដោយសតិ និង សម្បជញ្ញៈ ដោយប្រការ ដូចច្នេះឯង។

ការរលឹកដឹងខ្លួនក្នុងឥរិយាបថណាមួយ ពុំមានសត្វបុគ្គល អ្វីឡើយ មានត្រឹមតែសង្ខារធម៌កើតពីហេតុប្បច្ច័យ គឺ រូបធម៌ នាមធម៌ ធ្វើកិច្ចដោយខ្លួនឯងដែលមាន **សាត្ថកសម្បជញ្ញៈ** (ការកំណត់ដឹងនូវប្រយោជន៍ ឬ មិនប្រយោជន៍ជាមុន) **សប្បាយសម្បជញ្ញៈ** (សេចក្តីសប្បាយក្នុងអារម្មណ៍ដែលប្រព្រឹត្តទៅនោះ) **គោចរសម្បជញ្ញៈ** (កម្មដ្ឋាន ៣៨ ប្រការ ក្នុងទីគោចរ សម្គាល់រូបនាំទៅមិននាំត្រឡប់ មិននាំទៅ មិននាំត្រឡប់ ទាំងនាំទៅទាំងនាំត្រឡប់) **អសម្មោហសម្បជញ្ញៈ** (មិនវង្វេងភ្លេចក្នុងការឈានទៅមុខជាដើម ដោយបរមត្ថធម៌សុទ្ធ គឺធាតុប៉ុណ្ណោះ ដែលមានសេចក្តីពិស្តារនៅក្នុងជីវិតប្រក្រតីភាគីទី ១)។

❋ **ឥន្ទ្រិយសំវរៈ** (ការសង្រួមឥន្ទ្រិយ) គឺរវាំងតាមទ្វារទាំង ៦ ហៅថាសតិសំវរៈជាតួសីល ។ នៅក្នុងវិសុទ្ធិមគ្គសីលនិទ្ទេសភាគ ១/១៤ ក្នុងសំវរសីលទ្រង់លើកយកពីសំវរៈមាន ៥ ។

ក្នុងប្រការថា សំវរៈជាតួសីលនេះ គប្បីជ្រាបថា សំវរៈដោយអាការៈ ៥ គឺ បាដិមោក្ខសំវរៈ សតិសំវរៈ ញាណសំវរៈ ខន្តីសំវរៈ និងវីរិយសំវរៈ ។

អ្វីជាតួសីល ឈ្មោះថា ចេតនាជាតួសីល ដែលជាចេតនាក្នុងកម្មបថ ៧ (កាយកម្ម ៣ + វចីកម្ម ៤) របស់បុគ្គលអ្នកលះទោសមានបាណាតិបាតជាដើម ។ ធម៌ គឺ អនភិជ្ឈា អព្យាបាទ និងសម្មាទិដ្ឋិ ដែលទ្រង់ត្រាស់ទុកដោយន័យថា "ភិក្ខុ លះអភិជ្ឈាមានចិត្តប្រាសចាកអភិជ្ឈា" ដូច្នោះជាដើម ឈ្មោះថា **ចេតសិក-សីល** ។

ក្នុងបដិសម្ភិទា <<សួរថា អ្វីជាតួសីល ឆ្លើយថា ចេតនាជាតួសីល ចេតសិកជាតួសីល សំវរៈជាសីល ការមិនប្រព្រឹត្តកន្លងក៏ជាតួសីល>> ។

អត្ថនៃសីល

នៅសល់បញ្ហាខ្លះ ត្រូវឆ្លើយតទៅទៀត ។ "ដែលហៅថា សីល ព្រោះអត្ថថា ជាសីលនៈ (ឬសគល់)" ឈ្មោះថា សីលនៈគឺកិរិយាប្រមូលរួបរួមទុកយ៉ាងល្អ បានដល់កម្មក្នុងទ្វារមានកាយកម្មជាដើម មិនឱ្យខ្ចាត់ខ្ចាយរាប៉ាត់រាប៉ាយ ដោយរបៀប

របបល្អ ១ ការចូលទៅទទួលទុក បានដល់ ជាទីទទួលរង ដែល ជាទីអាស្រ័យនៃកុសលធម៌ទាំងឡាយ ១ គឺ អាចារ្យអ្នក ដឹងនូវលក្ខណៈនៃសព្ទទាំងឡាយ ឃើញដោយអត្ថ ២ យ៉ាង ប៉ុណ្ណោះ ចំណែកអាចារ្យដទៃៗ ពណ៌នាក្នុងសីលសព្ទនោះទុក ដោយន័យផ្សេងៗ ដូចជា សីលសព្ទ មានអត្ថថា សីរៈ មានអត្ថថា សីសៈ មានអត្ថថា សីតលៈ (ត្រជាក់) មានអត្ថថា សិវៈ (ក្សេម) ដូច្នេះ ជាអាទិ៍ ។ សីល មានអត្ថថា សីលនៈ (ឫសគល់) ជាលក្ខណៈ មានកិរិយាកម្ចាត់ការទ្រុស្តសីល ជារស ឬផល មានការស្អាត ជាបច្ចុប្បដ្ឋាន និងមាន ឱត្តប្បៈហិរិ-ឬហិរោត្តប្បៈ ជាបទដ្ឋាន ។

❋ **សុចរិត ៣** ការសង្រួមឥន្ទ្រិយបានល្អនាំឱ្យមាន សុចរិត ៣ គឺ សុចរិតផ្លូវកាយ ៣, សុចរិតផ្លូវវាចា ៤ និង សុចរិតផ្លូវចិត្ត ៣ ។

- សុចរិត ៣ តាមផ្លូវកាយ គឺមិនប្រព្រឹត្តបាណាតិបាត (មិនសម្លាប់សត្វ) មិនកាន់យកទ្រព្យដែលគេមិនបានឱ្យ ដោយ កាយវាចា មិនប្រព្រឹត្តខុសក្នុងកាម ។

- សុចរិត ៤ តាមផ្លូវវាចា គឺមិនពោលពាក្យភូតភរកុហក មិនពោលពាក្យញុះញង់បំបែកបំបាក់ មិនពោលពាក្យអាក្រក់

ទ្រគោះបោះបោក ដូចជា គេកាប់ចិញ្ចាំដោយពូថៅ និងមិនពោលពាក្យរោយរាយឥតប្រយោជន៍ មិនជាអត្ថ មិនជាធម្មប្រៀប ដូចគេទូងស្គរគ្រាន់តែឱ្យឮសំឡេងប៉ុណ្ណោះ ។

- សុចរិត ៣ តាមផ្លូវចិត្ត គឺអនភិជ្ឈា អព្យាបាទ និងសម្មាទិដ្ឋិ ។ សុចរិតទាំង ៣ នេះ កើតតាមទ្វារ ៦ ត្រូវជា ១៨ ដែលមាននៅក្នុងអដ្ឋកថា កុណ្ឌលិយសូត្រយ៉ាងពិស្តារបញ្ជាក់ជូនថែមទៀត។

❋ **សតិប្បដ្ឋាន ៤:** មានពួកកាយ គឺពិចារណាឃើញកាយក្នុងកាយជាប្រក្រតីគ្រប់តិរិយាបថទាំងបួន មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវ អភិជ្ឈា និង ទោមនស្សក្នុងលោកចេញ។ ពួកវេទនា គឺពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយ ជាប្រក្រតីគ្រប់តិរិយាបថ ៤ ។ល។) ពួកចិត្ត ពិចារណាឃើញចិត្តក្នុងចិត្តជាប្រក្រតី គ្រប់តិរិយាបថ ៤ ។ល។ ពួកធម្ម ពិចារណាឃើញ ធម្មក្នុងធម្មទាំងឡាយជាប្រក្រតី គ្រប់តិរិយាបថទាំង ៤ មានព្យាយាម ជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។

✵ **ពោជ្ឈង្គ ៧ ប្រការ** គឺ សតិសម្ពោជ្ឈង្គ ធម្មវិចយ-សម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ បីតិសម្ពោជ្ឈង្គ បស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យ វិវេកអាស្រ័យនិរោធ បង្អោនទៅក្នុងការលះ មានអត្ថថា ត្រាស់ដឹង ។

✵ **វិជ្ជានិងវិមុត្តិ** មានវិជ្ជាជំនួសអវិជ្ជា (ការមិនដឹងទុក្ខសច្ចៈមិនដឹងសមុទយសច្ចៈ មិនដឹងនិរោធសច្ចៈ និងមគ្គសច្ចៈ) ជាវិមុត្តិ គឺការរួចផុតចាកទុក្ខទាំងពួង ។ ជាបន្តទៅនេះសូមលើកយកព្រះសូត្រឈ្មោះ កុណ្ឌលិយសូត្រនិងអដ្ឋកថា ដែលទ្រង់ត្រាស់សម្តែងពីវិជ្ជានិងវិមុត្តិមកបញ្ជាក់ជូនដោយពិស្តារដូចតទៅនេះ ។

បញ្ជាក់ : នៅក្នុងធម្មាភិសម័យ ដែលទេវតាទាំងឡាយបានសម្រេច មគ្គផល មិនត្រឹមតែបានស្តាប់មង្គលសូត្រមួយនេះទេ នៅមាន ប្រសូត្រដទៃផ្សេងៗទៀតជាច្រើន ដូចជា មហាសម័យ-សូត្រ មង្គលសូត្រ សមចិត្តសូត្រ រាហុលោវាទសូត្រ ធម្មចក្រសូត្រ បរាភវសូត្រ និងទេវតាសមសូត្រ ក៏មិនមែនមានតិចប្រមាណ មិនបាន ។

អដ្ឋកថា សំ.ទសក ឯកាទសកនិបាត ក្នុងអវិជ្ជាសូត្រលេខ ៣៨/២០០ ។

បទថា វិជ្ជាវិមុត្តិ បានដល់ ផលញាណ ។

បទថា ពោជ្ឈង្គា បានដល់ អង្គនៃបញ្ញា គ្រឿងត្រាស់ដឹងគឺមគ្គ ។

បទថា អាហារ បានដល់ មានបច្ច័យ ។

កុណ្ឌលិយសូត្រ

ឥថាគតចាតវិជ្ជានិងវិមុត្តិជាអានិសង្ស

(អដ្ឋកថា សំ.មហាវារវគ្គ លេខ៣០/២០២)

សម័យមួយ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ប្រថាប់នៅព្រៃអញ្ជនមិគទាយ (ជាទីឱ្យអភ័យដល់ម្រឹគ) ជិតទីក្រុងសាកេត ។ គ្រានោះឯង កុណ្ឌលិយបរិព្វាជក ចូលទៅគាល់ព្រះដ៏មានព្រះភាគជាម្ចាស់ដល់ទីទ្រង់ប្រថាប់ បានប្រាស្រ័យជាមួយព្រះដ៏មានព្រះភាគជាម្ចាស់ លុះការប្រាស្រ័យល្មមឱ្យរលឹកដល់គ្នា និងគ្នាហើយ ទើបអង្គុយនៅទីដ៏សមគួរម្ខាង ។ រួចហើយបានក្រាបទូលព្រះដ៏មានព្រះភាគជាម្ចាស់ថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គចូលចិត្តធ្វើដំណើរទៅក្នុងអារាម និងចូលទៅក្នុងទីប្រជុំជន នេះជាហេតុការណ៍របស់ខ្ញុំព្រះអង្គក្រោយពីបរិភោគអាហារពេលព្រឹករួច ខ្ញុំព្រះអង្គតែងដើរទៅរឿយៗ ត្រាច់ពីឧទ្យានមួយទៅកាន់ឧទ្យានមួយ ។ នៅទីនោះ ខ្ញុំព្រះអង្គឃើញសមណព្រាហ្មណមួយពួក កំពុងពោលពីការដោះវាទៈថាយ៉ាងដូច្នេះ ជាអានិសង្ស ហើយក៏មានការអាក់អន់ចិត្ត ជាអានិសង្ស ចំណែកព្រះគោតមមានអ្វី ជាអានិសង្ស ។ ព្រះដ៏មានព្រះភាគ

ជាម្ចាស់ទ្រង់ត្រាស់ឆ្លើយថា ម្នាល កុណ្ឌលិយៈ តថាគតមានវិជ្ជា និងវិមុត្តិជាផលានិសង្ស ។

ក- បពិត្រព្រះគោតមដ៏ចម្រើន ធម៌ទាំងនោះណា ដែលបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ រមែងញុំាងវិជ្ជានិងវិមុត្តិឱ្យបរិបូណ៌យ៉ាងដូចម្តេចខ្លះ?

ព- ម្នាលកុណ្ឌលិយៈ ពោជ្ឈង្គ ៧ ដែលបុគ្គលចម្រើនហើយធ្វើឱ្យច្រើនហើយ រមែងញុំាងវិជ្ជា និងវិមុត្តិឱ្យបរិបូណ៌ ។

ក- បពិត្រព្រះគោតមដ៏ចម្រើន ធម៌ទាំងនោះណាដែលបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ រមែងញុំាងពោជ្ឈង្គ ៧ ឱ្យបរិបូណ៌ ។

ព- ម្នាលកុណ្ឌលិយៈ សតិប្បដ្ឋាន ៤ ដែលបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ រមែងញុំាងពោជ្ឈង្គ ៧ ឱ្យបរិបូណ៌ ។

ក- បពិត្រព្រះគោតមដ៏ចម្រើន ធម៌ទាំងនោះណា ដែលបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ រមែងញុំាងសតិប្បដ្ឋាន ៤ ឱ្យពេញបរិបូណ៌ ។

ព- សុចរិត ៣ ដែលបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ រមែងញុំាងសតិសប្បដ្ឋាន ៤ ឱ្យពេញបរិបូរណ៌ ។

ក- បពិត្រព្រះគោតមដ៏ចម្រើន ធម៌ទាំងនោះណា ដែលបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ រមែងញុំាងសុចរិត ៣ ឱ្យពេញបរិបូរណ៌។

ខ- ម្នាលកុណ្ឌលិយៈ ឥន្ទ្រិយសំវរៈដែលបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ រមែងញុំាងសុចរិត ៣ ឱ្យពេញបរិបូណ៌។

ឥន្ទ្រិយសំវរៈដែលបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ យ៉ាងណា រមែងញុំាងសុចរិត ៣ ឱ្យបរិបូណ៌ ។

ម្នាលកុណ្ឌលិយៈ ភិក្ខុ ក្នុងធម្មវិន័យនេះឃើញរូបជាទីគាប់ចិត្ត ដោយចក្ខុហើយ រមែង មិនត្រេកអរ មិនខឹង ឬស្អប់ មិនធ្វើសេចក្តីប្រាថ្នាឱ្យកើតឡើង នាមកាយរបស់អ្នកនៅដដែល ចិត្តក៏ដដែល តាំងមាំល្អនៅខាងក្នុង រួចផុតស្រឡះដោយល្អ ។ ម្យ៉ាងទៀត អ្នកឃើញរូប ដែលមិនជាទីគាប់ចិត្តដោយចក្ខុហើយ ធ្វើហាក់ដូចជាមិនដឹង មិនមានចិត្តតាំងនៅដោយអំណាចកិលេស មិនខូចចិត្ត មានចិត្ត មិនព្យាបាទ ចំណែកនាមកាយរបស់អ្នកនៅដដែល ចិត្តក៏ដដែលតាំងមាំល្អនៅខាងក្នុង រួចផុតស្រឡះដោយល្អ ។

ប្រការមួយទៀត ភិក្ខុស្តាប់សំឡេងដោយត្រចៀក។ ល។ ហិតក្លិនដោយច្រមុះ ។ល។ ភ្លក្សរសជាតិដោយអណ្តាត ។ល។

ប៉ះពាល់ផោដ្ឋព្វៈ ដោយកាយ ។ ល។ ដឹងច្បាស់នូវធម្មារម្មណ៍ដែលពេញចិត្តដោយមនោហើយ រមែងមិនត្រេកអរ មិនខឹងស្អប់ មិនញុំាងសេចក្តីប្រាថ្នាឱ្យកើតឡើង ចំណែកនាមកាយរបស់អ្នកនៅដដែល ចិត្តក៏នៅដដែល តាំងមាំល្អនៅខាងក្នុង រួចផុតស្រឡះដោយល្អ ។ ម្យ៉ាងទៀតអ្នកដឹងនូវធម្មារម្មណ៍ដែលមិនពេញចិត្តដោយចិត្តហើយ ធ្វើដូចជា មិនដឹង មិនមានចិត្ត តាំងនៅដោយអំណាចកិលេស មិនខូចចិត្ត មានចិត្តមិនព្យាបាទ ចំណែកនាមកាយរបស់អ្នកនៅដដែល ចិត្តក៏នៅដដែល តាំងមាំល្អនៅខាងក្នុង រួចផុតស្រឡះដោយល្អ ។

ម្នាលកុណ្ឌលិយៈ ព្រោះហេតុដែលភិក្ខុឃើញរូបដោយចក្ខុហើយជាអ្នកនៅដដែល មិនខូចចិត្តមានចិត្តមិនព្យាបាទ ព្រោះរូបដែលពេញចិត្ត និងមិនពេញចិត្ត នាមកាយរបស់អ្នកនៅដដែល ចិត្តនៅដដែលតាំងមាំនៅខាងក្នុង រួចផុតស្រឡះហើយ ភិក្ខុឮសំឡេងដោយសោតៈ ។ ល។ ហិតក្លិនដោយច្រមុះ។ ល។ ភក្សរស ដោយជិវ្ហា ។ ល។ ប៉ះខ្ចប់ផោដ្ឋព្វៈដោយកាយ ។ល។ ដឹងធម្មារម្មណ៍ដោយចិត្តហើយ ជាអ្នកនៅដដែលមិនខូចចិត្ត មានចិត្ត មិនព្យាបាទព្រោះធម្មារម្មណ៍ដែលពេញចិត្តនិងមិនពេញចិត្ត ចំណែកនាមកាយរបស់អ្នកនៅដដែល ចិត្តក៏នៅដដែល តាំងមាំ

ល្អនៅខាងក្នុង រួចផុតស្រឡះល្អហើយ ម្នាលកុណ្ឌលិយៈ ឥន្ទ្រិយសំវរៈ ដែលបុគ្គលចម្រើន ធ្វើឱ្យច្រើនហើយយ៉ាងនេះឯង រមែង ញុំាងសុចរិត ៣ ឱ្យបរិបូណ៌ ។

ម្នាលកុណ្ឌលិយៈ ក៏សុចរិតទាំងនោះ ដែលបុគ្គលចម្រើន ហើយធ្វើឱ្យច្រើនយ៉ាងណា រមែងញុំាងសតិប្បដ្ឋាន ៤ ឱ្យបរិបូណ៌ ។

ភិក្ខុក្នុងធម្មវិន័យនេះ ចម្រើនកាយសុចរិត ដើម្បីលះកាយទុច្ចរិត ចម្រើនវចីសុចរិត ដើម្បីលះវចីទុច្ចរិត ចម្រើនមនោ-សុចរិត ដើម្បីលះមនោទុច្ចរិត ។ សុចរិត ៣ ដែលបុគ្គលចម្រើន ធ្វើឱ្យច្រើនហើយ យ៉ាងនេះឯង រមែងញុំាងសតិប្បដ្ឋាន ៤ ឱ្យ បរិបូណ៌ ។

ម្នាលកុណ្ឌលិយៈ សតិប្បដ្ឋាន ៤ ដែលបុគ្គលចម្រើន ហើយធ្វើឱ្យច្រើនយ៉ាងណា រមែងញុំាងពោជ្ឈង្គ ៧ ឱ្យបរិបូណ៌ ។

ភិក្ខុក្នុងធម្មវិន័យនេះ រមែងពិចារណាឃើញកាយ ក្នុងកាយរឿយៗ មានសេចក្តីព្យាយាម មានសម្បជញ្ញៈ មានសតិ គប្បីកម្ចាត់អភិជ្ឈា និងទោមនស្សក្នុងលោកចេញបាន រមែង ពិចារណាឃើញវេទនា ក្នុងវេទនារឿយៗ ។ល។ រមែងពិចារណា ឃើញចិត្តក្នុងចិត្តរឿយៗ ។ល។ រមែងពិចារណា ឃើញធម៌

ក្នុងធម៌រឿយៗ មានសេចក្តីព្យាយាម មានសម្បជញ្ញៈ មានសតិគប្បីកម្ចាត់អភិជ្ឈា និងទោមនស្សក្នុងលោកចេញបាន ។

ម្នាលកុណ្ឌលិយៈ សតិប្បដ្ឋាន ៤ ដែលបុគ្គលចម្រើនហើយធ្វើឱ្យច្រើនយ៉ាងនេះឯង រមែងញុំាងពោជ្ឈង្គ ៧ ឱ្យបរិបូណ៌ ។

ម្នាលកុណ្ឌលិយៈ ពោជ្ឈង្គ ៧ ដែលបុគ្គលចម្រើនហើយធ្វើឱ្យច្រើនយ៉ាងណា រមែងញុំាងវិជ្ជា និងវិមុត្តិឱ្យបរិបូណ៌ ។

ភិក្ខុក្នុងធម្មវិន័យនេះ រមែងចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យ វិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅក្នុងការលះ ។ល។ រមែងចម្រើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅក្នុងការលះ ។ ម្នាលកុណ្ឌលិយៈ ពោជ្ឈង្គដែលបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយយ៉ាងនេះឯង រមែងញុំាងវិជ្ជា និងវិមុត្តិឱ្យសម្បូរណ៌ ។

ពេលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ កុណ្ឌលិយបរិព្វាជកបានក្រាបទូល ព្រះដ៏មានព្រះភាគជាម្ចាស់ថា បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គជាក់ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គជាក់ច្បាស់ណាស់ ព្រះគោតមទ្រង់ប្រកាសធម៌ដោយអនេកបរិយាយ ប្រៀបដូចបុគ្គលផ្ងាររបស់ដែលផ្កាប់ បើករបស់ដែលបិទ ប្រាប់

ផ្លូវដល់អ្នកវង្វេង ឬអុចប្រទីបក្នុងទីងងឹត ដោយប្រាថ្នាថា អ្នក
មានចក្ខុនឹងឃើញរូបបាន ដូច្នោះខ្ញុំព្រះអង្គសូមដល់ព្រះគោតម
ជាមួយព្រះធម៌ និងព្រះសង្ឃថា ជាសរណៈ សូមព្រះគោតម
ចូរទ្រង់ជ្រាបខ្ញុំព្រះអង្គថា ជាឧបាសក អ្នកដល់សរណៈអស់មួយ
ជីវិតចាប់ដើមពីថ្ងៃនេះតទៅ ។

អដ្ឋកថាកុណ្ឌលិយសូត្រ

សំ.មហាវារវគ្គ លេខ ៣០/២០៥

គប្បីជ្រាបវិនិច្ឆ័យក្នុងកុណ្ឌលិយសូត្រទី៦

បទថា **អារាមនិយាតិ** បានដល់ ឈ្មោះថា ត្រាច់ទៅក្នុង
អារាម ព្រោះអាស្រ័យអារាមជាទីត្រាច់ទៅ ។ បទថា **បរិសាយចរោ**
បានដល់ ត្រាច់ទៅក្នុងបរិស័ទ ។ ជនពាលខ្លះ បណ្ឌិតខ្លះ មករួម
គ្នា ឈ្មោះថា បរិស័ទ ។ ចំណែកអ្នកណា រមែងអាចញុំាញីវាទៈ
របស់អ្នកដទៃហើយ ទើបសម្តែងវាទៈរបស់ខ្លួនបាន អ្នកនោះ
ឈ្មោះថា ត្រាច់ទៅក្នុងបរិស័ទ ។ បទថា **អារាមេន អារាមំ**
សេចក្តីថា ខ្ញុំម្ចាស់ធ្វើដំណើរទៅរឿយៗ ចំពោះអារាម ពីអារាម
អធិប្បាយថា មិនបានដើរទៅខាងក្រៅ សូម្បីក្នុងឧទ្យានក៏មាន
ន័យដូចគ្នា ។ ក្នុងចំណុចនេះមានខ្លឹមសារថា ចូលទៅអារាម

មួយ ចេញពីអារាមមួយ ចូលទៅឧទ្យានមួយ ចេញពីឧទ្យានមួយ ។ បទថា **ឥតិ ទាឧប្បមោក្ខានិសំសំ** សេចក្តីថា វាទៈ ដូច្នេះ ការដោះវាទៈ ដូច្នេះ ដោយន័យថា ការសួរមានយ៉ាងនេះ ការឆ្លើយមានយ៉ាងនេះ ការកាន់យកសេចក្តីយ៉ាងនេះ ខៃសេចក្តីយ៉ាងនេះ ដូចនេះ ជាអានិសង្ស ។ បទថា **ឧបារម្ភានិសំសំ** បានដល់ មានទោសក្នុងវាទៈជាអានិសង្ស យ៉ាងនេះថា នេះជាទោសក្នុងការសួរ នេះជាទោសក្នុងការឆ្លើយដូច្នេះ ។ ឈ្មោះថា **កថំ តាទិកោ កុណ្ឌលិយ ឥន្ទ្រិយសំទរោ** សេចក្តីថា ព្រះសាស្តាទ្រង់ដឹងថា បរិព្វាជកសួរ ឋានៈមានប្រមាណប៉ុណ្ណេះ ហើយ ពេលនេះ គេមិនអាចនឹងសួរទៀត ពេលទ្រង់សួរ ទើបទ្រង់ផ្តើមទេសនា ដោយទ្រង់ត្រិះរិះថា ត្រាដំបូងទេសនានេះ មិនប្រព្រឹត្តទៅតរៀងគ្នា ឥឡូវនេះ យើងនឹងឱ្យទេសនាតរៀងគ្នា ។

ក្នុងបទទាំងនោះ បទថា **មនាបំ នាភិឡ្យាយតិ** បានដល់ រមែងមិនសម្លឹងអារម្មណ៍ដែលគួរប្រាថ្នា ។ បទថា **នាទិហឺសតិ** បានដល់ រមែងមិនប្រៀតប្រៀន ដោយសេចក្តីត្រេកអរដែលមានអាមិស ។ បទថា **តស្ស ទិកោ ច ការយោ ហោតិ ឋិតំ**

ចិត្តំ អជ្ឈត្តំ សេចក្តីថា នាមកាយ និងចិត្តរបស់អ្នកតាំងនៅក្នុងអារម្មណ៍ ។ បទថា **សុសណ្ឋិតំ** បានដល់ តាំងមាំយ៉ាងល្អ ដោយអំណាចកម្មដ្ឋាន ។ បទថា **សុវិមុត្តំ** បានដល់ ផុតស្រឡះ យ៉ាងល្អដោយកម្មដ្ឋាន ។ បទថា **អមនាបំ** បានដល់ អារម្មណ៍ ដែលមិនគួរប្រាថ្នា ។ បទថា **ន មក្ខុ ហោតិ** បានដល់ រមែង មិនធ្វើដូចជា មិនដឹង ក្នុងរូបនោះ ។ បទថា **អប្បតិដ្ឋិតចិត្តោ** បានដល់ មានចិត្ត មិនតាំងនៅដោយអំណាចកិលេស ។ បទថា **អនិន្ទូមានសោ** បានដល់ មានចិត្តដែលកិលេសប្រកាន់ ដោយអំណាចទោមនស្សមិនបាន ។ បទថា **អព្យាបន្នចេតសោ** បានដល់ មានចិត្តមិនតាំងនៅដោយអំណាចទោសៈ ។

☞ ក្នុងបទថា **ឯវម្ភាវិតោ ខោ កុណ្ឌលិយ ឥន្ទ្រិយសំវរោ ឯវំ ពហុលីកតោ តីណិ សុចរិតានិ បរិបូរេតិ** តប្បីជ្រាបការញុំាងសុចរិតឱ្យបរិបូណ៌យ៉ាងនេះ ។ ទុច្ចរិត ទាំងឡាយមាន ១៨ ក្នុងទ្វារ ៦ សួរថា មានយ៉ាងណា? ឆ្លើយថា ពេលមិនទាន់ឱ្យកាយនិងវាចាកម្រើកនៅពេលមាន

អារម្មណ៍គួរប្រាថ្នា មកដល់គន្លងចក្ខុទ្វារមុនដំបូង ក៏ញុំាងសេចក្តី
លោភឱ្យកើតឡើងក្នុងអារម្មណ៍នោះ ចាត់ជា មនោទុច្ចរិត ។
ពេលនិយាយមានចិត្តប្រកបដោយសេចក្តីលោភថា ឱប្ពុំ របស់
នេះគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ដូចនេះ ចាត់ជា
វចីទុច្ចរិត នៅពេលយកដៃចាប់ត្រូវរបស់ទាំងនោះ ចាត់ជា
កាយទុច្ចរិត សូម្បីក្នុងទ្វារ ដែលនៅសល់ក៏មាន ន័យនេះដូចគ្នា ។

ចំណែកសេចក្តីផ្សេងគ្នា ដូចនេះ ដោយថា នៅពេលចាប់
ត្រូវគ្រឿងតន្ត្រីមានស័ង្ខនិងបណ្តោះជាដើម ជាអនាមាសដែល
ជាទីតាំងរបស់សទ្ទារម្មណ៍ ក្នុងសោតទ្វារ ចាប់ត្រូវគ្រឿងក្រអូប
និងផ្កាជាដើម ដែលជាទីតាំងរបស់គន្ធារម្មណ៍ ក្នុងឃានទ្វារ
ចាប់ត្រូវ ត្រី និងសាច់ជាដើម ដែលជាទីតាំងរបស់រសារម្មណ៍
ក្នុងជិវ្ហាទ្វារ ចាប់ត្រូវចីវរជាដើម ដែលជាទីតាំងរបស់ផោដ្ឋព្វារម្មណ៍
ក្នុងកាយទ្វារ ពេលចាប់ត្រូវខ្លាញ់ប៊ីរ ប្រេង ទឹកឃ្មុំ និង
ទឹកអំពៅ ជាដើម ដែលជាធម្មារម្មណ៍ដោយអំណាចនៃបញ្ញត្តិ
ក្នុងមនោទ្វារ គប្បី ជ្រាបថា ជាកាយទុច្ចរិត ។ ប្រសិនបើពោល
ដោយសង្ខេប ក្នុងចំណុចនេះ មាន ទុច្ចរិត ៣ ប៉ុណ្ណោះ គឺការ

ល្អើសផ្លូវកាយក្នុងទ្វារ ៦ ចាត់ជា កាយទុច្ចរិត ការល្អើស ផ្លូវ
វាចា ចាត់ជា វចីទុច្ចរិត ការល្អើសផ្លូវចិត្ត ចាត់ជា មនោទុច្ចរិត ។

☞ ចំណែកភិក្ខុ តាំងមាំនៅក្នុងការពិចារណាភាវនា
របស់ខ្លួន រមែងប្រព្រឹត្តសុចរិតទាំងនេះ ឱ្យជាសុចរិតធម៌ ។
សួរថា ប្រព្រឹត្តយ៉ាងណា ? ឆ្លើយថា ពេលមិនទាន់ញុំាងកាយ
និងវាចាឱ្យកម្រើក ពេលមានអារម្មណ៍ដែលគួរប្រាថ្នាមកដល់
គន្លង ចក្ខុទ្វារមុនដំបូង ប្រាថ្នានូវិបស្សនា ដែលមានរូបជា
អារម្មណ៍ ចាត់ជា មនោសុចរិត ។ ពេលនិយាយមានចិត្ត
ប្រកបដោយវិបស្សនា ថា មានការអស់ទៅជាធម្មតា មានការ
វិនាសទៅជាធម្មតា ចាត់ជា វចីសុចរិត ។ ពេលមិនទាន់ចាប់ត្រូវ
ដោយគិតថា របស់នេះជា អនាមាស ចាត់ជាកាយសុចរិត
សូម្បីក្នុងទ្វារដែល នៅសល់ក៏មានន័យនេះដូចគ្នា ។ ប្រសិនបើ
ពោលដោយពិស្តារ សុចរិត មាន ១៨ តាមទ្វារ ដែលនៅសល់
មានប្រការដូច្នេះ ប៉ុន្តែដោយសង្ខេប ក្នុងប្រការនេះមានសុចរិត
៣ ប៉ុណ្ណោះ គឺការសង្រួមផ្លូវកាយក្នុងទ្វារទាំង ៦ ចាត់ជា កាយ
សុចរិត ការសង្រួមផ្លូវវាចា ចាត់ជា វចីសុចរិត និងការសង្រួម
ផ្លូវចិត្ត ចាត់ជាមនោសុចរិត ។ ការសង្រួមឥន្ទ្រិយយ៉ាងនេះ គប្បី

ជ្រាបថា រមែងញុំាងសុចរិត ៣ ឱ្យបរិបូណ៌ គឺលោកពោលដល់ឥន្ទ្រិយសំវរសីល ដែលសីលតាមរក្សាហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

ក្នុងបទជាដើមថា **កាយទុច្ចរិតំ បហាយ** បានដល់កាយទុច្ចរិត ៣ យ៉ាង វចីទុច្ចរិត ៤ យ៉ាង និងមនោទុច្ចរិត ៣ យ៉ាង ។ គប្បីជ្រាបកាយសុចរិតជាដើម ដោយអំណាចផ្តុំយកគ្នាពីកាយទុច្ចរិតនោះ ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ រមែងពោលដល់បាដិមោក្ខសំវរសីល ក្នុងការសង្រួមផ្លូវកាយ និងផ្លូវវាចា ។ សីល ៣ មានការសង្រួមផ្លូវចិត្ត រមែង ពោលដល់ចតុប្បារិសុទ្ធិសីល ចំណែកក្នុងសូត្រនេះទាំងអស់ គប្បីជ្រាបថា លោកពោលដល់សតិប្បដ្ឋានមានសុចរិតជាមូល លាយឡំជាមួយលោកុត្តរៈ ។ សតិប្បដ្ឋានជាមូលនៃពោជ្ឈង្គ ៧ ថា ជាបុព្វភាគពោជ្ឈង្គមានសតិប្បដ្ឋានជាមូល ថាជាបុព្វភាគ សូម្បីទាំងអស់នោះ ក៏ពោលថា ជាបុព្វភាគ ។ ចំណែកពោជ្ឈង្គ ដែលជាមូលនៃវិជ្ជានិងវិមុត្តិ គប្បីជ្រាបថា លោកពោលជា លោកុត្តរៈពិត ។

សតិប្បដ្ឋាន

(ជំហានទី៩)

ជីវិតប្រក្រតីរស់តាមធម្មតា ចូលចិត្តស្រាវជ្រាវរកការពិត នៅក្នុងពួកកាយានុបស្សនាសតិប្បដ្ឋាន ដែលបានសរសេរជម្រាបជូនពីអានាបាណបព្វៈ ឥរិយាបថបព្វៈ សម្បជញ្ញបព្វៈ បដិកូល-មនសិការបព្វៈ និងធាតុមនសិការបព្វៈ នៅក្នុងជីវិតប្រក្រតីភាគទី១ ក៏ឥឡូវនេះនឹងសូមលើកយក នវសីវថិកាបព្វៈ មកអធិប្បាយឱ្យបានល្អិតល្អន់ដូចតទៅ ។ មុននិងចូលដល់ នវសីវថិកាបព្វៈ សូមរំលឹកនូវបទខាងដើមថា :-

ឥធ ភិក្ខវេ ភិក្ខុ ការយេ កាយា នុបស្សី
ឥហរតិ អាតាបី សម្បជានោ សតិមា
ឥនេយ្យលោកេ អភិជ្ឈាទោមនស្សំ ។

ប្រែថា : ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស

ក្នុងលោកចេញដែលមាន (នៅក្នុងទីឃនិកាយ មហាវគ្គបិដក លេខ ១៧/២៤៥) ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុឃើញនូវសរីរៈស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន ទោះស្លាប់អស់ ១ ថ្ងៃក្តី ស្លាប់អស់ ២ ថ្ងៃក្តី ស្លាប់អស់ ៣ ថ្ងៃក្តី ដែលកំពុងហើមមានសម្បុរខៀវ ដោយច្រើនមានខ្ទុះហូរចេញតាមទ្វារផ្សេងៗ ដូចម្តេចមិញ ។ ភិក្ខុនោះ (ក៏បង្អោនសរីរៈស្លាប់នោះ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយ[1] នេះ សោត ក៏គង់នឹងមានសភាពដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះនឹងកន្លង នូវភាវៈដូច្នោះពុំបានឡើយ ។ ភិក្ខុពិចារណាឃើញនូវកាយក្នុង កាយខាងក្នុងជាប្រក្រតី (ដោយការកំណត់នូវអសុភមាន អសុភកំពុងហើមជាដើម) ត្រប់តិរិយាបថទាំង ៤ យ៉ាងនេះឯង ។ល។

---

(១) អដ្ឋកថា ថា បានដល់កាយដែលនៅមានធម៌ ៣ ប្រការ គឺអាយុ ១ កម្មរូលភ្លើងធាតុ១ វិញ្ញាណ ១ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានឡើត ភិក្ខុ
គប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោលនៅក្នុងព្រៃស្មសាន
ដែលក្អែកទាំងឡាយកំពុងចឹកស៊ីក្តី ត្រដក់ គម្រង់ទាំងឡាយ
កំពុងកកេរស៊ីក្តី ឆ្កែតទាំងឡាយកំពុងចឹកស៊ីក្តី សត្វស្វាន ទាំង
ឡាយកំពុងចឹកស៊ី ចចកទាំងឡាយកំពុងកកេរស៊ីក្តី បាណកជាតិ
(សត្វល្អិតៗ មានរុយជាដើម) ទាំងឡាយផ្សេងៗ កំពុងរួង
ជញ្ជក់ស៊ីក្តីដូចម្តេចមិញ។ ភិក្ខុនោះ (ក៏បង្អោនសរីរៈ ស្លាប់នោះ)
មកប្រៀបនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹង
មានសភាវៈយ៉ាងដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវ
ភាវៈដូច្នោះ ពុំបានឡើយ។ ភិក្ខុ ពិចារណាឃើញនូវកាយក្នុង
កាយខាងក្នុងជាប្រក្រតី ដោយការកំណត់នូវអសុភមានអសុភ
ដែលពួកសត្វកំពុងចឹកស៊ីជាដើម គ្រប់តិរិយាបថទាំង ៤ យ៉ាង
នេះផង ពិចារណា ឃើញនូវកាយក្នុងកាយខាងក្រៅ ជាប្រក្រតី
គ្រប់តិរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយ ក្នុងកាយ
ខាងក្នុង និងខាងក្រៅជាប្រក្រតីគ្រប់តិរិយាបថទាំង ៤ ផង
ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង ក្នុងកាយជា
ប្រក្រតីគ្រប់តិរិយាបថទាំង ៤ ផង ពិចារណាឃើញ នូវធម៌ដែល
សូន្យទៅក្នុងកាយជាប្រក្រតី គ្រប់តិរិយាបថទាំង ៤ ផង

ពិចារណាឃើញនូវធម៌ ដែលប្រជុំកើតឡើង និងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់តិរិយាបថទាំង (៤) ផង ។ មួយទៀតស្មារតីរបស់ភិក្ខុនោះ ក៏ផ្ងង់ឡើងចំពោះថា កាយមានមែនគ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្ត មិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់តិរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់តិរិយាបថទាំង ៤ យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន សល់នៅតែរាងឆ្អឹងប្រឡាក់ដោយសាច់និងឈាម មានសរសៃជាគ្រឿងចងដូចម្តេចមិញ ។ ល ។

សរីរៈនៅសល់តែរាងឆ្អឹង ឥតមានសាច់ប្រឡាក់ដោយឈាម មានសរសៃជាគ្រឿងចង ។ល ។

សរីរៈនៅសល់តែរាងឆ្អឹង មិនមានសាច់និងឈាម មានតែសរសៃជាគ្រឿងចង ។ល ។

សរីរៈនៅសល់តែរាងឆ្អឹងទទេ មិនមានសរសៃចងរួបរឹតខ្ជាត់ខ្ជាយរត់រាយ ទៅក្នុងទិសតូច និងទិសធំ គឺឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះទៅដោយឡែក ឆ្អឹងខ្នងទៅដោយឡែក ឆ្អឹងទ្រនុងខ្នងទៅដោយឡែក ឆ្អឹងជំនីរទៅដោយឡែក ឆ្អឹងទ្រូងទៅដោយឡែក ឆ្អឹងស្មាទៅដោយឡែក ឆ្អឹងកំភួនដៃទៅដោយឡែក ឆ្អឹងកទៅដោយឡែក ឆ្អឹងចង្កាទៅដោយឡែក ធ្មេញទៅដោយឡែក លលាដ៏ក្បាលទៅដោយឡែក (ដូចម្តេចមិញ) ។ ភិក្ខុនោះ (ក៏បង្អោនសរីរៈស្លាប់នោះ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាវៈដូច្នោះ គង់នឹងក្លាយទៅជា ដូច្នោះ នឹងកន្លងនូវភាវៈដូច្នោះពុំបានឡើយ ។ ភិក្ខុពិចារណាឃើញ នូវកាយក្នុងកាយខាងក្នុងជាប្រក្រតី (ដោយការកំណត់នូវសរីរៈស្លាប់ដែលនៅសល់តែរាងឆ្អឹងជាដើម) គ្រប់តិរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញ នូវកាយក្នុងកាយ ខាងក្រៅជាប្រក្រតីគ្រប់តិរិយាបថទាំង ៤ ផង ពិចារណាឃើញកាយក្នុងកាយ ខាងក្នុងនឹងខាងក្រៅជាប្រក្រតី គ្រប់តិរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងកាយជាប្រក្រតីគ្រប់តិរិយាបថ

ទាំង ៤ ផង ពិចារណាឃើញ នូវធម៌ដែលសូន្យទៅក្នុងកាយជា ប្រក្រតី គ្រប់តរិយាទាំង ៤ ផង ពិចារណាឃើញ នូវធម៌ដែល ជាទីប្រជុំកើតឡើង និងធម៌ដែលសូន្យទៅក្នុងកាយ ជាប្រក្រតី គ្រប់តរិយាបថទាំង ៤ ផង។ មួយទៀតស្មារតីរបស់ភិក្ខុ ក៏ផ្ងង់ ឡើងចំពោះថា កាយនេះមានមែន គ្រាន់តែជាទីកំណត់ ដើម្បី ឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ភិក្ខុមានចិត្តមិន អាស្រ័យ (ដោយ តណ្ហា និងទិដ្ឋិ) គ្រប់តរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់ អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុពិចារណា ឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់តរិយាបថទាំង ៤ ផង យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុ គប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន សល់នៅ តែឆ្អឹងទទេ មាន សម្បុរ ស ដូចជាសម្បុរនៃស័ង្ខ ។ល។

សរីរៈសល់នៅតែឆ្អឹងទទេ រោយរាយជាពំនូត៧កន្លងហួស ទៅមួយឆ្នាំហើយ ។ល។

សរីរៈសល់នៅតែឆ្អឹងទទេ ពុកផុយខ្ទេចខ្ទី ជាកម្ទេចតូច កម្ទេចធំផ្សេង។ (ដូចម្តេចមិញ) ។ ភិក្ខុនោះ (ក៏បង្ហោនសរីរៈ ស្លាប់នោះ) មកប្រៀប នឹងកាយនេះឯងថា សូម្បីកាយនេះសោត

ក៏គង់ នឹងមានសភាវៈដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវសភាវៈដូច្នោះពុំបានឡើយ ។ ភិក្ខុ ពិចារណាឃើញនូវកាយក្នុងកាយ ខាងក្នុងជាប្រក្រតីគ្រប់តិរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយ ខាងក្រៅជាប្រក្រតីគ្រប់តិរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយ ខាងក្នុង និងខាងក្រៅ ជាប្រក្រតី គ្រប់តិរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលជាទីប្រជុំកើតឡើងក្នុងកាយ ជាប្រក្រតីគ្រប់តិរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលសូន្យទៅក្នុងកាយជា ប្រក្រតីគ្រប់តិរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលជាទីប្រជុំកើតឡើង និងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់តិរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ដង់ឡើងចំពោះថា កាយនេះមានមែនគ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុ មានចិត្តមិនអាស្រ័យ (ដោយ តណ្ហា និងទិដ្ឋិ) គ្រប់តិរិយាបថទាំង ៤ មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយ ជាប្រក្រតី គ្រប់តិរិយាបថទាំង ៤ យ៉ាងនេះឯង ។

អដ្ឋកថា

អ.មូលបណ្ណាសក លេខ ១៧/៧២៣

ព្រះដ៏មានព្រះភាគជាម្ចាស់ នៅពេលទ្រង់ចែកកាយានុបស្សនា ដោយអំណាចការមនសិការដល់ធាតុយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែក **ឆឝសីឝថិកាបព្វៈ** (ធម៌ដែលពោលពីព្រៃខ្មោច ៩) ទើបត្រាស់ពាក្យជាដើមថា **បុន ច បរំ** ដូចនេះ។

បណ្តាបទទាំងនោះ បទថា **សេយ្យថាបិ បស្សេយ្យ** បានដល់ **យថា បស្សេយ្យ** (ប្រែថា គប្បីឃើញយ៉ាងណា) ។

បទថា **សរីរំ** បានដល់រាងកាយរបស់អ្នក ដែលបានស្លាប់ហើយ ។

បទថា **សីឝថិកាយ ឆឌ្ឌិតំ** សេចក្តីថា ដែលគេទុកដាក់នៅព្រៃខ្មោច ។

រាងកាយរបស់អ្នកដែលស្លាប់បានមួយថ្ងៃ ឈ្មោះ ថា **ឯកាហមតៈ** ។

រាងកាយរបស់អ្នកដែលស្លាប់បាន ២ ថ្ងៃ ឈ្មោះថា **ទ្វិហាយក:** ។

រាងកាយរបស់អ្នកដែលស្លាប់ បាន ៣ ថ្ងៃ ឈ្មោះថា **តីហាយក:** ។

សពដែលហើមប៉ោងដូចគេសប់ ឈ្មោះ **ឧទ្ធុមាតក:** (ឡើងប៉ោង) ព្រោះហើម ដោយ សង្កត់ទៅ តាមលំដាប់ក្រោយ ពីអស់ជីវិតហើយ ។

ពណ៌ជាំខ្សែវគេហៅថា **វិនីលៈ** ។ **វិនីលក:** ក៏គឺ **វិនីលៈ** នោះឯង។ ម្យ៉ាងទៀត សពដែលមាន ពណ៌ខ្សែវស្រអាប់គួរខ្ពើមព្រោះជារបស់ បដិកូល ហេតុនោះទើបឈ្មោះថា **វិនីលក:** ។ ពាក្យថា វិនីកលៈនេះ ជាឈ្មោះរបស់សាកសព ដែលមានពណ៌ក្រហម ក្នុងទីដែលមានសាច់ល្មៀនចេញ មានពណ៌ស ក្នុងទីដែលមានខ្ទុះតាំងនៅ ប៉ុន្តែដោយច្រើនមានពណ៌ខ្សែវ ក្នុងទីដែលមានពណ៌ខ្សែវ ហាក់ដូចគេគ្របដណ្តប់សំពត់ពណ៌ខ្សែវ ។

ម្យ៉ាងទៀតខ្ទុះដែលហូរចេញពីកន្លែងបូស ឬទ្វារទាំង ៩ សូម្បីក្នុងទីដែលបែកប្រេះហើយ ឈ្មោះថា **វិបុព្វៈ** ។ **វិបុព្វៈ** ក៏គឺ **វិបុព្វក:** នោះឯង ។ ម្យ៉ាងទៀត ខ្ទុះដែលជាំគួរខ្ពើម

ព្រោះ បដិកូល ហេតុដូច្នោះទើបឈ្មោះថា **ទិបុព្វកៈ** ។ សពដែលក្លាយជាខ្ទុះ គឺដល់ភាវៈយ៉ាងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **ទិបុព្វកជាកៈ** ។

បទថា **សោ តំយេវ កាយំ** សេចក្តីថា ភិក្ខុនោះ បង្អោន កាយរបស់ខ្លួនចូលទៅ (ប្រៀបធៀប) ជាមួយកាយនោះដោយញាណ ។បទថា **ឧបសំហរតិ** ប្រែថា : បង្អោនចូលទៅ ។ បង្អោនចូលទៅយ៉ាងណា? បង្អោនចូលទៅដល់ កាយនេះថា ជាធម្មតាយ៉ាងនេះមានសភាពយ៉ាងនេះ មិនកន្លងផុតសភាពជា យ៉ាងនេះទៅបាន ។លោកពោលអធិប្បាយយ៉ាងណា ?

លោកអធិប្បាយថា ព្រោះមានធម៌ ៣ យ៉ាង គឺ អាយុ ភ្លើងធាតុ(ចំហាយក្តៅងំ) វិញ្ញាណ ទើបកាយនេះ បន្ត (ការប្រែប្រួលឥរិយាបថ) មានឈរ និងដើរជាដើមបាន ប្រសិនបើមិនមានធម៌ទាំង ៣ នេះ ទេ រាងកាយមានយ៉ាងនេះជាធម្មតា គឺមាន សភាពគួរនឿយណាយដូចគ្នា ។

បទថា **ឯវំភាវី** សេចក្តីថា (កាយនេះ) នឹងជាយ៉ាងនេះដូចគ្នា គឺនឹងទៅជាប្រភេទផ្សេងៗ ដូចរាងកាយដែលហើមពោងយ៉ាងដូច្នោះ ។

បទថា **ឯវំ អនតីតោ** សេចក្តីថា មិនកន្លងផុតសភាពជាយ៉ាងនេះ គឺរាងកាយដែលហើមប៉ោងនោះ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរមានប្រក្រតី ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬ ក្នុងកាយរបស់អ្នកដទៃ គឺមានប្រក្រតីពិចារណាឃើញកាយរបស់ខ្លួនតាមកាល ឬក្នុងកាយរបស់អ្នកដទៃតាមកាល ដោយអាការយ៉ាងនេះ ដោយការកំណត់រាងកាយ ដែលហើមប៉ោងនោះ ។

បទថា **ខជ្ជមានំ** សេចក្តីថា រាងកាយដែលត្រូវសត្វទាំងឡាយ មានក្អែកនិងត្មាតចឹកស៊ី ចាប់ទាញអវយវៈមានពោះជាដើម ហើយចឹកយកសាច់ពោះ សាច់បបូរមាត់ និងត្របកភ្នែកចេញមក (ស៊ី) ។

បទថា **សមំសលោហិតំ** សេចក្តីថា រាងកាយដែលប្រកបទៅដោយសាច់ និងឈាមនៅសេសសល់ ។

បទថា **និម្មំសលោហិតមក្ខិតំ** សេចក្តីថា ដល់ពេលសាច់អស់ហើយ ឈាមក៏នៅមិនទាន់អស់ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់កំណត់យកឈាមនោះ ទើបទ្រង់ត្រាស់ថា **លោហិតមក្ខិតំ** ដូច្នេះ ។

បទថា **អញ្ញេន** បានដល់ ដោយទិសាភាគដទៃ ។

បទថា **ហត្ថដ្ឋិកំ** សេចក្តីថា ឆ្អឹងដៃទាំង ៦៤ កំណាត់ ខ្ចាត់ខ្ចាយរាត់រាយទៅតាមទិសផ្សេងៗ សូម្បីឆ្អឹងជើងក៏ន័យដូចគ្នា ។

បទថា **គេរោទសឿកានិ** បានដល់ (ឆ្អឹង) ទុកបានយូរ ។

បទថា **ឃូតិនិ** សេចក្តីថា ឆ្អឹងដែលនៅកណ្តាលវាល ពេលត្រូវខ្យល់និងភ្លៀងរមែងពុកផុយ ឆ្អឹងដងកាំបិតទុកបានយូរ មិនពុកផុយ ប៉ុន្តែឆ្អឹងដែល កប់នៅក្នុងដី រមែងនៅបានយូរជាង ។

បទថា **ចុណ្ណកថាតានិ** បានដល់កម្ទេចឆ្អឹងល្អិតៗ ខ្ចាត់ ខ្ចាយទៅ ។ គ្រប់បទ បណ្ឌិតគប្បីតាក់តែងពាក្យប្រកបដោយ អំណាចនៃកាយដែលត្រូវក្អែកនិងត្មាតចឹកស៊ីជាដើម តាមន័យ ដែល ពោលថា **សោ ឥមេន** ដូចនេះ ។

បទថា **ឥតិ អជ្ឈត្តំ ឯា** សេចក្តីថា ព្រះយោគាវចរ មានប្រក្រតីពិចារណា ឃើញកាយក្នុងកាយរបស់ខ្លួន ឬក្នុងកាយ របស់អ្នកដទៃ មានប្រក្រតីពិចារណាឃើញកាយក្នុងកាយ របស់ ខ្លួនតាមកាល ឬក្នុងកាយរបស់អ្នកដទៃតាមកាល ដោយ អាការយ៉ាងនេះ គឺដោយការកំណត់កាយ មានកាយដែលត្រូវ

ត្នាតក្អែកជាដើម ចឹកស៊ីជាអាទីរហូតទៅជារបស់ល្អិតខ្ទេចខ្ទី ពុក
ផុយអស់ ។

ព្រៃខ្មោច ៩ យ៉ាង

ព្រៃខ្មោច ៩ គប្បីប្រមូលទុកក្នុងទីនេះថា :-

១/- ព្រៃខ្មោចទាំងអស់ដែលទ្រង់ត្រាស់ទុកដោយន័យ
ថា **ឯកាហមតំ វា** (សាកសពដែលស្លាប់បានមួយថ្ងៃ) ខ្លះ ។

២/- ព្រៃខ្មោច ដែលទ្រង់ត្រាស់ទុក ថា **ការកេហិ វា
ខជ្ជមានំ** (សាកសព ដែលត្រូវពួកសត្វក្អែកចឹកស៊ី) ខ្លះ ។

៣/-ព្រៃខ្មោច ដែលទ្រង់ត្រាស់ទុក ថា **អដ្ឋិកសខដ្ឋិកំ
សមំសរោហិត ន្ហារុសម្ពន្ធំ** (សាកសពដែលមានតែរាង
ឆ្អឹងមានសាច់និងឈាមជាប់នៅ មានសរសៃពួររាត់រាយ) ។

៤/- ព្រៃខ្មោច ដែលទ្រង់ត្រាស់ទុក ថា **និម្មំស-
រោហិតមក្ខិតំន្ហារុសម្ពន្ធំ** (សាកសព ដែលមិនមានសាច់
មានតែលោហិត និងសរសៃពួររាត់រាយ) ។

៥/- ព្រៃខ្មោច ដែលទ្រង់ត្រាស់ទុកថា **អបគតមំ-
សរោហិតំ ន្ហារុសម្ពន្ធំ** (សាកសព ដែលមិនមានសាច់
និងឈាមនៅជាប់ ប៉ុន្តែ មានសរសៃពួររាត់រាយ) ។

៦/- ព្រៃខ្មោច ដែលទ្រង់ត្រាស់ទុក ថា **អដ្ឋិកានិ-អបគតសម្ពន្ធនានិ** (ឆ្អឹងដែលមិនមានសរសៃពួររាត់រាយ) ។

៧/- ព្រៃខ្មោច ដែលទ្រង់ត្រាស់ទុក ថា **អដ្ឋិកានិ សេតានិ សង្ខវណ្ណបដិភាគានិ** (ឆ្អឹងស ដូច ពណ៌ស័ង្ខ) ។

៨/- ព្រៃខ្មោច ដែលទ្រង់ត្រាស់ទុក ថា **បុញ្ជកិតានិ តេរោវស្សិកានិ** (ឆ្អឹងដែលរួមនៅ ជាកងយូរឆ្នាំ) ។

៩/- ព្រៃខ្មោច ដែលទ្រង់ត្រាស់ទុក ថា **បូតិនិ ចុណ្ណកជាតានិ** (កម្ទេចឆ្អឹង ពុកផុយ យ៉ាងល្អិត) ។

ព្រះដ៏មានព្រះភាគជាម្ចាស់ នៅពេលទ្រង់សម្តែង ព្រៃខ្មោច ៩ យ៉ាងទុកទីនេះហើយ ជាការបញ្ចប់កាយានុបស្សនាសតិប្បដ្ឋាន ទើបត្រង់ត្រាស់ថា ឯវំ ខោ ភិក្ខវេ ដូច្នេះ ។

ព្រៃខ្មោចគេខ្ពើមរអើមត្រៃពេក មិនគួរចង់ត្រេករួមរស់ជាមួយ
តែពួកតណ្ហាចូលចិត្តលើកស្ទួយ **សង**ស្អុយរលួយ រីករាយទៅវិញ ។
ខ្មោចរស់ខ្មោចស្លាប់ស្អុយដូចតែគ្នា ខ្មោចមច្ចុមារលក់ភ្លានគេទិញ
អ្នកប្រាជ្ញដឹងច្បាស់ឱ្យរត់គេចចេញ បណ្តេញខ្មោចនោះទើបរួចផុតទុក្ខ

ដោយ នា សុខា

អរិយសច្ចៈក្នុងនវសីវថិកា

សតិ ជាគ្រឿងកំណត់ព្រៃខ្មោច ៩ ក្នុង នវសីវថិកាបព្វៈ នេះ ជាទុក្ខសច្ចៈ តណ្ហាដែលជាតួនាំឱ្យកើតសតិនោះជា សមុទយសច្ចៈ ការមិនប្រព្រឹត្តទៅនៃទុក្ខសច្ចៈនិងសមុទយសច្ចៈ ទាំង ២ នេះ ជានិរោធសច្ចៈ អរិយមគ្គដែលជាការកំណត់ដឹងទុក្ខ លះសមុទ័យ មាននិរោធ(និព្វាន)ជាអារម្មណ៍ ជាមគ្គសច្ចៈ ។

ព្រះយោគាវចរ រមែងសម្រេចដល់និព្វាន ដោយអំណាចសច្ចៈទាំង ៤ ដូចពណ៌នាមកនេះ បញ្ជាក់បូកសរុបថា នេះជាផ្លូវនៃធម៌ គ្រឿងនាំចេញរហូតដល់ព្រះអរហាត្តរបស់ភិក្ខុ អ្នកកំណត់ ព្រៃខ្មោច ៩ យ៉ាងនេះឯង ។

សេចក្តីអធិប្បាយ

នៅក្នុងបទានុក្រមធម្មបទ ពាក្យថា

នវសីវថិកាវស ប៉ុំ (នវ+សីវថិកា+វស) អំណាចនៃភូមិ ជាទីតាំងនៃសាកសព ៩ ។

ការឃើញនូវសាកសពហើយសម្លឹងពិនិត្យនូវចំណែកផ្សេងៗ ទាំង ៩ យ៉ាងនេះ ក៏មានចិត្តកំណាត់សម្គាល់មិនចេះអស់មិនចេះហើយ ដោយមើលពិនិត្យសាចុះសាឡើង នូវចំណែកដទៃៗ របស់សាកសពនោះ ដូចជាសាកសពហើមប៉ោង ដែលបានស្លាប់ត្រឹម មួយថ្ងៃខ្លះ ពីរថ្ងៃខ្លះ បីថ្ងៃខ្លះ រហូតមានខ្ទុះហូរចេញគ្រប់ទ្វារទាំង ៩ ហើយត្រូវពួកសត្វក្អែកត្មាត និងគម្រង់ចឹកស៊ីទាញយកនូវចំណែកផ្សេងៗនៃរូបរាងកាយមានពោះវៀនធំ ពោះវៀនតូច និងអវយវៈតូចធំជាដើម មកចឹកស៊ីតាមសេចក្តីត្រូវការ ក៏រូបរាងកាយគ្មានកម្រើកអ្វីបន្តិចបន្តួច ធ្វើហាក់ដូចជាមិនដឹងបណ្តោយឱ្យពួកសត្វទាំងនោះធ្វើតាមអំពើចិត្ត គ្មានតតាំង ឬស្រែកគំរាម ដោយវាចាណាមួយក៏មិនមានដែរ ព្រោះរូបកាយជាធាតុមិនដឹងអ្វីទាំងអស់ ដោយវិញ្ញាណប្រាសចេញអស់ទៅហើយ ជារូបដេកនៅស្ងុកស្ដឹង ទុកដូចជាអង្កត់ឱសរកប្រយោជន៍គ្មានឡើយ ។

ម្យ៉ាងទៀតរូបនោះ លុះទុកយូរថ្ងៃ យូរខែ ច្រើនឆ្នាំក៏ត្រូវរលេះរលួយជ្រុះសាច់ខ្លះ មានឈាមជាប់និងសាច់ខ្លះនៅសល់តែសរសៃពួរយឺងរយោងរហូតដល់អស់សាច់អស់ឈាម អស់សរសៃពួរនៅសល់តែរាងឆ្អឹងទទេ ហើយឆ្អឹងនេះក៏ប្រែក្លាយទៅជាកំណាត់

តូច។ ដូចជាឆ្អឹងដៃ ៦៤ កំណាត់ និងឆ្អឹងជើងក៏ដូចគ្នា ។ លុះយូរទៅទៀត ឆ្អឹងកំណាត់នេះនឹងត្រូវពុកផុយ ទៅជាកម្ទេចល្អិតៗ ព្រោះត្រូវភ្លៀង និងកម្តៅថ្ងៃ នៅសល់ តែស្នាមសាកសពប៉ុណ្ណោះ ។

ការឃើញនូវសាកសពទាំង ៩ យ៉ាង ដែលព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់សម្តែងមកនេះ បានធ្វើឱ្យយើងរាល់គ្នា ចេះពិចារណាដោយបញ្ញាញាណ គឺ យកសាកសពទាំងនោះមកប្រៀបធៀបនឹងរូបកាយរបស់យើងម្នាក់ៗដែលកំពុងរស់នៅសព្វថ្ងៃ ថាគង់តែនឹងមានសភាពដូចគ្នា ព្រោះការកើតឡើងរបស់សត្វទាំងឡាយតែងនាំយកនូវជរានិងមរណៈ មកជាមួយ នេះជាសង្ខេបវត្ថុ ៨ យ៉ាងដែលយើងខ្ញុំបាន សរសេរជាកំណាព្យជម្រាបជូននៅក្នុងជីវិតប្រក្រតីភាគទី១ ។

ការពិចារណាឃើញ សេចក្តីស្លាប់ដែលមានសាកសពទាំង ៩ យ៉ាង ធ្វើឱ្យមានសេចក្តីតក់ស្លុតក្នុងជីវិត ដែលមួយថ្ងៃទៅមួយថ្ងៃ ទ្រាំទ្ររស់នៅ គ្រាន់តែរង់ចាំដល់ពេលចុតិចូលមកដល់ ពុំមានសង្ឃឹមថាជីវិតនឹងត្រូវទទួលបាននូវអ្វីដែលប្រសើរជាងការរស់នៅត្រឹមតែដេកសម្រាក ហូបចុកនូវអាហារមានឱជារសឆ្ងាញ់ មានទ្រព្យសម្បត្តិច្រើន ឬ មានគេរាប់អាន សរសើរលើកតម្កើងដោយមានះ រួចត្រូវវិនាស ព្រាត់ប្រាស់ចោលរបស់

ទាំងនោះគ្រប់ៗគ្នា មិនថាអ្នកណាៗ សូម្បីពួកទេវតាមារព្រហ្ម ក្នុងភពបី ក៏ដូចគ្នាទាំងអស់ ។

ការឃើញសាកសពទាំង ៩ យ៉ាង ដែលជាអារម្មណ៍កម្មដ្ឋាននេះ ព្រះមានព្រះភាគទ្រង់លើកយកមកសម្តែង ដើម្បីជួយដាស់តឿន ស្មារតីដល់សព្វសត្វកុំឱ្យងប់ងល់ ជ្រុលជ្រប់តែនឹងវត្ថុសម្ភារៈខ្លាំងពេក គួរមានសេចក្តីសង្វេគតក់ស្លុតនៅក្នុងជីវិតថា រូបរាងកាយរបស់យើង ក៏ដូចជាសាកសពទាំងនោះ មិនខានឡើយ ។ ឃើញដូច្នោះ ទើបពិចារណារកទីពឹងមួយផ្សេងក្រៅពីនេះ បានដល់ការលះបង់ចោលនូវអ្វីៗដែលមាន ហើយចូលខ្លួនមកស្វែងរកធម៌ជាទីពឹង មានគុណព្រះរតនត្រ័យជាទីរលឹកសម្រាប់អ្នកដែលមានឧបនិស្ស័យ ប្រសិនបើមិនដូច្នោះការប្រព្រឹត្តិរបស់ពួកគេនោះមិនលែងចោល នឹងត្រូវបន្ថែមល្បឿនឱ្យកាន់តែខ្លាំងឡើងជាងមុនទៅទៀត ដើម្បីយកជ័យជម្នះលើអ្នកក្រខ្សត់ បានន័យថា ធ្វើយ៉ាងណាឱ្យកាន់តែមានទ្រព្យសម្បត្តិច្រើនៗ សម្បូរហូរហៀរទុកសម្រាប់បង្ហូត សេចក្តីស្លាប់ ដែលមានសាកសពទាំង ៩ យ៉ាងនោះ ជាឧទាហរណ៍ ព្រោះគេយល់ថា ការរស់នៅត្រូវការសប្បាយ ឬថាកាលណាគេស្លាប់ទៅ មិនបានសប្បាយ

ដូចនេះទៀតឡើយ នេះជាការយល់ច្រឡំរបស់អ្នកបរិភោគកាម ហៅថា កាមភោគីបុគ្គល ។

ការមានស្មារតីមិនមែនដូច្នេះឡើយ កាលណាគេមានសេចក្តីសង្វេគយ៉ាងនេះ ក៏មិនត្រូវរស់នៅក្នុងសេចក្តីល្ងង់ខ្លៅតទៅទៀត ត្រូវតែរើបម្រះចេញ រិះរកផ្លូវផ្សេង គឺសិក្សាស្រាវជ្រាវរកផ្លូវណាដែលមិនធ្វើឱ្យមានសេចក្តីស្លាប់និងភ័យតក់ស្លុត ។ កន្លែងនេះ មានសំនួរសួរថា: អ្វីទៅសម្រាប់ដោះស្រាយជីវិតឱ្យមានសុខសេរីភាពមិនមានសេចក្តីស្លាប់ និងភ័យតក់ស្លុត ឆ្លើយថា: ការលះហេតុនៃតណ្ហាមាន ឆន្ទរាគៈជាដើម តែមួយគត់ ទើបរកសុខឃើញ ដូចបានជម្រាបជូនពីមង្គលសូត្រនៅក្នុងសៀវភៅនេះស្រាប់ គ្រាន់តែលើកឡើងប៉ុណ្ណោះ ដើម្បីបញ្ជាក់ជូនពីសិរីសួស្តី របស់សត្វលោកក្នុងជីវិតដ៏តិចតួចស្តួចស្តើងយ៉ាងនេះ ។

ការមើលឃើញនូវសាកសពទាំង ៩ យ៉ាង ឬអសុភជាមធ្យោបាយដ៏កម្រក្រៃលែងរបស់ព្រះដ៏មានព្រះភាគ ក្នុងបំណងញុំាងចិត្តព្រះយោគាវចរ អ្នកមានការព្យាយាមបដិបត្តិធម៌ ឱ្យវិលមករកការបង្អោនចិត្ត ចូលមកពិចារណានូវរូបរាងកាយ នៃយើងគ្រប់ៗគ្នាវិញ ដូចជាបទថា **ឥតិ អជ្ឈត្តំ វា កាយេ**

កាយានុបស្សី ឥហរតិ ប្រែថា: ពិចារណាឃើញនូវកាយក្នុងកាយ ខាងក្នុងជាប្រក្រតីគ្រប់តរិយាបថទាំង ៤ ផង ។ **ពហិទ្ធា វា កាយេ កាយានុបស្សី ឥហរតិ** ប្រែថា: ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់តរិ-យាបថទាំង ៤ ផង ។ **អជ្ឈត្តពហិទ្ធា វា កាយេ កាយានុ-បស្សី ឥហរតិ អាតាបី សម្បជានោ សតិមា ឥនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ប្រែថា: ពិចារណាឃើញនូវកាយក្នុងកាយខាងក្នុងនិងខាងក្រៅជាប្រក្រតីគ្រប់តរិយាបថទាំង ៤ ផង មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។

រូបរាងកាយនៃយើង ដែលមើលឃើញពីខាងក្រៅថា ស ល្អ ស្អាត គួរពេញចិត្ត ឬមិនពេញចិត្ត អាក្រក់យ៉ាងណា ដែលកំពុងរស់នៅនេះ ក៏មានសភាពដូចសាកសពទាំង ៩ ឬ អសុភ ដែលទ្រង់ត្រាស់សម្តែង ដើម្បីធ្វើការប្រៀបធៀបគ្នា មិនមែនមានន័យផ្សេងពីសាកសពនោះឡើយ គឺសាកសពដូចតែគ្នា គ្រាន់តែមានធម៌ ៣ គឺ អាយុ ១ ឧស្ម័ (ភ្លើងធាតុ) ១

និងវិញ្ញាណ ១ មិនទាន់ប្រាសចេញទៅប៉ុណ្ណោះ ។ ចំពោះរូបកាយ ជារបស់មិនស្អាត ជារបស់គួរស្អប់ខ្ពើម ជាទុក្ខមិនគួរចូលចិត្ត តែការយល់ខុសរបស់សត្វខ្លះ បែរទៅជាពេញចិត្ត ចូលចិត្តនៃបនិត្យ ស្និទ្ធស្នាល ថើប បឺត ជញ្ជក់មាត់ ថែមទាំងចូលចិត្តប៉ះពាល់ ឱបរឹតនូវរបស់ ស្មោកគ្រោកទៅវិញ តើមូលហេតុអ្វី ព្រោះឆន្ទរាគៈនាំឱ្យមាន ការកើតជាទុក្ខ ជរាមណៈជាទុក្ខ សេចក្តីត្រេកត្រអាលនូវអ្វីៗ គ្រប់បែបយ៉ាង ក៏ជាទុក្ខដែលជាឫសគល់របស់វដ្តៈ មានអវិជ្ជាធាតុ ប្រធាននៃអំពើកម្មកសាងអភិសង្ខារសម្រាប់បង្កើតកូនចាត់ចែងពិភពលោក ឱ្យដើរទៅតាមមិច្ឆាបដិបទា ក្នុងបំណងទាញសត្វឱ្យធ្លាក់ចុះក្នុងភពទទួលរងទុក្ខទោសគ្រោះថ្នាក់មិនចេះស្រាកស្រាន្ត ទុកបន្តពូជមច្ចុមារ សោយរាជ្យក្នុងនគរកាយយ៉ាងយូរអង្វែងតទៅមិនចេះចប់ ។

ការមើលសាកសព និងការពិនិត្យសាកសព ធ្វើឱ្យមានការពិចារណាដោយ បញ្ញាញាណ គឺមិនមែនមើលត្រឹមតែមើលសំខាន់ត្រូវមានសតិស្មារតីនឹករលឹកឃើញជាក់ស្តែង នូវសាកសពទាំង ៩ យ៉ាង ហើយយកមកប្រៀបធ្ងឹមនឹងរូបកាយរបស់យើង

☞ តាមការចង្អុលប្រាប់ពីព្រះដ៏មានព្រះភាគ ដែលជាមធ្យោបាយបណ្តេញពួកកិលេសទាំងឡាយ ដោយបច្ចក្ខវិបស្សនា-វិជ្ជា ដែលមាននាមរូបជាទីតាំងនៃអារម្មណ៍របស់សតិប្បដ្ឋាន មានអនុស័យកិលេស គឺ ទិដ្ឋានុស័យជាដើម ធ្លាប់ដេកត្រាំនៅក្នុងខន្ធសន្តានជាយូរមកហើយ ឱ្យរលត់រលាយកុំមានតទៅទៀត ។ ការធ្វើតាមរបៀបនេះ រឿយៗ ញយៗ មានការព្យាយាមរបស់វីរិយសម្ពោជ្ឈង្គធម៌ អង្គនៃការត្រាស់ដឹងនៅក្នុងពោធិបក្ខិយធម៌ ៣៧ ប្រការ អាចសម្រេចមគ្គផល ក្នុងពេលណាមួយជាមិនខាន ។ ការឃើញរឿយៗជានិច្ចកាលនូវរបស់ណាមួយ សញ្ញាដែលជាគ្រឿងចងចាំនៅក្នុងខន្ធ ៥ គឺ រូបធម៌ នាមធម៌ ប្រាកដជានឹងចាប់យកនូវចំណុចនោះ សន្សំទុកក្នុងជវនវិថីធ្វើវិបាកកិច្ច គឺ កិច្ចកើតផលផ្លែផ្កាទៅថ្ងៃអនាគត ខាងមុខ ។ តាមធម្មតា ការប្រព្រឹត្តិនូវកម្មណា ផលត្រូវតែសម្រេចទៅតាមកម្មនោះ ។

ការឃើញនូវសាកសពទាំង ៩ នេះ នាំឱ្យមានសេចក្តីត្រេកអរនៅក្នុងកម្មដ្ឋាន ចេះពិចារណារកឬសរកគល់នូវការពិតរបស់ខន្ធ ទាំង ៥ ដែល សន្ទត ហៅថា សត្វលោក ព្រោះ

ចាប់តាំងពីមានជាតិដឹងក្តី រហូតដល់ស្លាប់ទៅវិញ តើមានអ្វីនាំយក
ទៅជាមួយ ឆ្លើយថា ពុំមានអ្វីទាល់តែសោះ ទ្រព្យសម្បត្តិទាំង
ឡាយ បន្សល់ទុកឱ្យអ្នកក្រោយ គឺ កូនចៅទទួលកេរមរតក
ជំនួស យកបានទៅជាមួយ នូវអំពើបុណ្យនិងបាប ដែលខ្លួនបាន
ប្រព្រឹត្តក្នុងពេលកំពុងនៅរស់ ។ កន្លែងនេះគួរសង្កេតមែន
ទែន ធ្វើឱ្យមានការកាត់បន្ថយនូវបំណងប្រាថ្នាលើរបស់ទាំងពួង
បានដល់ឧបាទានក្ខន្ធទាំង៥ ដោយមិនគួរប្រកាន់ ព្រោះមាន
អនុបស្សនាទាំង ៧ កើតឡើង ដូចជា អនិច្ចានុបស្សនា រមែង
ពិចារណាឃើញនូវអ្វីៗ គឺកាយនេះមិនទៀងទាត់ប្រាកដឋិតថេរ
ជានិច្ចកាល រមែងលះនូវនិច្ចសញ្ញា ។ ទុក្ខានុបស្សនា រមែង
ពិចារណាឃើញនូវកាយនេះ ឬរបស់អ្វីដទៃទៀត ជាទុក្ខ
រមែងលះនូវសុខសញ្ញាបាន ។ អនត្តានុបស្សនា ពិចារណា
ឃើញនូវកាយនេះមិនមែនខ្លួន រមែងលះអត្តសញ្ញា គឺសម្គាល់
ថា ខ្លួនចេញបាន ។ និព្វិទានុបស្សនា ពិចារណាឃើញនូវរូប
កាយនេះ គួរនឿយណាយ រមែងលះនន្ទិ គឺ សេចក្តីត្រេកត្រអាល
ភ្លើតភ្លើន ។ វិរាគានុបស្សនា រមែងពិចារណាឃើញកាយនេះ ថា
មិនគួរត្រេកអរ រមែងលះនូវសេចក្តីប្រាថ្នាបាន ។ និរោធានុ-
បស្សនា ពិចារណាឃើញកាយនេះរលត់ រមែងលះនូវតណ្ហា

គឺហេតុនាំឱ្យកើតទុក្ខបាន ។ បដិនិស្សគានុបស្សនា ពិចារណាឃើញនូវកាយនេះ មិនគួរប្រកាន់ រមែងលះនូវការប្រកាន់បាន។

ការឃើញ សាកសពទាំង ៩ យ៉ាង **ឬ អសុភ** ជារបស់មិនស្អាត តែងតែនឹកទៅដល់សេចក្តីស្លាប់រឿយៗ គឺមរណានុស្សតិ ដោយសម្លឹងឃើញថា សង្ខារទាំងពួងមិនទៀងនឹងបែកធ្លាយចាកចោលលោកនេះ ក្នុងពេលដ៏ខ្លីខាងមុខជាមិនខាន ហើយក៏មិនសន្សំកពូននូវកិលេសទាំងឡាយមាន លោភៈ ជាប់ជំពាក់ទោសៈ ប្រទូសរ៉ាយ មោហៈ វង្វេងស្រវឹង ទៅលើអ្វីមួយដូចជាមានភរិយាជាទីគាប់ចិត្ត មានកូនជាទីពឹងពំនាក់ និងទ្រព្យសម្បត្តិជាដើម ត្រូវដកចិត្តចេញជាបណ្តើរៗ ចាប់ពីពេលនេះតទៅ ព្រោះថាអ្វីៗទាំងពួងកាលបើអ្នកលះបង់ចោលហើយ អ្នកទាំងឡាយនឹងទទួលបាននូវសេចក្តីសុខ ។

នៅក្នុងព្រះពុទ្ធសាសនា មានពាក្យប្រៀនប្រដៅថា សូមអ្នកលះបង់នូវអ្វីក្នុងលោក ព្រោះលោកនេះ គឺឧបាទានក្ខន្ធ ៥ ជាជំរំទុក្ខ កាលបើអ្នកលះបង់បានហើយ សេចក្តីទុក្ខ នឹងមិនប្រែតប្រែនមិនជាប់តាមអ្នកឡើយ ព្រោះហេតុនោះបានជាព្រះពុទ្ធអង្គ ទ្រង់ត្រាស់ដឹងឡើងក្នុងលោក សម្រាប់ជួយស្រោច

ស្រង់លោក មិនឱ្យសត្វលោកទទួលនូវទារុណកម្មនៃទុក្ខវដ្តៈត
ទៅទៀត ទើបទ្រង់ត្រាស់សម្តែងប្រាប់ផ្លូវធ្វើដំណើរទៅរកទី
បំផុតទុក្ខគឺ អរិយមគ្គអង្គ ៨ ប្រការ។ ឥឡូវនេះ នឹងលើកយក
អរិយមគ្គមានអង្គ ៨ ប្រការ មកជម្រាបជូន បន្ថែមទៀត ។

មហាវគ្គ មគ្គកថា

អដ្ឋកថា ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៦៩/៤២៩

ពាក្យថា **មគ្គោ** សេចក្តីថា ឈ្មោះថា **មគ្គ** ព្រោះអត្ថ
ថាអ្វី។

ក្នុងខណៈសោតាបត្តិមគ្គ សម្មាទិដ្ឋិ ព្រោះអត្ថថា ឃើញ
ជាមគ្គ និង ជាហេតុដើម្បីលះមិច្ឆាទិដ្ឋិ ដើម្បីឧបត្ថម្ភ សហជាតធម៌
ដើម្បីគ្របសង្កត់កិលេសទាំងឡាយ ដើម្បីសេចក្តីហ្មត់ចត់ក្នុង
ខាងដើមនៃបដិវេធៈ ដើម្បីសេចក្តីតាំងមាំនៃចិត្ត ដើម្បីសេចក្តី
បរិសុទ្ធនៃចិត្ត ដើម្បីសម្រេចធម៌ពិសេស ដើម្បីចាក់ធ្លុះធម៌
ដ៏ក្រៃលែង ដើម្បីត្រាស់ដឹងសច្ចៈ ដើម្បីឱ្យចិត្តតាំងនៅក្នុងនិរោធ។
សម្មាសង្កប្បៈ ព្រោះអត្ថថា ត្រិះរិះ ជាមគ្គ និងជាហេតុ ដើម្បី
លះមិច្ឆាសង្កប្បៈ ...។ សម្មាវាចា ព្រោះអត្ថថា កំណត់យក ជាមគ្គ
និងជាហេតុ ដើម្បីលះមិច្ឆាវាចា ...។ សម្មាកម្មន្តៈ ព្រោះអត្ថថា

ជាសមុដ្ឋាន ជាមគ្គ និងជាហេតុ ដើម្បីលះមិច្ឆាកម្មន្តៈ ... ។ សម្មាអាជីវៈ ព្រោះអត្ថថាបរិសុទ្ធ ជាមគ្គ និងជាហេតុ ដើម្បីលះមច្ឆាជីវៈ ... ។ សម្មាវាយាមៈ ព្រោះអត្ថថាផ្គងទុក ជាមគ្គ និងជាហេតុ ដើម្បីលះមិច្ឆាវាយាមៈ ... ។ សម្មាសតិ ព្រោះអត្ថថាតាំងមាំ ជាមគ្គ និងជាហេតុ ដើម្បីលះមិច្ឆាសតិ... ។ សម្មាសមាធិ ព្រោះអត្ថថា មិនរវើរវាយ ជាមគ្គ និងជាហេតុ ដើម្បីលះមិច្ឆា-សម្មាធិ ដើម្បីឧបត្ថម្ភសហជាតធម៌ ដើម្បីគ្របសង្កត់កិលេសទាំងឡាយ ដើម្បីសេចក្តីហ្មត់ចត់ក្នុងខាងដើមនៃបដិវេធៈ ដើម្បីសេចក្តីតាំងមាំនៃចិត្ត ដើម្បីសេចក្តីបរិសុទ្ធនៃចិត្ត ដើម្បីសម្រេចធម៌ពិសេស ដើម្បីចាក់ធ្លុះធម៌ដ៏ក្រៃលែង ដើម្បីត្រាស់ដឹងនូវសច្ចៈ ដើម្បីចិត្តតាំងមាំនៅក្នុងនិរោធ ។

ក្នុងខណៈសកទាគាមិមគ្គ សម្មាទិដ្ឋិ ព្រោះអត្ថថាឃើញ ។ ល ។ សម្មាសមាធិ ព្រោះអត្ថថាមិនរវើរវាយ ជាមគ្គ និង ជាហេតុ ដើម្បីលះកាមរាគសំយោជនៈ បដិឃសំយោជនៈ កាមរាគានុស័យ បដិឃានុស័យ ចំណែកខាងគ្រោតគ្រាត។... ។

ក្នុងខណៈអនាគាមិមគ្គ សម្មាទិដ្ឋិព្រោះអត្ថថា ឃើញ។ ល ។ សម្មាសមាធិ ព្រោះអត្ថថាមិនរវើរវាយ ជាមគ្គ និង ជាហេតុ

ដើម្បីលះកាមរាគសំយោជនៈ បដិឃសំយោជនៈ កាមរាគា-
នុស័យ បដិឃានុស័យ ចំណែកខាងល្អិតៗ... ។

ក្នុងខណៈអរហត្តមគ្គ សម្មាទិដ្ឋិព្រោះអត្ថថាឃើញ។ ល។
សម្មាសមាធិ ព្រោះអត្ថថា មិនរវើរវាយ ជាមគ្គ និង ជាហេតុ
ដើម្បីលះ រូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ
រាគានុស័យ អវិជ្ជានុស័យ ដើម្បីឧបត្ថម្ភសហជាតធម៌ ដើម្បីគ្រប
សង្កត់កិលេសទាំងឡាយ ដើម្បីសេចក្តីហ្មត់ចត់ក្នុងខាងដើមនៃ
បដិវេធៈ ដើម្បីការតាំងមាំនៃចិត្ត ដើម្បីសេចក្តីបរិសុទ្ធនៃចិត្ត
ដើម្បីសម្រេចធម៌ពិសេស ដើម្បីចាក់ធ្លុះធម៌ដ៏ក្រៃលែង ដើម្បី
ត្រាស់ដឹងនូវសច្ចៈ ដើម្បីឱ្យចិត្តតាំងមាំក្នុងនិរោធ។

សម្មាទិដ្ឋិ ជាមគ្គនៃការឃើញ សម្មាសង្កប្បៈ ជាមគ្គនៃ
ការត្រិះរិះ សម្មាវាចា ជាមគ្គនៃការកំណត់ សម្មាកម្មន្តៈ ជាមគ្គ
នៃសមុដ្ឋាន សម្មាអាជីវៈ ជាមគ្គនៃសេចក្តីបរិសុទ្ធ សម្មាវាយាមៈ
ជាមគ្គនៃការផ្គងទុក សម្មាសតិ ជាមគ្គនៃការតាំងមាំ សម្មាសមាធិ
ជាមគ្គមិនរវើរវាយ ។ សតិសម្ពោជ្ឈង្គ ជាមគ្គនៃការសម្រិត
សម្រាំង វីរិយសម្ពោជ្ឈង្គ ជាមគ្គនៃការផ្គងទុក បីតិសម្ពោធជ្ឈង្គ
ជាមគ្គនៃការផ្សាយទៅ បស្សទ្ធិសម្ពោជ្ឈង្គ ជាមគ្គនៃសេចក្តីស្ងប់
សមាធិសម្ពោជ្ឈង្គ ជាមគ្គនៃការមិនរវើរវាយ ឧបេក្ខាសម្ពោជ្ឈង្គ

ជាមគ្គនៃការពិចារណាកន្លង ។ សទ្ធាពលៈ ជាមគ្គ នៃការមិន
ញាប់ញ័រ ក្នុងការមិនមានសទ្ធា វីរិយពលៈ ជាមគ្គនៃការមិន
ញាប់ញ័រ ក្នុងសេចក្តីខ្ជិលច្រអូស សតិពលៈ ជាមគ្គនៃការមិន
ញាប់ញ័រ ក្នុងសេចក្តីមិនប្រមាទ សមាធិពលៈ ជាមគ្គនៃការមិន
ញាប់ញ័រ ក្នុងឧទ្ធច្ចៈ បញ្ញាពលៈ ជាមគ្គនៃការមិនញាប់ញ័រ ក្នុង
អវិជ្ជា។ សទ្ធិន្ទ្រិយ ជាមគ្គនៃការបង្អោនចិត្តជឿ វីរិយិន្ទ្រិយ
ជាមគ្គនៃការផ្គងទុក សតិន្ទ្រិយ ជាមគ្គនៃការតាំងមាំ សមា-
ធិន្ទ្រិយ ជាមគ្គនៃការមិនរវើរវាយ បញ្ញិន្ទ្រិយ ជាមគ្គនៃការ
ឃើញ។ ឥន្ទ្រិយជាមគ្គ ព្រោះអត្ថថាជាធំ ពលៈ ជាមគ្គព្រោះ
អត្ថថាមិនញាប់ញ័រ ពោជ្ឈង្គ ជាមគ្គព្រោះអត្ថថានាំចេញ ។ ឈ្មោះ
ថាមគ្គ ព្រោះអត្ថថាជាហេតុ សតិប្បដ្ឋាន ជាមគ្គព្រោះអត្ថថា
តាំងមាំ សម្មប្បធាន ជាមគ្គ ព្រោះអត្ថថាតាំងទុក ឥទ្ធិបាទ
ជាមគ្គ ព្រោះអត្ថថា ឱ្យសម្រេច សច្ចៈ ជាមគ្គ ព្រោះអត្ថថាពិត
សមថៈ ជាមគ្គ ព្រោះអត្ថថាមិនរវើរវាយ វិបស្សនា ជាមគ្គ
ព្រោះអត្ថថា ពិចារណាឃើញ សមថៈនិងវិបស្សនា ជាមគ្គ ព្រោះ
អត្ថថាមានកិច្ចតែមួយ។ ធម៌ ដែលជាគូគ្នា ជាមគ្គព្រោះអត្ថថា
មិនកន្លងគ្នា និង គ្នា ។ សីលវិសុទ្ធិ ជាមគ្គព្រោះអត្ថថា សង្រួម
ចិត្តវិសុទ្ធិ ជាមគ្គ ព្រោះអត្ថថាមិនរវើរវាយ ទិដ្ឋិវិសុទ្ធិជាមគ្គ
ព្រោះអត្ថថា ឃើញ ។ វិមោក្ខ ជាមគ្គព្រោះអត្ថថា រួចផុត វិជ្ជា
ជាមគ្គព្រោះអត្ថថា ចាក់ធ្លុះ វិមុត្តិ ជាមគ្គ ព្រោះអត្ថថាដោះចេញ

ញ្ញាណក្នុងការអស់ទៅ ជាមគ្គ ព្រោះអត្ថថា ដាច់ខាត ឆន្ទៈ ជាមគ្គព្រោះអត្ថថា ជាមូល មនសិការ ជាមគ្គព្រោះអត្ថថាជា សមុដ្ឋាន ផស្សៈ ជាមគ្គព្រោះ អត្ថថាជាទីប្រជុំ វេទនា ជាមគ្គ ព្រោះអត្ថថា ជាទីរួម សមាធិ ជាមគ្គព្រោះអត្ថថា ជាប្រធាន សតិជាមគ្គព្រោះអត្ថថា ជាធំ បញ្ញា ជាមគ្គព្រោះអត្ថថា ជាធម្មិ ក្រៃលែងជាងធម្មិនោះ វិមុត្តិ ជាមគ្គ ព្រោះអត្ថថាជាសារៈ និព្វានដែលញ៉ាំងចុះចំពោះអមតៈ ជាមគ្គ ព្រោះអត្ថថា ជាទីបំផុត ។

ដូចបានលើកយកនូវមគ្គកថាមកជម្រាបជូន ក៏ដើម្បី ត្រួសត្រាយផ្លូវក្នុងព្រះពុទ្ធសាសនា ថាដំណើរជីវិតប្រក្រតី ប្រព្រឹត្តទៅតាមផ្លូវមូលតែមួយ ពុំមានផ្លូវដទៃណាក្រៅពីនេះ ដែលព្រះដ៏មានព្រះភាគ ព្រមទាំងអរិយសាវ័កទាំងឡាយ ធ្វើ ដំណើរទៅមុនតាមផ្លូវនេះរួចហើយ ។ អរិយមគ្គអង្គ ៨ ប្រការ តែងកើតឡើងគ្រប់ពេលក្នុងជីវិតប្រក្រតី ដោយសតិប្បដ្ឋាន ជា បុព្វភាគ នៅពេលណាពិចារណាឃើញសង្ខារទាំងឡាយ ទាំងពួង មិនទៀង ជាទុក្ខ និង ជាអនត្តា ។

ក្នុងបទថា **អត្ថង្គមាយ ញ្ញាយស្ស មគ្គិគមាយ** ប្រែថា : ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ជាផ្លូវ គឺសតិប្បដ្ឋាន ៤ នេះឯង ។

សេចក្តីនេះមានយ៉ាងណា ព្រោះ សតិប្បដ្ឋាន ជាការលះបង់នូវសក្កាយទិដ្ឋិដែលជាសេចក្តីប្រកាន់របស់សត្វទាំងឡាយ ពោលគឺឧបាទានក្ខន្ធ ៥ ក្នុងការរស់នៅនោះ តែងជាប់ជំពាក់រើខ្លួនមិនរួចពីសង្ខារទុក្ខ ហើយក៏មិនដឹងមានផ្លូវឯណា មកជួយដោះស្រាយជីវិតឱ្យមានសុខសេរីភាព ប្រសើរខ្ពង់ខ្ពស់ រួចផុតពីទុក្ខកង្វល់ក្រៅពីផ្លូវនេះ ។

ការប្រសូតរបស់ព្រះមហាបុរស

អដ្ឋកថា ឧបរិបណ្ណាសក លេខ ២៣/៦៧

ព្រះបរមពោធិសត្វ ទ្រង់ប្រសូតនៅថ្ងៃសុក្រ ពេញបូណ៌មី ខែ ពិសាខ ឆ្នាំ ច វេលាថ្ងៃជិតត្រង់ក្រោមដើមសាលព្រឹក្សក្នុងព្រៃលុម្ពិនី ត្រង់ចន្លោះនគរកបិលពស្តុ និងទេវទហៈ ធ្វើឱ្យម៉ឺនលោកធាតុកក្រើកញាប់ញ័រ ព្រោះដោយអំណាចអភិនិហារបារមីដ៏មានកម្លាំងខ្លាំងលើសលុបជាងអ្វីៗ ក្នុងជម្ពូទ្វីបចក្រវាលនេះ ដោយបានពុះជ្រែកមហាសមុទ្ទសង្សារ គឺប្រឹថពីនេះ ដែលមានអវិជ្ជា តណ្ហាស្រោបរួបរឹត មិនអាចរារាំងទប់ស្កាត់នូវការកើតឡើង របស់ធម្មនិយាម ប៉ុន្តែមិនធ្វើឱ្យអន្តរាយដល់ជីវិតទេ ដើម្បីប្រែក្លាយ

សភាពតានតឹងរបស់សត្វទាំងឡាយ ឱ្យមកជាសុខសួស្តីសិរីមង្គល មានច្រើនប្រការ មិនឃ្លៀងឃ្លាតពីមង្គលសូត្រឡើយ ។

១- ក្នុងថ្ងៃដែលព្រះមហាបុរសទ្រង់ប្រសូត ម៉ឺនលោកធាតុញាប់ញ័រ ជាបុព្វនិមិត្តនៃការបានចំពោះនូវសព្វញ្ញុតញ្ញាណ ។

២- ដែលទេវតាទាំងឡាយ មកប្រជុំគ្នាក្នុងចក្រវាលតែមួយ ជាបុព្វនិមិត្ត នៃការរួមប្រជុំទទួលនូវព្រះសទ្ធម្ម ក្នុងពេលតែមួយ និងពេលដែលប្រកាសធម្មចក្រ ។

៣- ដែលពួកទេវតាទទួលព្រះពោធិសត្វមុនគេ ជាបុព្វនិមិត្តនៃការបានចំពោះនូវរូបាវចរជ្ឈាន ៤ ។

៤- ដែលមនុស្សទាំងឡាយទទួលក្រោយ ជាបុព្វនិមិត្តនៃការបាននូវអរូបជ្ឈាន ៤ ។

៥- ដែលគ្រឿងតន្ត្រីលាន់ឮឡើងដោយខ្លួនឯង ជាបុព្វនិមិត្តនៃការបានចំពោះនូវអនុបុព្វវិហារធម៌ ៩ ។

៦- ដែលស្គរពាសដោយស្បែកស្នូរឮឡើងដោយខ្លួនឯង ជាបុព្វនិមិត្តនៃការទូន្មានដោយធម្មភេរីប្រសើរក្រៃលែង ។

៧- ដែលគ្រឿងពន្ធនាការដាច់ចេញពីគ្នា ជាបុព្វនិមិត្តនៃការកាត់នូវអស្មិមានៈបានជាដាច់ខាត ។

៨- ដែលមនុស្សទាំងឡាយជាសះស្បើយរោគផ្សេងៗ ជាបុព្វនិមិត្ត
នៃការប្រាសចេញទៅនូវកិលេសទាំងពួង ។

៩- ដែលមនុស្សខ្វាក់ពីកំណើតអាចមើលឃើញរូបបាន ជាបុព្វនិមិត្ត
នៃការបានចំពោះនូវទិព្វចក្ខុ ។

១០- ដែលមនុស្សថ្លង់ពីកំណើត បានឮសំឡេងឡើងវិញ ជាបុព្វនិមិត្ត
នៃការបានចំពោះនូវទិព្វសោត ។

១១- ដែលមនុស្សពិការមានកម្លាំងឡើងវិញ ជាបុព្វនិមិត្តនៃការ
បានសម្រេចនូវឥទ្ធិបាទទាំង ៤ ។

១២- ដែលមនុស្សឆ្កួតទឹកមាត់ ត្រឡប់ជាមានសតិឡើងវិញ
ជាបុព្វនិមិត្តនៃការបានចំពោះនូវសតិប្បដ្ឋានទាំង ៤ ។

១៣- ដែលទូកឬសំពៅទាំងឡាយ បើកចេញទៅក្រៅប្រទេស
ដល់ចំណតដោយស្រួល ជាបុព្វនិមិត្តនៃការបានចំពោះនូវ
បដិសម្ភិទាទាំង ៤ ។

១៤- ដែលរតនៈទាំងឡាយមានពន្លឺភ្លឺដោយខ្លួនឯង ជាបុព្វនិមិត្ត
នៃពន្លឺភ្លឺស្វាងរបស់ព្រះធម៌ ដែលព្រះអង្គទ្រង់សម្តែងដល់
សត្វលោក ។

១៥- ដែលសត្រូវទាំងឡាយត្រឡប់ជាមានមេត្តាចិត្ត ជាបុព្វនិមិត្ត
នៃការបានចំពោះនូវព្រហ្មវិហារធម៌ ៤ ។

១៦- ដែលភ្លើងអវិចិន្តរករលត់ ជាបុព្វនិមិត្តនៃការបានចំពោះនូវការរលត់ភ្លើងទាំង ១១ កង ។

១៧- ដែលលោកន្តរនរកមានពន្លឺភ្លឺស្វាង ជាបុព្វនិមិត្តនៃការដែលព្រះអង្គទ្រង់កម្ចាត់នូវសេចក្តីងងឹត គឺ អវិជ្ជា ហើយឃើញពន្លឺភ្លឺស្វាងបានដោយព្រះញ្ញាណ ។

១៨- ដែលទឹកទន្លេមិនហូរ ជាបុព្វនិមិត្តនៃការបានវេសារជ្ជញ្ញាណ ៤ ។ (ស្រង់ចាកបារមីភាគទី ២)

◈ ១៩-ដែលទឹកមហាសមុទ្រ ធ្លាប់តែមានរសជាតិប្រៃ ត្រឡប់ជាមានរសជាតិផ្អែម ជាបុព្វនិមិត្តនៃព្រះធម៌ មានរសតែមួយ។

២០- ដែលមិនកើតមានរោគភ័យ ជាបុព្វនិមិត្តនៃសេចក្តីដែលពុទ្ធបរិស័ទមិនបែកបាក់គ្នាដោយអំណាចទិដ្ឋិ ៦២ ។

២១- ដែលសត្វស្លាបហើរធ្លាក់ចុះមកលើផែនដី ជាបុព្វនិមិត្តនៃការដែលមហាជនស្តាប់ពាក្យទូន្មានដល់នូវសរណៈ ស្មើដោយជីវិត ។

២២- ដែលព្រះចន្ទរុងរឿងភ្លឺស្អាតក្រៃលែង ជាបុព្វនិមិត្តនៃការដែលមហាជនចាប់អារម្មណ៍លើព្រះធម៌ ។

២៣- ដែលព្រះអាទិត្យ មិនក្តៅពេកមិនត្រជាក់ពេក ផ្តល់ឱ្យនូវសេចក្តីសុខស្រួលតាមរដូវកាល ជាបុព្វនិមិត្តនៃការដែលមហាជន មានសេចក្តីសុខកាយ សុខចិត្ត ។

២៤- ដែលពួកទេវតានាំគ្នាលេងកីឡា ទះដៃ នៅតាមមាត់ទ្វារ វិមាន ជាបុព្វនិមិត្តនៃការដែលព្រះមហាក្សត្រ សម្រេចដល់ភាពជាព្រះពុទ្ធហើយទ្រង់ផ្តែងនូវឧទាន។

២៥- ដែលមហាមេឃទាំង ៤ ទិស ញាំងទឹកភ្លៀងឱ្យធ្លាក់ចុះ ជាបុព្វនិមិត្តនៃការដែលខ្សែទឹក គឺ ព្រះធម៌ធ្លាក់ចុះ យ៉ាងច្រើន ។

២៦- ដែលមនុស្សទាំងឡាយ មិនត្រូវសេចក្តីឃ្លានស្រេក ប្បែតប្បែន ជាបុព្វនិមិត្តនៃការបានចំពោះនូវអមតធម៌គឺ កាយគតាសតិ។

២៧- ដែលមនុស្សទាំងឡាយ មិនត្រូវសេចក្តីក្រហល់ក្រហាយ ស្រេកទឹកប្បែតប្បែន ជាបុព្វនិមិត្តនៃការ ដែលពុទ្ធបរិស័ទមានសេចក្តីសុខ ដោយវិមុត្តិសុខ ។

២៨- ដែលទ្វារមុខទាំងឡាយរបើកឯង ជាបុព្វនិមិត្តនៃការបើកទ្វារអដ្ឋង្គិកមគ្គ ។

២៩- ដែលដើមឈើទាំងឡាយចេញផលផ្លែផ្កា ជាបុព្វនិមិត្តនៃព្រះធម៌ដែលរីកដូចផ្កា គឺវិមុត្តិ និងពេញណែនដោយសាមញ្ញផល ។

៣០- ដែលម៉ឺនលោកធាតុមានទង់ ជារបៀបតែមួយដូចគ្នា គប្បីជ្រាបថា ជាបុព្វនិមិត្តនៃពុទ្ធបរិស័ទមានទង់របស់ព្រះអរិយៈជាកម្រងផ្កា នេះឈ្មោះថា សម្ពហុលវារៈ ។

ក្នុងអធិការនេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ។ ដែលព្រះអង្គទ្រង់ប្រថាប់ឈរនៅលើផែនដី ដោយព្រះបាទរាបស្មើ ជាបុព្វនិមិត្តនៃការបានចំពោះនូវឥទ្ធិបារមី៤ ។ ដែលព្រះអង្គទ្រង់បែរព្រះភក្ត្រឆ្ពោះទៅទិសឧត្តរ ជាបុព្វនិមិត្តនៃការដែលស្តេចយាងទៅយ៉ាងប្រសើរក្រៃលែង លើមហាជន ។ ដែលព្រះអង្គទ្រង់ដំណើរយាងទៅបាន ៧ ជំហាន ជាបុព្វនិមិត្តនៃការបានចំពោះនូវរតនៈគឺ ពោជ្ឈង្គ ៧ ប្រការ។ ដែលទ្រង់ស្វែតច្ឆត្រជាទិព្វ ជាបុព្វនិមិត្តនៃការបានចំពោះ នូវឆត្រគឺវិមុត្តិ។ រាជកកុធភណ្ឌទាំង៥ ជាបុព្វនិមិត្តនៃការរួចផុតដោយវិមុត្តិទាំង ៥ ប្រការ ។ ដែលទ្រង់សម្លឹងមើលទៅទិសទាំងពួង ជាបុព្វនិមិត្ត នៃការបានចំពោះនូវ អនាវរណាញ្ញាណ ។ ដែលទ្រង់ថ្លែងនូវអាសភិវាចា ជាបុព្វនិមិត្តនៃការបានចំពោះ នូវការប្រកាសធម្មចក្រ ទោះបីនរណាៗក៏មិនអាចធ្វើឱ្យវិលត្រឡប់បាន ។ សីហនាទ ដែលទ្រង់ថ្លែងថា " **អយមន្តិមា ជាតិ** (ជាតិនេះជាជាតិចុងក្រោយ) គប្បីជ្រាបថា ជាបុព្វនិមិត្ត នៃការបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ។

នេះគ្រាន់តែជាការដកស្រង់ នូវខ្លឹមសារសំខាន់ប្លែកៗ ដែល ព្រះពោធិសត្វយាងចេញចាកព្រះគភ៌នៃព្រះវរមាតា ហើយឈានទៅមុខ ធ្វើឱ្យផែនដីកក្រើកញាប់ញ័រ ក៏ជាចំណែកមួយ សម្រាប់បង្ហាញប្រាប់ពីអាថិកំបាំងរបស់លោកនៅក្នុងធម្មជាតិទាំងឡាយដែលអ្នកមិនធ្លាប់ដឹង ឱ្យបានដឹងឡើងនូវភាពចម្លែកអស្ចារ្យនេះ ដើម្បីទុកជាកំណប់ទ្រព្យ ក្នុងការជួយអប់រំផ្លូវចិត្តកុំឱ្យខ្ពល់ខ្វាយនូវអ្វីៗ ដែលមិនគួរជឿ ឱ្យលះបង់ចោល ព្រោះការមិនប្រកាន់អ្វីៗទាំងពួង នេះឯងជាផ្លូវដើរទៅរកសេចក្តីសុខស្ងប់ ដែលមានតែក្នុងព្រះពុទ្ធសាសនា គឺ សតិប្បដ្ឋានប្បដិបត្តិ ។

រឿងពាណិជ ៧០០ នាក់

មង្គលទីបនីប្រែ ភាគទី ១/១០៥

ក្នុងអតីតកាល មានពួកពាណិជ ៧០០នាក់ បានឆ្លងសមុទ្រដោយសំពៅ។ ក្នុងថ្ងៃទី ៧ សំពៅក៏បានលិចកណ្តាលមហាសមុទ្រ។ ទឹកបានជោរឡើងហើយ ពួកពាណិជជួបប្រទះភ័យហើយ ក៏បានកំណត់យកឈ្មោះនៃពួកទេវតារបស់ខ្លួនម្នាក់ៗ ហើយធ្វើកម្មផ្សេងៗ មានការសុំបួងសួងជាដើម ។

ក្នុងបណ្តាពួកពាណិជទាំងនោះ មានបុរសម្នាក់នឹករលឹកទានដែលខ្លួនបានប្រគេនហើយដល់ព្រះភិក្ខុសង្ឃ ជាសរណៈ និងសីលដែលខ្លួនបានទទួលហើយក្នុងថ្ងៃចុះសំពៅបានអង្គុយ មិនតក់ស្លុតសោះឡើយ ។ ពួកពាណិជក្រៅពីនេះឃើញបុរសនោះមិនភិតភ័យ ក៏សួរនូវហេតុការមិនភិតភ័យបុរសបានប្រាប់ នូវហេតុដល់ពួកពាណិជទាំងនោះ ។

ពួកពាណិជ នែនាយ! ក៏សីលរមែងសមគួរដល់ជនទាំងឡាយដែរ ឬទេ ?

បុរស មែនហើយ សីលរមែងសមគួរដល់ជនទាំងនោះ ។

ពួកពាណិជ បើដូច្នោះ ចូរអ្នកឱ្យនូវសីលដល់ពួកយើងខ្ញុំទាំងឡាយផងចុះ ។

បុរសនោះ បានរៀបចំមនុស្សជា ៧ ក្រុម ក្នុងមួយក្រុមៗ មាន ១00 នាក់ រួចហើយទើបឱ្យនូវសីល ៥ ។

ក្រុមទី១- បានឈរនៅក្នុងទឹកប្រមាណត្រឹម ក ជើង ហើយទទួលនូវសីល

ក្រុមទី២- បានឈរនៅក្នុងទឹកប្រមាណត្រឹម ជង្គង់ ហើយទទួលនូវសីល

ក្រុមទី៣- បានឈរនៅក្នុងទឹកប្រមាណត្រឹម ចង្កេះ ហើយ ទទួលនូវសីល

ក្រុមទី៤- បានឈរនៅក្នុងទឹកប្រមាណត្រឹម ផ្ចិត ហើយ ទទួលនូវសីល

ក្រុមទី៥- បានឈរនៅក្នុងទឹកប្រមាណត្រឹម ដោះ ហើយ ទទួលនូវសីល

ក្រុមទី៦- បានឈរនៅក្នុងទឹកប្រមាណត្រឹម ក ហើយ ទទួលនូវសីល

ក្រុមទី៧-បានឈរនៅក្នុងទឹកប្រែកំពុងហូរចូលក្នុងមាត់ ហើយទទួលនូវសីលដូចគេឯងដែរ ។

បុរស បានឱ្យសីលដល់ជនទាំងឡាយរួចហើយ ទើបប្រកាស ថា <<ទីពឹងដទៃរបស់អ្នក ក្រៅពីនេះ មិនមានឡើយ អ្នកទាំងឡាយចូររលឹកចំពោះសីលតែម្យ៉ាងចុះ>> ដូច្នោះ ហើយក៏បានស្លាប់ទៅកើតក្នុងភពតាវត្តិង្ស ។ ពួកជនទាំង ៧០០ នាក់ បានកើតហើយ ក្នុងភពតាវត្តិង្សដូចគ្នាដែរ ព្រោះអាស្រ័យសីលដែលខ្លួនបានទទួល ក្នុងពេលទៀបនឹងស្លាប់ ។

ទេវបុត្រទាំងអស់នោះ លោកហៅថា <<**សគុឡ្ហបភាយិកា** (អ្នកស្ថិតនៅក្នុងខណៈដែលលើកតម្កើងនូវសេចក្តីល្អ)>> ព្រោះ

ជាអ្នកលើកតម្កើងនូវធម៌របស់ពួកសប្បុរស ដោយអំណាចការសមាទានសីលរួចហើយ ទើបបានទៅកើតក្នុងពពួកទេវតា ថ្នាក់តាវត្តឹង្ស-សួគ៌ ។

វិមានរបស់ពួកទេវបុត្រទាំងនោះ កើតឡើងដោយអំណាចការប្រជ្រៀតគ្នាតែម្តង យ៉ាងដូច្នេះ ។ បណ្តាពួកទេវបុត្រទាំងនោះ វិមានមាសរបស់ទេវបុត្រជាអាចារ្យ មានប្រវែងប្រមាណ ១00 យោជន៍ កើតឡើងនៅកណ្តាលវិមានទាំងពួងឯវិមានទាំងឡាយ របស់ពួកទេវបុត្រដែលជាអន្តេវាសិក កើតឡើងព័ទ្ធជុំវិញវិមានទេវបុត្រជាអាចារ្យ ចំណែកវិមានទេវតាថ្នាក់ទាបជាងគេ មានប្រវែងប្រមាណ ១២ យោជន៍ ។

ទេវបុត្រទាំងឡាយ នីករលើកឃើញនូវកម្មក្នុងខណៈដែលខ្លួនកើតហើយនុ៎ះឯង ដឹងនូវការបានសម្បត្តិ ព្រោះអាស្រ័យពីអាចារ្យ ក៏មានបំណងចង់ពោលសរសើរគុណរបស់អាចារ្យ ក្នុងសម្នាក់ព្រះសាស្តា ទើបនាំគ្នាមកកាន់វត្តជេតពនក្នុងចន្លោះមជ្ឈិមយាម ក្រាបថ្វាយបង្គំព្រះសាស្តាហើយ ទើបឈរនៅទីដ៏សមគួរ។ បណ្តាទេវបុត្រទាំងនោះ ទេវតា ៦ អង្គ ប្រាថ្នាចង់ ពោលគាថា ក្នុងមួយអង្គៗ មួយគាថាតាមលំដាប់គ្នា ក៏បានពោលគាថា ទាំងឡាយ ៦ ធ្វើបាទទី ៤ ឱ្យខុសផ្សេងពីគ្នា និង ៣ បាទក្រៅពីនេះ ឱ្យដូចគ្នាតែមួយថា :-

១- បុគ្គល គប្បីគប់រកនឹងពួកសប្បុរសតែម្យ៉ាង គប្បីធ្វើការស្និទ្ធស្នាលនឹងពួកសប្បុរស ព្រោះបានដឹងនូវព្រះសទ្ធម្ម របស់ពួកសប្បុរស គុណធម៌ដ៏ប្រសើរមែងកើតមាន មិនមែនជាទោសដ៏លាមកទេ ។

២- បុគ្គល គប្បីគប់រកនឹងពួកសប្បុរសតែម្យ៉ាង គប្បីធ្វើការស្និទ្ធស្នាលនឹងពួកសប្បុរស ព្រោះបានដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស បុគ្គលតែងបាននូវបញ្ញានឹងបាន អំពីបុគ្គលដទៃ មិនមានឡើយ ។

៣- បុគ្គល គប្បីគប់រកនឹងពួកសប្បុរសតែម្យ៉ាង គប្បីធ្វើការស្និទ្ធស្នាលនឹងពួកសប្បុរស ព្រោះបានដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស បុគ្គលរមែងមិនសោយសោក ក្នុងកណ្តាលនៃបុគ្គលអ្នកសោយសោក ។

៤- បុគ្គល គប្បីគប់រកនឹងពួកសប្បុរសតែម្យ៉ាង គប្បីធ្វើការស្និទ្ធស្នាលនឹងពួកសប្បុរស ព្រោះបានដឹងនូវព្រះសទ្ធម្ម របស់ពួកសប្បុរស បុគ្គលរមែងរុងរឿងក្នុងកណ្តាលនៃញាតិ ។

៥- បុគ្គល គប្បីគប់រកនឹងពួកសប្បុរសតែម្យ៉ាង គប្បីធ្វើការស្និទ្ធស្នាលនឹងពួសប្បុរស ព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស សត្វទាំងឡាយ រមែងទៅកាន់សុគតិ ។

៦- បុគ្គល គប្បីគប់រកនឹងពួកសប្បុរសតែម្យ៉ាង គប្បីធ្វើការស្និទ្ធស្នាលនឹងពួសប្បុរស ព្រោះបានដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស សត្វទាំងឡាយ រមែងស្ថិតនៅ អស់កាលជាយូរអង្វែង។

គ្រានោះ ទេវតាដទៃទៀតក្រាបទូលសួរថា <<បពិត្រព្រះដ៏មានព្រះភាគ ពាក្យរបស់អ្នកណាទៅ ជាសុភាសិត ?>> ។

ព្រះសាស្តាទ្រង់ត្រាស់ថា "ពាក្យអ្នកទាំងអស់គ្នាជាសុភាសិតដោយបរិយាយ ចូរអ្នកទាំងឡាយ ស្តាប់នូវពាក្យរបស់តថាគតខ្លះផង" ដូច្នោះ ហើយទ្រង់ត្រាស់នូវគាថានេះថា:-

<<បុគ្គល គប្បីសេពគប់នឹងពួកសប្បុរសតែម្យ៉ាង គប្បីធ្វើការស្និទ្ធស្នាលនឹងពួកសប្បុរស ព្រោះបានដឹងនូវព្រះសទ្ធម្ម របស់ពួកសប្បុរស បុគ្គលរមែងរួចផុតចាកសេចក្តីទុក្ខទាំងពួង>> ។

យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ

ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ។

ប្រែថា : បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកអ្នកដែលមានសីល មានការពិនិត្យពិចារណា ជាប្រក្រតីប្រសើរជាង ។

ធម្មបទគាថា បិដកលេខ ៥២/៤៥

ប្រវត្តិសង្ខេបរបស់ព្រះពុទ្ធឃោសាចារ្យ

គម្ពីរព្រះវិសុទ្ធិមគ្គនេះ បណ្ឌិតទាំងពួងគប្បីជ្រាបថា ព្រះគន្ថរចនាចារ្យ អ្នកមាននាមប្រាកដថា ព្រះពុទ្ធឃោសាចារ្យ ដែលបានចតុបដិសម្ភិទាញ្ញាណ ដឹងបែកធ្លាយជំនាញចាក់ធ្លុះធ្លាយ ក្នុងព្រះត្រៃបិដកមានបញ្ញាវិសារទៈគឺ ក្លៀវក្លា បានរចនាតាក់តែងទុក ដើម្បីជាប្រយោជន៍ដល់ព្រះពុទ្ធសាសនា ។

ឥឡូវនេះនឹងពោលរៀបរាប់ពីការឧប្បត្តិឡើងនៃព្រះពុទ្ធឃោសាចារ្យ ដោយបានដកស្រង់សេចក្តីតាមនិទានប្រវត្តិ ដែលមានមកក្នុងគម្ពីរពុទ្ធឃោសុប្បត្តិ មើលគម្ពីរញាណោទ័យបកររណ៍ ដោយសង្ខេប ។

សេចក្តីថា ព្រះអ្នកជាម្ចាស់ព្រះពុទ្ធឃោសាចារ្យអង្គនេះ កាលពីបុព្វជាតិមុន បានកើតជាទេវបុត្រ មាននាមថា ឃោស-ទេវបុត្រ សោយទិព្វសម្បត្តិនៅក្នុងតាវត្តិង្សទេវលោក ។

នៅពេលព្រះពុទ្ធសាសនាកន្លងទៅបាន ២៣៦ វស្សា រាប់គិតចាប់តាំងពីព្រះដ៏មានព្រះភាគទ្រង់ រំលត់ខន្ធបរិនិព្វាន ព្រះមហាមហិន្ទត្ថេរៈ អ្នកជាអង្គព្រះអរហន្តពិសេស បានចេញទៅប្រតិស្ថាន ព្រះបរិយត្តិធម្មសាសនាទុកក្នុងលង្កាទ្វីប ។

ក្នុងកាលជាខាងក្រោយកន្លងយូរមក កុលបុត្រក្នុងជម្ពូ-
ទ្វីបនេះ សិក្សារៀនសូត្រព្រះបរិយត្តិធម៌ បានដោយលំបាកក្នុង
សម័យនោះ ទើបមានព្រះមហាថេរៈមួយអង្គ ជាព្រះមហាខីណា
ស្រព មាននាមថា ព្រះធម្មឃោសាចារ្យ ព្រះនាមមួយទៀតហៅ
ថា ព្រះរេវតមហាថេរៈ ជាអ្នកមានឫទ្ធិគិតនឹងទំនុកបម្រុងព្រះ-
បរិយត្តិសាសនារបស់សម្តេចព្រះបរមសាស្តាឱ្យរុងរឿង ទើបចូល
ឈាន សមាបត្តិសម្តែងឫទ្ធី ឡើងទៅប្រាកដចំពោះព្រះភក្ត្រសម្តេច
សក្កទេវរាជក្នុងពិភពតាវត្តិង្ស សូមឱ្យអារាធនាឃោសទេវបុត្រ
អ្នកមានសម្ភារបារមី បានសាងសន្សំអប់រំមកក្នុងសម្ពាក់ព្រះពុទ្ធ
មុនៗ ច្រើនព្រះអង្គ ជាអ្នកមានត្រៃហេតុកបដិសន្ធិបញ្ជាចាស់ក្លា
ឱ្យចុតិ ចុះមកកើត ក្នុងមនុស្សលោកជួយទំនុកបម្រុងព្រះបរិយត្តិ
សាសនា របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ឱ្យរុងរឿងឡើង ។

នៅពេលឃោសទេវបុត្រ បានទទួលអារាធនាពីសម្តេច
ទេវានមិន្ទ្រទេវរាជហើយ ក៏ចុតិចាកទេវលោកមកកើតក្នុងគភ
របស់នាងកេសិនីព្រាហ្មណី ជាភរិយារបស់កេសីព្រាហ្មណ៍បុរោ-
ហិតាចារ្យ ជំនាញក្នុងត្រៃវេទ រស់នៅក្នុងផ្ទះឃោសតាម ជិត
ដើមព្រះមហាពោធិក្នុងមហានគរ ដែលជាតំបន់នៃមជ្ឈិម-
ប្បទេសក្នុងជម្ពូទ្វីប ។

ខណៈពេលទារកនោះកើតឡើង សំឡេងមនុស្សនៅក្នុងផ្ទះរហូតដល់ទាសកម្មករជាដើម ពោលតែពាក្យជាមង្គលដល់គ្នានិងគ្នា ដូចជា សម្រែកពោលពាក្យសរសើរ ឮអ៊ឹងកង ទើបមាតាបិតា និងពួកញាតិដាក់នាមដល់ទារកនោះថា ឃោសកុមារ ព្រោះហេតុសំឡេងពោល មង្គលកថាឮអ៊ឹងកងនោះ ។

ពេលឃោសកុមារមានវ័យវឌ្ឍនាការអាយុបាន ៧ ខួប ក៏មានសតិបញ្ញាឆ្លៀវឆ្លាតយ៉ាងក្រៃលែង បានចូលទៅសិក្សានូវគម្ពីរត្រៃវេទបែកធ្លុះធ្លាយក្នុងអាយុ ៧ ខួប ។ ចំណែកព្រាហ្មណ៍បុរោហិត បិតា ធ្វើជាព្រះរាជគ្រូបង្ហាត់បង្រៀនត្រៃវេទាង្គសាស្ត្រដល់ព្រះមហាក្សត្រក្នុងនគរ បាននាំបុត្រចូលទៅក្នុងព្រះរាជវាំងជានិច្ចកាល ។

ក្នុងវេលាថ្ងៃមួយ ព្រាហ្មណ៍បុរោហិត បង្រៀនត្រៃវេទដល់ព្រះមហាក្សត្រនូវបទគណ្ឋិក្នុងត្រៃវេទមួយបទ ក៏មានសេចក្តីសង្ស័យគិតអត្ថាធិប្បាយមិនចេញ ទើបទូលលានាំបុត្តត្រឡប់មកផ្ទះជាប្រញាប់ ហើយក៏ចេះតែនឹកគិតរឿយៗយ៉ាងណានៅតែត្រិះរិះ មិនឃើញពីការអត្ថាធិប្បាយនោះ ។

ចំណែកឃោសកុមារ ដឹងថាបិតាគិតមិនឃើញនូវការអត្ថាធិប្បាយបទត្រៃវេទនោះហើយ ទើបសរសេរចំណុចអត្ថា-

ធិប្បាយបទគណ្ឋិក្នុងត្រៃវេទចុះក្នុងស្លឹកត្នោត (ឬស្លឹកចាក) ។ លុះបិតាចេញមកបានឃើញអក្សរហើយ ក៏យល់នូវពាក្យអត្ថាធិប្បាយនោះ ព្រោះបានដឹងថា បុត្តរបស់ខ្លួនមានការចេះដឹងយ៉ាងស្ទាត់ជំនាញក្រៃលែង ទើបមកសរសេរអត្ថាធិប្បាយនូវចំណុចវេទមន្តនោះទុកឱ្យ ដោយមានការសរសើរ និងត្រេកអរជាទីបំផុត ព្រមទាំងនាំបុត្រចូលគាល់ព្រះមហាក្សត្រ ក្រាបទូលអំពីការប្រព្រឹត្តិនូវហេតុនោះ ។ សម្តេចបរមខត្តិយរាជ ទ្រង់សោមនស្សរីករាយក្នុងព្រះរាជហឫទ័យក្រៃលែង ទើបចាប់ឱបលើកឃោសកុមារឱ្យឡើងអង្គុយលើព្រះពាលា ជញ្ជក់ថើបក្បាល រួចមានព្រះរាជ-តម្រាស់ថា ចាប់ពីពេលនេះទៅ ចៅចូរជាបុត្រធម៌របស់យើង រួចត្រាស់សរសើរបញ្ញាឃោសកុមារយ៉ាងច្រើនប្រការ ។

ពេលឃោសកុមារមានវ័យវឌ្ឍនាការចម្រើនឡើង បានមកបព្វជាក្នុងសម្នាក់ព្រះធម្មឃោសាចារ្យ ជាព្រះឧបជ្ឈាយាចារ្យ ដោយបានសិក្សាព្រះធម្មវិន័យព្រះត្រៃបិដក ក្នុងប្រមាណមួយខែប៉ុណ្ណោះ ក៏បានសម្រេចការចេះដឹងក្នុងប្រសូត្រ ព្រះវិន័យ និង ព្រះអភិធម្មនូវបិដកទាំងបី ។ ក្រោយពីបានឧបសម្ប័ទបួសជា ភិក្ខុភាវៈក្នុងព្រះពុទ្ធសាសនារួចហើយ ក៏មានបញ្ញា-វិសារទៈ ក្លៀវក្លា បានសម្រេចចតុបដិសម្ភិទាញ្ញាណ ដឹងចាក់

ធ្លុះជំនាញក្នុងបាលី និងអដ្ឋកថា ព្រមទាំងនិរុត្តិបទវិគ្គហៈ និង បដិភាណ ការពោលបានឆ្លើយឆ្លងយ៉ាងស្ទាត់ជំនាញព្រមជាមួយ អង្គនៃបដិសម្ភិទាញ្ញាណទាំង ៤ ដែលមានកិត្តិគុណសរសើរ បញ្ញាល្បី សាយសុះផ្សាយទៅក្នុងសកលជម្ពូទ្វីប ទើបមាន ព្រះនាមថា ព្រះពុទ្ធឃោសភិក្ខុ ។ ព្រះពុទ្ធឃោសាចារ្យ ប្រៀបដូចសម្តេច ព្រះពុទ្ធអង្គ នៅពេលទ្រង់មានព្រះជន្មនៅ ឡើយ ដែលមានព្រះកិត្តិសព្ទ និងព្រះកិត្តិគុណផ្សាយទៅក្នុង ផ្ទៃមហិតលរកទីបំផុតគ្មាន ។

ក្នុងវេលាដ៏សមគួរចូលមកដល់ហើយ ព្រះមហាថេរៈ ជាព្រះឧបជ្ឈាយ៍មានព្រះថេរសាសនំ បញ្ជូន ឬ (និមន្ត) ព្រះពុទ្ធ ឃោសាចារ្យឱ្យទៅប្រែព្រះពុទ្ធវចនបរិយត្តិធម៌ត្រៃបិដក ក្នុង លង្កាទ្វីប ចេញពីសិង្ហលភាសា ត្រឡប់មកជាភាសាមគធៈ ដើម្បីជាប្រយោជន៍ក្នុងព្រះពុទ្ធសាសនាឱ្យថាវរៈតទៅ ។

ចំណែកព្រះពុទ្ធឃោសាចារ្យ ទទួលឧបជ្ឈាយាសាសន៍ ហើយ ទើបសូមឱកាសទៅទូន្មានព្រះបិតា ដែលនៅជាមិច្ឆាទិដ្ឋិ ឱ្យត្រឡប់ជាសម្មាទិដ្ឋិជ្រះថ្លា ក្នុងព្រះរតនត្រ័យ រហូតបាន សម្រេចព្រះសោតាបត្តិផល ហើយក៏ត្រឡប់មកនមស្ការលា

ព្រះឧបជ្ឈាយ៍ចុះសំពៅជាមួយពួកពាណិជ ចេញទៅក្នុងមហាសមុទ្រ ។

ក្នុងខណៈនោះ ដោយតេជៈវិសុទ្ធិសីលាទិគុណ និងអំណាចបុណ្យចេតនារបស់ព្រះពុទ្ធឃោសាចារ្យ ដែលតាំងចិត្តថានឹងប្រែព្រះបរិយត្តិធម៌ ជួយទំនុកបម្រុងព្រះពុទ្ធសាសនាឱ្យរុងរឿងតទៅនោះ ជាបុញ្ញកិរិយាវត្ថុមហាកុសល កើតជាទិដ្ឋធម្មវេទនីយផល ទើបមានទេវរាជានុភាពរបស់សក្កទេវរាជ និងព្រហ្មានុភាព របស់ព្រះព្រហ្មដែលមានមហិទ្ធិឫទ្ធី ជួយថែរក្សាសំពៅព្រះពុទ្ធឃោសាចារ្យ ឱ្យអណ្តែតទៅក្នុងមហាសមុទ្រ ដោយសុវត្ថិភាព មិនមានភ័យអន្តរាយ ។

ពេលសំពៅព្រះពុទ្ធឃោចារ្យអណ្តែតទៅបានបីថ្ងៃ ក៏បានជួបនឹងសំពៅព្រះពុទ្ធទត្តថេរៈមួយអង្គ ដែលបើកចេញពីលង្កាទ្វីបបានបីថ្ងៃដែរ ហើយសំពៅទាំងពីរនេះបានអែបជិតគ្នា។ ព្រះថេរៈទាំង ២ អង្គ និមន្តចេញមកធ្វើបដិសណ្ឋារៈ រួចសាកសួរពីកិច្ចរវាងគ្នានឹងគ្នា ។ ព្រះពុទ្ធទត្តៈទ្រង់ជ្រាបថា ព្រះពុទ្ធឃោសាចារ្យទ្រង់និមន្តចេញទៅប្រែព្រះបរិយត្តិធម៌ក្នុងលង្កាទ្វីប ក៏បានត្រេកអរជ្រះថ្លាក្រៃលែង ទើបជម្រាបថា លោកបានប្រែ ព្រះបរិយត្តិ-ធម៌ទុក ៣ គម្ពីរដែរ គឺបាលីជិនាលង្កា ១ បាលីទន្តធាតុ ១

បាលីពុទ្ធវង្ស ១ ប៉ុន្តែនៅមិនទាន់បានរចនាគម្ពីរ អដ្ឋកថា និង
គម្ពីរដីកា ហើយក៏បានសូមអារាធនា ព្រះពុទ្ធឃោសាចារ្យ ឱ្យ
ជួយតាក់តែងគម្ពីរអដ្ឋកថា និងគម្ពីរដីកាសម្រាប់ បាលីទាំង ៣
គម្ពីរនោះផង ដើម្បីជាប្រយោជន៍ដល់ព្រះពុទ្ធ សាសនាតទៅ ។
ព្រះពុទ្ធទ័ត្តវេរៈ ក៏ថ្វាយផ្លែសម៉ ជាថ្នាំ ព្យាបាលរោគ ១
ដែកចារមានដង ១ ថ្មសម្លៀងដែកចារ ១ ដល់ព្រះពុទ្ធ-
ឃោសាចារ្យនូវរបស់ ៣ មុខនោះ ។ សម្តេច សុជប្បតិទេវរាជ
ទ្រង់បានថ្វាយនូវរបស់ទាំង ៣ មុខនេះ ដល់ព្រះអ្នកជាម្ចាស់រួច
មុនហើយ ។ ប៉ុន្តែនៅក្នុងគម្ពីរ ញ្ញាណោទ័យបករណ៍ ពោលថា
សម្តេចសក្កទេវរាជ បានថ្វាយផ្លែសម៉ ដែកចារ ដល់ព្រះពុទ្ធ-
ឃោសាចារ្យក្នុងថ្ងៃដែលព្រះអ្នកជាម្ចាស់ចុះ សំពៅចេញចាក
ជម្ពូទ្វីបមុនរួចហើយ ។ នៅពេលសំពៅព្រះពុទ្ធ ទត្តថេរៈមក
ដល់ជម្ពូទ្វីប សំពៅព្រះពុទ្ធឃោសាចារ្យ ក៏ចូលមកដល់ចំណត
កំពង់លង្កាទ្វីបដែរ ។

ក្នុងពេលដ៏សមគួរ ព្រះពុទ្ធឃោសាចារ្យបាននិមន្តទៅ
សម្ភាក់សម្តេចព្រះសង្ឃរាជាធិបតីមានានាមថា ព្រះសង្ឃបាលជា
កំពូលសង្ឃក្នុងលង្កាទ្វីប ដែលប្រថាប់នៅក្នុងមហាវិហារ គង់
ពីក្រោយសិស្សសង្ឃដែលមករៀនព្រះបរិយត្តិធម៌ ។ ក្នុងថ្ងៃនោះ

សម្តេចព្រះសង្ឃរាជ ប្រាប់ព្រះអភិធម្ម និងព្រះវិន័យដល់សិស្ស សង្ឃនូវបទគណ្ឋិ ក្នុងព្រះអភិធម្មក៏មិនយល់ពីសេចក្តីអធិប្បាយ ទើបប្រាប់សង្ឃសិស្សទាំងឡាយ ឱ្យត្រឡប់ចូលទៅក្នុងបន្ទប់ ដើម្បីឱ្យគិតត្រិះរិះអត្ថាធិប្បាយ នូវបទគណ្ឋិព្រះអភិធម្មនោះ ។

ចំណែកព្រះពុទ្ធឃោសាចារ្យដឹងថា សម្តេចព្រះសង្ឃរាជ ទ្រង់មិនជ្រាបនូវអត្ថាធិប្បាយក្នុងបទគណ្ឋិព្រះអភិធម្ម ទើប សរសេរ សេចក្តីអត្ថាធិប្បាយនិងអដ្ឋកថា ចុះទុកក្នុងផ្ទាំងក្រដាស ជិតអាស្រមសម្តេចព្រះសង្ឃរាជ រួចហើយក៏ត្រឡប់មកទីកន្លែងរបស់ខ្លួន ។ នៅពេលសម្តេចព្រះសង្ឃរាជ ចេញពីបន្ទប់ បានឃើញអក្សរ ក៏យល់សេចក្តីអធិប្បាយ ក្នុងបទគណ្ឋិព្រះអភិធម្មនោះយ៉ាងជាក់ច្បាស់ ទើបប្រើអ្នកបដិបត្តិឱ្យទៅតាមអារាធនា ព្រះពុទ្ធឃោសាចារ្យមកចោទសួរ ។ លុះបានជ្រាបថា ព្រះពុទ្ធឃោសាចារ្យជាអ្នកចេះដឹងព្រះត្រៃបិដកចាក់ធ្លុះជំនាញ បានមកសរសេរសេចក្តីអធិប្បាយទុកឱ្យ ក៏មានសេចក្តីរីករាយ ទើបប្រគល់គណៈសង្ឃឱ្យព្រះពុទ្ធឃោសាចារ្យជាអ្នកពោលប្រាប់ បង្រៀនព្រះត្រៃបិដក ចំណែកព្រះពុទ្ធឃោសាចារ្យមិនព្រមទទួល ទើបប្រកាសកិច្ចរបស់ខ្លួនដែលព្រះឧបជ្ឈាយ៍

បញ្ជូនមកឱ្យប្រែ ព្រះបរិយត្តិធម៌ចេញពីសិង្ហលភាសាមកជា មគធភាសា ។

សម្តេចព្រះសង្ឃរាជ មានសេចក្តីត្រេកអរក្រៃលែងទទួល ពាក្យថា សាធុ ប្រពៃហើយបានអារាធនា ព្រះពុទ្ធឃោសាចារ្យ ឱ្យរចនាតាក់តែង "គម្ពីរព្រះវិសុទ្ធិមគ្គ" ដែលជាកំពូលធម៌នូវ ពាក្យទូន្មានអប់រំរបស់សម្តេចព្រះដ៏មានព្រះភាគ ឱ្យដូចគម្ពីរតែ មួយ ដើម្បីអាចឃើញបញ្ហាមុន ។

ព្រះពុទ្ធឃោសាចារ្យទទួលពាក្យ អារាធនាសម្តេច ព្រះ-សង្ឃរាជហើយ ទើបរចនាតាក់តែងគម្ពីរព្រះវិសុទ្ធិមគ្គបករណ៍ តាំងគាថាព្រះពុទ្ធដីកាថា "**សីលេ បតិដ្ឋាយ នរោ សបញ្ញោ**" ជាអាទិ៍ចុះជាគោលសូត្រ ហើយទើបរចនាតាក់តែងអដ្ឋកថា បាន យ៉ាងរហ័សក្រៃលែង គ្រាសម្រេចចប់ព្រះគម្ពីរហើយក៏ទុកដាក់រួច សិងលក់ទៅ ឯព្រះគម្ពីរនោះក៏បាត់ទៅដែរ ដោយសក្តទេវរាជា-នុភាព ។

នៅពេលតើនឡើងមិនឃើញគម្ពីររបស់ខ្លួន ក៏ចារគម្ពីរ ព្រះវិសុទ្ធិមគ្គឡើងទៀត ជាគម្រប់ពីរ យ៉ាងរហ័សជាទីបំផុត ដោយពន្លឺប្រទីបរួចស្រេច ក៏ដាក់គម្ពីរនោះទុក រួចសិងលក់បាត់

ទៅ ដោយទេវរាជានុភាពនៃសក្កទេវរាជទៀត ។ ឯព្រះ អ្នកជា
ម្ចាស់នៅពេលតើនឡើងមិនឃើញគម្ពីរ ជាគម្រប់ពីរនោះហើយ
ក៏ប្រញាប់ចារគម្ពីរព្រះវិសុទ្ធិមគ្គម្តងទៀត ជាគម្ពីរគម្រប់បី
ដោយពន្លឺប្រទីប លុះចាររួចហើយ ទើបចងគម្ពីរនោះទុកជាមួយ
ចីវរ ។

លុះដល់ពេលព្រឹក ព្រះអ្នកជាម្ចាស់តើនឡើង បានឃើញ
គម្ពីរព្រះវិសុទ្ធិមគ្គទាំងពីរ ដែលបានរចនាចារបាត់ទៅនោះ ដោយ
សក្កទេវរាជ បានយកមកសងវិញ ទុកដាក់នៅកន្លែងចាស់
ដដែល ព្រះអ្នកជាម្ចាស់ក៏មានសេចក្តីសោមនស្សរីករាយយ៉ាង
ក្រៃលែង ។

តាមគម្ពីរញ្ញាណោទ័យបករណ៍ពោលថា ដែលសក្កទេវ-
រាជានុភាព បណ្តាលឱ្យប្រព្រឹត្តទៅនោះ ក៏ដើម្បីឱ្យកើតបុញ្ញ-
កិរិយាវត្ថុដល់មហាជន ដើម្បីបានថ្វាយស្លឹកចារថ្មី ដល់ព្រះអ្នក
ជាម្ចាស់ ចារព្រះវិសុទ្ធិមគ្គ ទុកជាប្រយោជន៍ដល់ព្រះពុទ្ធសាសនា
បានច្រើនគម្ពីរ ។ តែបណ្ឌិតទាំងឡាយអនុមានថា ដែលសក្កទេវ-
រាជានុភាព ឱ្យហេតុប្រព្រឹត្តទៅនោះ ដើម្បីសម្តែងសេចក្តី
នៃបញ្ញាវិសារទៈ និងវីរិយៈឧស្សាហៈរបស់ព្រះអ្នកជាម្ចាស់ឱ្យ
ប្រាកដ ដល់ប្រជាជនលង្កាទ្វីបទូទៅ ។ រួចស្រេចហើយទើប

នាំគម្ពីរ ព្រះវិសុទ្ធិមគ្គ ទៅថ្វាយសម្តេចព្រះសង្ឃរាជ ។ ក៏មានសេចក្តីងឿងឆ្ងល់ក្នុងចិត្ត ទើបដាក់ឱ្យជំនុំសង្ឃ អ្នកចេះដឹងជំនាញក្នុងព្រះបរិយត្តិធម៌ ជួយពិនិត្យមើលខុសត្រូវ ព្រះវិសុទ្ធិមគ្គទាំងបីគម្ពីរ សព្វដែលមាននិបាត និងឧបសគ្គជាដើម ដែលព្រះអ្នកជាម្ចាស់បានរចនាតាក់តែង ហើយចារក្នុងបទណាៗ ក៏ស្មើស្មាន គ្នាល្អក្នុងបទនោះៗ តាំងនៅដូចដែលព្រះអ្នកជាម្ចាស់តាក់តែងចារទុកពីដំបូងទាំងបីគម្ពីរ ។

គម្ពីរព្រះវិសុទ្ធិមគ្គមាន ២៣ បរិច្ឆេទគឺ

បរិច្ឆេទទី ១ ឈ្មោះ សីលនិទ្ទេស សម្តែងប្រភេទសីល ផ្សេងៗ

បរិច្ឆេទទី ២ ឈ្មោះ ធុតង្គនិទ្ទេស សម្តែងពីធុតង្គវត្ត ១៣ ប្រការ

បរិច្ឆេទទី ៣ ឈ្មោះ កម្មដ្ឋានគហណនិទ្ទេស សម្តែងពីសមថៈកម្មដ្ឋាន ៤០ ប្រការ

បរិច្ឆេទទី ៤ ឈ្មោះ បឋវីកសិណនិទ្ទេស សម្តែងពី បឋវីកសិណជាដើម

បរិច្ឆេទទី ៥ ឈ្មោះ សេសកសិណនិទ្ទេស សម្តែងពីកសិណដែលនៅសល់ ៩ ប្រការ រួមជាមួយបឋវីកសិណ ទើបជា ១០ ប្រការ

បរិច្ឆេទទី ៦ ឈ្មោះ អសុភនិទ្ទេស សម្តែងពីអសុភ ១០ ប្រការ

បរិច្ឆេទទី ៧ ឈ្មោះ ឆានុស្សតិនិទ្ទេស សម្តែងពីអនុស្សតិ ៦ គឺ ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ និងទេវតានុស្សតិ

បរិច្ឆេទទី ៨ ឈ្មោះ សេសានុស្សតិនិទ្ទេស សម្តែងពីអនុស្សតិ ៤ ដែលនៅសល់គឺ មរណានុស្សតិ កាយគតាស្សតិ អានាបាណស្សតិ ឧបសមានុស្សតិ រួមជាមួយអនុស្សតិ ៦ ត្រូវជាអនុស្សតិ ១០ ប្រការ

បរិច្ឆេទទី ៩ ឈ្មោះ ព្រហ្មវិហារនិទ្ទេស សម្តែងពីព្រហ្មវិហារ ទាំង ៤ គឺ មេត្តា ករុណា មុទិតា និងឧបេក្ខា

បរិច្ឆេទទី ១០ ឈ្មោះ អរូបនិទ្ទេស សម្តែងពីអរូបសមាបត្តិ ៤ គឺ អាកាសានញ្ចាយតនៈ វិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ និងនេវសញ្ញានាសញ្ញាយតនសមាបត្តិ

បរិច្ឆេទទី ១១ ឈ្មោះ សមាធិនិទ្ទេស សម្តែងពីសមាធិជាមួយ បដិកូលសញ្ញា ធាតុវវត្ថាននិទ្ទេស

បរិច្ឆេទទី ១២ ឈ្មោះ ឥទ្ធិវិធីនិទ្ទេស សម្តែងពីឫទ្ធិវិធីផ្សេងៗ

បរិច្ឆេទទី ១៣ ឈ្មោះ អភិញ្ញានិទ្ទេស សម្តែងពីអភិញ្ញា ៥ មាន ទិព្វសោត ទិព្វចក្ខុនិងចេតោបរិយញ្ញាណ គឺដឹងវារចិត្តរបស់អ្នក ដទៃជាដើម

បរិច្ឆេទទី ១៤ ឈ្មោះ ខន្ធនិទ្ទេស សម្តែងពីបញ្ចក្ខន្ធ និងវិសេស នាមរបស់ខន្ធផ្សេងៗ

បរិច្ឆេទទី ១៥ ឈ្មោះ អាយតនធាតុនិទ្ទេស សម្តែងពីអាយតនៈ ១២ និងធាតុ ១៨

បរិច្ឆេទទី ១៦ ឈ្មោះ ឥន្ទ្រិយសច្ចនិទ្ទេស សម្តែងពីឥន្ទ្រិយ ២២ និងអរិយសច្ច ៤

បរិច្ឆេទទី ១៧ ឈ្មោះ ភូមិនិទ្ទេស សម្តែងពីធម្ម ៦ គឺ ខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ អរិយសច្ចៈ បដិច្ចសមុប្បាទ ដែលជា ភូមិភាគគ្រឹះវិបស្សនាកម្មដ្ឋាន

បរិច្ឆេទទី ១៨ ឈ្មោះ ទិដ្ឋិវិសុទ្ធិនិទ្ទេស សម្តែងពីសេចក្តីបរិសុទ្ធ នៃទិដ្ឋិ គឺការឃើញ

បរិច្ឆេទទី ១៩ ឈ្មោះ កង្ខាវិតរណវិសុទ្ធិនិទ្ទេស សម្តែងពីសេចក្តី បរិសុទ្ធដែលឆ្លងសេចក្តីសង្ស័យចេញបាន

បរិច្ឆេទទី ២០ ឈ្មោះ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនិទ្ទេស សម្តែងពីសេចក្តីបរិសុទ្ធក្នុងការឃើញអរិយមគ្គ ដោយញាណបញ្ញា ថារបស់នោះជាអរិយមគ្គ របស់នេះ មិនមែនអរិយមគ្គ

បរិច្ឆេទទី ២១ ឈ្មោះ បដិបទាញ្ញាណទស្សនវិសុទ្ធិនិទ្ទេស សម្តែងពីសេចក្តីបរិសុទ្ធក្នុងការឃើញដោយញាណបញ្ញាថា មគ្គគួរបដិបត្តិ

បរិច្ឆេទទី ២២ ឈ្មោះ ញាណទស្សនវិសុទ្ធិនិទ្ទេស សម្តែងពីសេចក្តីបរិសុទ្ធក្នុងការឃើញអរិយសច្ចៈ និងព្រះនិព្វាន ដោយញាណបញ្ញាដែលដឹងពិតឃើញពិតយ៉ាងជាក់ច្បាស់

បរិច្ឆេទទី ២៣ ឈ្មោះ ភាវនានិសង្សនិទ្ទេស សម្តែងពីអានិសង្ស-ផល នៃភាវនាក្នុងព្រះវិបស្សនាកម្មដ្ឋាន រួមជា ២៣ បរិច្ឆេទ ដោយបរិបូណ៌ ។

សម្តេចព្រះសង្ឃរាជាធិបតី បានឃើញគម្ពីរព្រះវិសុទ្ធិមគ្គ មានបទត្រឹមត្រូវល្អមិនមានវិបល្លាសឃ្លៀងឃ្លាត យ៉ាងណាមួយដូច្នេះហើយ ក៏មានចិត្តត្រេកអរវីកវាយក្រៃលែង ទើបទ្រង់អនុ-ញ្ញាតឱ្យព្រះពុទ្ធឃោសាចារ្យ ប្រែព្រះបរិយត្តិធម៌ចាក សិង្ហល-ភាសា មកជាមគធភាសា ហើយអនុញ្ញាតឱ្យសេនាសនៈ ដែលនៅក្នុងលោហាប្រាសាទជាបឋម ដើម្បីឱ្យព្រះអ្នកជាម្ចាស់ ធ្វើកិច្ចបរិវត្តព្រះបរិយត្តិធម៌បានដោយស្រួល ។

ក្នុងគម្ពីរញ្ញាណោទ័យបករណ៍ពោលថា សម្តេចបរម-
ក្សត្រិយទ្រង់ព្រះនាមថា ព្រះបាទមហានាមខត្តិយរាជ គ្រប់គ្រង
ក្នុងលង្កាទ្វីប បានទ្រង់យាងមកដោយរាជបរិពារ ត្រាស់បវារណា
ថ្វាយភិក្ខាហារបិណ្ឌបាតដល់ព្រះពុទ្ធឃោសាចារ្យ រហូតសម្រេច
ការបរិវត្តព្រះបរិយត្តិធម៌ ។ តាំងពីនោះព្រះពុទ្ធឃោសាចារ្យ
ក៏តាំងបណិធានវិរិយៈ ឧស្សាហៈ ប្រែព្រះបរិយត្តិធម៌ពុទ្ធវចនៈ
ពីសិង្គលភាសាមកជា មគធភាសា ព្រមទាំងបាលី និងអដ្ឋកថា
ដីកាអស់ត្រីមាសក៏សម្រេចការបរិវត្ត ។ ប៉ុន្តែក្នុងគម្ពីរញ្ញាណោ-
ទ័យបករណ៍ពោលថា អស់សមជ័ត្សរ (១ឆ្នាំ) ទើបសម្រេច ។
ចំណែកសម្តេចព្រះសង្ឃរាជជាកំពូលសង្ឃ ក៏ឱ្យអនុមោទនា ដោយ
ពោលគាថាសរសើរគុណ របស់ព្រះពុទ្ធឃោសាចារ្យជាអនេក
បរិយាយ ។

លុះការបរិវត្តិព្រះបរិយត្តិធម៌សម្រេចហើយ ព្រះពុទ្ធ
ឃោសាចារ្យក៏នមស្ការលាសម្តេចព្រះសង្ឃរាជាធិបតី និងព្រះសង្ឃ
ជាថេរានុថេរៈ ចុះសំពៅជាមួយពួកពាណិជត្រឡប់មកជម្ពូ
ទ្វីបនមស្ការ ប្រាប់ហេតុដល់ព្រះឧបជ្ឈាយ៍ឱ្យបានជ្រាបសព្វ
គ្រប់ប្រការ ។

រឿងនិទាន ប្រវត្តិព្រះពុទ្ធឃោសាចារ្យ មានពិស្តារក្នុង គម្ពីរពុទ្ធឃោសុប្បត្តិ និងគម្ពីរញ្ញាណោទ័យបករណ៍ ព្រមទាំងទី ដទៃផ្សេងៗ ដែលជ្រើសរើសច្រូតកាត់មកពោលក្នុង អារម្ភកថា នេះដោយសង្ខេប ល្មមទុកជាប្រដាប់សតិបញ្ញា និងសទ្ធាជ្រះថ្លា របស់សាធុជនត្រឹមប៉ុណ្ណោះ ។

(ដោយសមាគមស្រាវជ្រាវ ខាងផ្លូវព្រះពុទ្ធសាសនា ដែលមានសម្តេច ព្រះសង្ឃរាជញ្ញាណោទ័យមហាថេរៈ វត្តស្រះកេសរាជវរមហាវិហាររួមគ្នា។ កិត្តិយា ករសាសនូបត្ថម្ភពីសម្ងាក់ សម្តេចព្រះនាងជាម្ចាស់ព្រះបរមរាជិនីនាថ ដើម្បីប្រយោជន៍ ក្នុងព្រះពុទ្ធសាសនាតទៅ) ។ ព្រះពុទ្ធឃោស ក្នុងរវាងព.ស.១000 ឆ្នាំ ។

ព្រះត្រៃសរណគមន៍ជាឥតីពិធ

សាសនាមានច្រើននៅក្នុងលោក ស្រាវជ្រាវជ្រើសយកបានតែមួយ
ព្រះពុទ្ធសាសនាទុកជាត្រួយ បានជួយរួចទុក្ខសត្វគ្រប់គ្នា ។
ព្រោះមានចក្ខុឃើញ**ធម្ម** ត្រាស់ដឹងសច្ចៈដោយវិជ្ជា
នៅគល់ពោធិព្រឹក្សពុទ្ធគយា ដើម្បីស្ថារលាចេញចាកភព ។
នាមរូបក្រសែនៃជីវិត សភាវធម៌ពិតគួរសេពគប់
ដោយមិនត្រូវការអ្វីមានគ្រប់ ចូលជ្រកក្រោមម្លប់បានសុខា ។
បើមិនទាន់ដល់ខំប្រឹងស្រូត កុំឱ្យរបូតត្រៃសិក្ខា
អាយុខ្លីណាស់តោងឧស្សាហ៏ ស្តាប់ធម្មទេសនារាល់យប់ថ្ងៃ ។
ក្រមានព្រះត្រាស់ក្រសម្តែង ធម៌ក្នុងខ្លួនឯងកុំស្រមៃ
ថានៅឯណាពិបាកថ្នែ គិតលៃរៀនសូត្រឱ្យបានល្អ ។
ធ្វើការងារអ្វីក៏ធ្វើចុះ តែកុំសន្តោសកុសលធម៌
ស្គាល់ពូជនាមរូបមានភ័ព្វល្អ លោកិយអង្វរសុំចុះចាញ់ ។
បើនៅតែខឹងស្រឡាញ់ស្អប់ នាមរូបសន្ធប់ជាប់សំណាញ់
ទិដ្ឋិអូសទាញដោយចិត្តក្តាញ់ ចម្រាញ់យកជលរងទុក្ខទៀត ។
មានតែសតិតម្កល់មាំ នាមរូបសន្សំដាក់សម្បើត
លើកងតណ្ហាតែងចូលជ្រៀត ឈប់ឆ្លៀតយកទោសដល់សព្វសត្វ ។
ឱ្យមានសេរីសុខក្សេមក្សាន្ត ជ្រុះអស់ខ្លួនប្រាណសល់បរមត្ថ
តាមផ្លូវកណ្តាលយ៉ាងស្ងៀមស្ងាត់ កម្ចាត់ទុក្ខសោករួចចាកលោក ។

ដោយ នា-សុខា

មតិបូកសរុប

កាលណាគេបានដឹងនូវមង្គល គឺសិរីសួស្តីស្រេចបាច់ហើយ គេក៏មានសេចក្តីត្រេកអររីករាយឥតឧបមា ព្រោះជាការកម្រ មិនអាចសម្បូរហូរហៀរ ដូចការដឹងនូវអ្វីផ្សេងក្រៅពីនេះឡើយ ព្រោះការកើតឡើងនូវសភាវៈនោះមានហេតុ មានបច្ច័យគ្រប់គ្រាន់ ។ ការមានជីវិតរស់នៅ ការកើតឡើងនៃព្រះពុទ្ធ ការបានស្តាប់ធម៌របស់ព្រះសម្មាសម្ពុទ្ធ ក៏ជាការកម្រដូចគ្នា យ៉ាងណា ការបានចូលទៅរកសប្បុរស មានព្រះពុទ្ធអង្គ ជាសរណៈនោះក៏ជាការកម្រ ព្រោះជាលាភក្នុងសង្សារវដ្ត ដែលត្រូវបានទទួលនូវព្រះសទ្ធម្ម ដើម្បីរលាស់ខ្លួនចេញចាកភព ។ ទាំងនេះសុទ្ធតែមានតម្លៃកាត់ថ្លៃមិនបាន ក៏ជាឱកាសមួយ សែនមហាក្រសម្រាប់យើងទាំងអស់គ្នា អ្នកមានឧបនិស្ស័យ ។ ប៉ុន្តែផ្ទុយទៅវិញ អ្នកដែលមិនបានចូលទៅសេពគប់នឹងបណ្ឌិត ហើយត្រឡប់ជាចូលទៅរកបុគ្គលពាលវិញ បង្ហាញប្រាប់ថា អ្នកនោះជាមនុស្សឥតលាភ ព្រោះជាបុគ្គលអភ័ព្វ តែងរស់នៅគ្រាន់តែចង្អៀតលោក រង់ចាំតែសេចក្តីស្លាប់មកដល់ប៉ុណ្ណោះ ដែលមានសម្តែងនៅក្នុងមង្គលសូត្រ និងបរាភវសូត្រ ។ ដំណើរនេះ បង្ហាញថាជីវិតមិនមែនសុទ្ធតែ មានតម្លៃដូចយើងនឹកគិតថា យើងមាន

ចំណេះវិជ្ជាផ្លូវលោក ឆ្លៀវឆ្លាតក្នុងការរកទទួលទាន មានទ្រព្យ
សម្បត្តិច្រើន មានរបស់ប្រើប្រាស់ល្អៗមានតម្លៃច្រើន ដូចសម័យ
ដែលគេនិយមចូលចិត្តនូវសម្ភារៈទំនើប តាមការចម្រើនជឿន
លឿនខាងផ្នែកវិទ្យាសាស្ត្រថា ថ្ងៃថ្នូរហើយ នេះក៏នៅមិនទាន់
ល្អប្រសើរ លុះត្រាតែអ្នកនោះមានធម៌ចម្រើនលូតលាស់
នៅក្នុងខ្លួនថែមទៀត ជាមនុស្សរស់នៅ ជួយលោកបម្រើលោក
ឱ្យអស់ពីសមត្ថភាពរបស់ខ្លួន ដូចយ៉ាងព្រះពុទ្ធអង្គ ទ្រង់បាន
ត្រាស់ដឹងឡើងសម្តែងធម៌ប្រោស ធ្វើឱ្យសត្វលោក មានពួក
ទេវតា មារព្រហ្ម និងមនុស្សលោក ឆ្លងរួចពីសេចក្តីទុក្ខ ឬក៏មាន
អ្នកដទៃណាផ្សេងក្រៅពីនេះ អាចសម្តែងធម៌តាមពាក្យទូន្មាន
ប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គក៏បានដែរ ។ ក្នុងសម័យពុទ្ធកាល
គេមិននិយមទ្រព្យសម្បត្តិជាធំទេ គេនិយមអ្នកមានបញ្ញាស្មារតី
ដោយសតិថ្នាក់ សតិប្បដ្ឋានវិបស្សនា រលឹកដឹងទាន់នូវសភាវ-
ធម៌កំពុងប្រាកដ ដូចយ៉ាងដែលព្រះដ៏មានប្រភាគទ្រង់ត្រាស់
សម្តែង មហាសតិប្បដ្ឋានសូត្រនាដែនកុរុ បានបន្សល់ទុកនៅពុទ្ធស្ថាន
ច្រើនកន្លែងក្នុងប្រទេសឥណ្ឌា ព្រមដោយប្រជាជនក្នុងសម័យនោះ
គេនិយមរាប់អានគ្នា ថាបើមាន អ្នកណាមិនចេះ មិនដឹងនូវ
មហាសតិប្បដ្ឋានសូត្រ គេក៏ជួយប្រាប់ ឱ្យបានចេះដឹងដូចគ្នា
ក៏ជាសម័យមួយ គេនិយមរាប់អានអ្នកមាន ចំណេះវិជ្ជាខាងផ្លូវ
ព្រះពុទ្ធសាសនា បើនិយាយឱ្យខ្លីទៅ សម័យ មាន ២ យ៉ាង

គឺសម័យគេនិយមសម្ភារៈ និងសម័យគេនិយមបញ្ញាស្មារតី ក្នុងការលើកតម្កើងធម៌វិន័យព្រះពុទ្ធសាសនា ។

ដំណើរនេះមានប្រការ ដែលគួរឱ្យយកចិត្តទុកដាក់ខ្លាំងទៅលើការរួចផុតចាកទុក្ខ ដូចបានលើកយកមង្គលសូត្រ សម្តែងប្រាប់ ជាការបើកទ្វារបញ្ញា ដើម្បីលះបង់ចោលនូវអ្វីមិនល្អ (គ្រឿងសៅហ្មង) ដែលពពួកសត្វកំពុងហែលក្នុងសមុទ្រសង្សារ ឱ្យភ្ញាក់ឡើងតោងក្បួន អរិយមគ្គមានអង្គ ៨ ប្រការ ទុកជាទីពឹងរបស់ខ្លួន ហើយធ្វើដំណើរទៅរកព្រះនិព្វាន បានដល់ការសេពគប់សប្បុរស ជាខាងដើម ដោយសេចក្តីថា យកធម៌ជាទីពឹង មិនយកអ្វីដទៃក្រៅពីនេះជាទីពឹង ដែលមិនមែនជាធម្មជាតិដូចការសេពគប់ជនពាលជាដើម ។

ការសិក្សាអប់រំផ្លូវចិត្ត មិនមែនប្រើពេលវេលាឆាប់រហ័សទេ ជាការសន្សំបន្តិចម្តងៗ ដោយការព្យាយាម លុះត្រាបានគ្រប់គ្រាន់ក៏បារមីនោះនឹងមានផលផ្លែផ្កាក្នុងពេលណាមួយ ក៏ត្រូវទទួលផលពុំមានអ្វីមកកែប្រែបានយ៉ាងណា ការបានសម្រេចមគ្គផលដូចទេវតា មកទូលសួរមង្គលដល់ព្រះសម្ពុទ្ធ នាពេលនេះជាឱកាសល្អកម្រមាន ។ គិតទៅមង្គលសូត្រ ទុកដូចជាអារម្មណ៍របស់សតិបដ្ឋានវិបស្សនា មានត្រឹមតែរូបធម៌នាមធម៌ រួបរួមប្រជុំចុះនៅក្នុងអាយតនសព្វៈ អ្នកបានស្តាប់ទៅហើយក៏មានចិត្តជ្រះថ្លារីករាយយ៉ាងក្រៃលែង ព្រោះជាកិច្ចបដិបត្តិតែមួយគត់ក្នុង

ព្រះពុទ្ធសាសនា ដែលមានតែព្រះពុទ្ធមួយព្រះអង្គឯងប៉ុណ្ណោះទើប
សម្តែងប្រោសសត្វបាន ។ ដូច្នោះ ការសន្សំបុណ្យនាំមកនូវ
សេចក្តីសុខ ការមិនសន្សំបុណ្យនាំមកនូវសេចក្តីទុក្ខ ដែលសត្វ
ទាំងឡាយបានស្តាប់នូវមង្គលសូត្រ ព្រោះមានការសិក្សា ជា
បណ្តើរ ការបដិបត្តិក៏មានជាមួយការសិក្សា ឯការចាក់ធ្លុះ ក៏នៅ
ទន្ទឹមគ្នា នឹងការបដិបត្តិ ។ ទាំង ៣ សទ្ធម្ម កើតឡើង ដំណាលគ្នា
ពុំមានអ្នកណាចេះវែកញែក ឱ្យដាច់ពីគ្នាបានទេ ហៅថា ជា
សតិប្បដ្ឋានប្បដិបត្តិ ចូលទៅអុចប្រទីបបញ្ញា ឱ្យភ្លឺស្វាងឆ្ពុះ
មើលនូវអ្វីៗក្នុងទីងងឹត ដើម្បីឃើញការពិត រួចក៏លែងប្រកាន់
អ្វីទាំងពួង បានដល់ទីបំផុតទុក្ខ ដោយបានលះបង់ នូវសក្កាយទិដ្ឋិ
ព្រោះពិចារណានិងអប់រំចម្រើនបញ្ញា មាន នាមរូបជាអារម្មណ៍
រឿយៗ ដែលនាមរូបនោះមិនត្រូវការអ្វី ហើយក៏ពុំមានអ្វី
ទាំងអស់ មានត្រឹមតែហេតុ និងបច្ច័យប៉ុណ្ណោះ ឯង ។

បញ្ជីរាយនាមពុទ្ធបរិស័ទចូលរួមចោះពុម្ពស្បៀវភៅ

- លោក ច័ន្ទ រស្មី និងអ្នកស្រី ពុទ្ធិដា ព្រមទាំងបុត្រ	60 $
- ឧបាសិកា កាំង ហ្គេចណៃ និងស្វាមី ព្រមទាំងបុត្រ	50 $
- ឯកឧត្តម សុខ សុរិយា និងឧបាសិកា ធូ វេជ្ជសារ ព្រមទាំងបុត្រ	50 $
- លោក ថាប ឆេង និងភរិយា ព្រមទាំងបុត្រ	50 $
- លោក ញ៊ីប ប៉េងហាក់ និងភរិយា ព្រមទាំងបុត្រ	50 $
- ឧបាសិកា បញ្ញា សារី ព្រមទាំងកូនចៅ	50 អូស្ត្រាលី
- ឧបាសិកា ហុក គីមស្រ៊ាង និងស្វាមី ព្រមទាំងបុត្រ	20 $
- ឧបាសិកា ឧត្តមា ពេជ្រអូន ព្រមទាំងកូនចៅ	10 $
- ឧបាសក លន់ គីមស៊ុយ ព្រមទាំងកូនចៅ	10 $
- ឧបាសក អ៊ិន បូ ព្រមទាំងកូនចៅ	10 $
- ឧបាសិកា ហ៊ុន ហេង និងស្វាមី ព្រមទាំងបុត្រ	20 $
- ឧបាសិកា ផាំង ស្រួយ ព្រមទាំងកូនចៅ	10 $
- ឧបាសិកា កាំង ប៉ោទាង ព្រមទាំងកូនចៅ	10 $
- ឧបាសិកា អេង ឆេងហ៊ាត ព្រមទាំងកូនចៅ	10 $
- ឧបាសិកា ឯក សារី និងប្អូន	10 $
- ឧបាសិកា ខាំ នាង សុខឺ និងស្វាមី ព្រមទាំងកូនចៅ	15 $+20.000៛
- ឧបាសក សាំង ហឿន និង អួង ឈុនហួង	10 $
- លោក ឡាយ គីមស្រ៊ី និងភរិយា	10 $
- ឧបាសិកា លន់ ច័ន្ទថារី និងស្វាមី ព្រមទាំងបុត្រ	10 $
- ឧបាសិកា លន់ ច័ន្ទថុល និងស្វាមី ព្រមទាំងបុត្រ	10 $
- ឧបាសិកា ជំ ប៉ុន ព្រមទាំងកូនចៅ	5 $

- ឧបាសិកា ហោង សុចិន្តា និងស្វាមី ព្រមទាំងបុត្រ 10.000៛
- ឧបាសិកា បួន ធល ព្រមទាំងកូនចៅ 10.000៛
- ឧបាសិកា ម៉ៅ ផុន និង យីម ផល្លី 10.000៛
- ឧបាសិកា ឃុត វ៉ាន់ថា និងស្វាមី ព្រមទាំងកូនចៅ 10.000៛
- ឧបាសិកា នេត សុថន និងស្វាមី ព្រមទាំងកូនចៅ 10.000៛
- ឧបាសិកា អាយ យាគ ព្រមទាំងកូនចៅ 10.000៛
- ឧបាសក ម៉ៅ ស្រ៊ីន និងភរិយា ព្រមទាំងបុត្រ 10.000៛
- ឧបាសក ចាន់ ឡៃហោង និងភរិយា ព្រមទាំងបុត្រ 10.000៛
- ឧបាសិកា ឈិន សាមេត ព្រមទាំងបុត្រ 10.000៛
- ឧបាសិកា យាយ ខ្សែង 10.000៛
- ឧបាសិកា អ៊ុក ហាសុកាន ព្រមទាំងបុត្រ 10.000៛
- ឧបាសិកា ង៉ោ ឆេង ព្រមទាំងបុត្រ 10.000៛
- ឧបាសិកា វ៉ាយ វុទ្ធា ព្រមទាំងបុត្រ 10.000៛
- ឧបាសិកា លីម ស្បៃវង៉ោ ព្រមទាំងកូនចៅ 10.000៛
- ឧបាសិកា ជា គីមហ៊ាប ព្រមទាំងកូនចៅ 10.000៛
- លោក អ៊ូច ដាវី និងភរិយា ព្រមទាំងបុត្រ 10.000៛
- ឧបាសិកា សយ សុផល ព្រមទាំងបុត្រ 10.000៛
- ឧបាសិកា ជ័យ យ៉ែង និង ជ័យ យ៉ន 10.000៛
- ឧបាសិកា ស្រុន កែវ 10.000៛
- ឧបាសក ទេព ជា និងភរិយា ព្រមទាំងកូនចៅ 20.000៛
- ឧបាសក ឃ្លោក ប៉េងឆាង និងភរិយា 10.000៛
- ឧបាសិកា អ៊ីម ប៉េងជូ 10.000៛

- ឧបាសិកា អ៊ូច ណន 10.000៛
- ឧបាសិកា ម៉ក គីមអូន 10.000៛
- ឧបាសិកា សាធ ណាគ្រី 10.000៛
- ឧបាសក សុខ យិន និងភរិយា ចិន តុន ព្រមទាំងកូនចៅ 20.000៛
- ឧបាសិកា ស្រី វិ ចិន្តា 10.000៛
- ឧបាសក រស់ សំបូរ និងឧបាសិកា ឡៃ សំអឿន 10.000៛
- ឧបាសក តុន ថៃ និងឧបាសិកា ព្រំ យ៉ាត ព្រមទាំងបុត្រ 10.000៛
- ឧបាសិកា សារី វីនី ព្រមទាំងកូនចៅ 10.000៛
- លោក លាង តូ និងឧបាសិកា ហោង សុធា ព្រមទាំងបុត្រ 10.000៛
- ឧបាសិកា សរ ដារី ព្រមទាំងកូនចៅ 10.000៛
- ឧបាសិកា ស៊ីវ ស៊ីនួន ព្រមទាំងកូនចៅ 10.000៛
- ឧបាសិកា មួយ ស្រុន 10.000៛
- ឧបាសក ឌ្សៀប លាង និងឧបាសិកា សំ អូន ព្រមទាំងកូនចៅ 10.000៛
- ឧបាសក សែស សុខន ព្រមទាំងបុត្រ 10.000៛
- ឧបាសិកា តាំង ប៉ោជីង (ហៅទន់) ព្រមទាំងបុត្រ 10.000៛
- ឧបាសក ឡាយ ច្រឹង និងភរិយា 10.000៛
- ឧបាសក ម៉ុង ហៃ និងភរិយា 10.000៛
- ឧបាសិកា ចាន់ ណន ព្រមទាំងកូនចៅ 10 $
- ឧបាសិកា ពេជ្រ សុឃិត 5 $
- ឧបាសិកា ឈួរ ច្រីសាន្ត និងឧបាសិកា សុខ ច័ន្ទ ព្រមទាំងកូនចៅ 5.000៛
- ពុទ្ធបរិស័ទ្ធចូល 5.000៛ ចំនួន ៣៣ នាក់ 165.000៛
- ពុទ្ធបរិស័ទ្ធចូល 7.000៛ ចំនួន ០៣ នាក់ 21.000៛

- ពុទ្ធបរិស័ទ្ធចូល 6.000៛ ចំនួន ០២ នាក់	12.000៛
- ពុទ្ធបរិស័ទ្ធចូល 2500៛ ចំនួន ០១ នាក់	2500៛
- ពុទ្ធបរិស័ទ្ធចូល 2.000៛ ចំនួន ០២ នាក់	4.000៛
- ឧបាសិកា ឈាវ សុភី ព្រមទាំងកូនចៅ	10 $
- លោក ឡាយ អូវ និងអ្នកស្រី ស៊ុន ដាឡែន ព្រមទាំងបុត្រ	10 $
- ឧបាសិកា គង់ សុកហៀក ព្រមទាំងកូនចៅ	20.000៛
- ឧបាសិកា ផៅ សូគិ ព្រមទាំងកូនចៅ	5.000៛
- ឧបាសិកា សៅ ចំរើន ព្រមទាំងកូនចៅ	5.000៛
- ឧបាសិកា រស់ វណ្ណា ព្រមទាំងកូនចៅ	5.000៛
- ឧបាសិកា ឈុន ចំណាន	5.000៛
- យាយ អូន ព្រមទាំងកូនចៅ	10.000៛
- ឧបាសិកា ម៉ម សារ៉ុន និងឧបាសក អ៊ុង ជា ព្រមទាំងកូនចៅ	20.000៛
- ឧបាសិកា ជា ឆេងអូន ព្រមទាំងកូនចៅ	20.000៛

ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ
ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា។

ប្រែថា: បុគ្គល កាលស្វះស្វែងរកកល្យាណមិត្ត ប្រសិនបើ មិនបានមិត្តដ៏ប្រសើរជាងខ្លួនឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯង ឱ្យខ្ជាប់ខ្ជួនវិញ ព្រោះថា សហាយតាគុណគឺ ចូឡសីល មជ្ឈិមសីល មហាសីល កថាវត្ថុ១០ ធុតង្គគុណ១៣ វិបស្សនាគុណ មគ្គ៤ ផល៤ វិជ្ជា៣ អភិញ្ញា៦ មិនមានក្នុងបុគ្គលពាលឡើយ ។

ISBN-13: 978-999-63-587-6-0